# អដ្ឋកថា បបញ្ចសូទនី

## នៃព្រះសុត្តន្តបិដក

## មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក

## ឆដ្ឋភាគ

## ភាគ ២៥

អធិប្បាយ

ព្រហ្មាយុ-សេល-អស្សលាយន-ឃោដមុខ-ចង្កី-ឯសុការី-ធនញ្ជានិ-វាសេដ្ឋ-សុភ-សគារវ

ពុទ្ធសករាជ ២៥៥៤

# អដ្ឋកថា ព្រះសុត្តន្តបិដក

## មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក

## ឆដ្ឋភាគ

## ភាគ ២៥

ឈ្មោះ

# បបញ្ចសូទនី

ពុទ្ធសករាជ ២៥៥៤

អធិប្បាយ

ព្រហ្មាយុ-សេល-អស្សលាយន-ឃោដមុខ-ចង្កី-ឯសុការី-ធនញ្ជានិ-វាសេដ្ឋ-សុភ-សគារវ

# ស្រៈនិងស្រ៍យ

## *Signes et accents:*



# ស្រៈពេញតួ

# *Voyelles.*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រូម Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອະ | ອາ | ອິ | ອີ | ອຸ | ອູ | ເ | ໂອ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ
# Consonnes:

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក | ខ | គ | ឃ | ង |
| រូប Romain | k | kh | g | gh | ṅ |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| សិង្ហ Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

D


Cambodgien
Romain
c ch j jh ñ
Siamois
Laotien
Cinghalais
Birman

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ដ | ឋ | ឌ | ឍ | ណ |
| រូប Romain | ṭ | ṭh | ḍ | ḍh | ṇ |
| សៀម Siamois | ฏ | ฐ | ฑ | ฒ | ณ |
| លាវ Laotien | ᨭ | ᨮ | ᨯ | ᨰ | ᨱ |
| សិង្ហល Cinghalais | ට | ඨ | ඩ | ඪ | ණ |
| ភូមា Birman | ဋ | ဌ | ဍ | ဎ | ဏ |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន |
| [illegible] | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| លាវ Laotien | ຕ | ຖ | ທ | ດ | ນ |
| សិង្ហ Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប | ផ | ព | ភ | ម |
| [illegible] Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ປ | ຜ | ພ | ຠ | ມ |
| លង្កា Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |


CAMBODGIEN
Romain
y r l v s h ḷ ṃ ./.
Siamois
Laotien
Cinghalais
Birman

# ពាក្យផ្ដើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

***សុត្ត*** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។

***គេយ្យ*** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

***វេយ្យាករណ*** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

***គាថា*** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

***ឧទាន*** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

***ឥតិវុត្តក*** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

***ជាតក*** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

***អព្ភូតធម៌*** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។

***វេទល្ល*** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបាននូវសេចក្ដី

រីករាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

> ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
> ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
> មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
> បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្ដែងធម៌មានហេតុផល ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ច្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាម អាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយ ច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមក ហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះ ខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយ ខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្អាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្ពាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញ៉ាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសររៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថាសង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្ដី ត្រកូលអាចារ្យ ១៨ ក្ដី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ៗ

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាន នាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរ អដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យ នោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុក ជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិត ស្ពានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍- សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញា ច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែល សមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះ បោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា**ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្ដើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវ័ក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុក ជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថា ទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តី ចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះ ពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាន និមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿង ប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាម ដទៃទៀតថា ( សិរិនិវាស ) ខ្លះ ( សិរិកុថៈ ) ខ្លះ ( សិរិកូដ្ឋៈ ) ខ្លះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុង មហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់ អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃ ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមាន ព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន
រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់
ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ
ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា
បានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន
រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដង
ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ
វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ
ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ
ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ
ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ
ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី
សម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ
ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ
នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការបានប្រកាសថា លោកអង្គ
នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ
ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់
លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយទមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធា-នឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋ-កថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរីយៈ ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្ដាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសះ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

ឧបាសក ក្អាត ហ៊ន

ឧបាសក ទុំ ទូន

ឧបាសក ជឹម ជំនិត

ឧបាសក សន ម៉ារឌី

ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក សំ ឆាយ

ឧបាសក ជា ស៊ីបាន

ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា យស សម្បត្តិ

ឧបាសិកា ប៊ុត សេដាដួង

ឧបាសក នាក់ ម៉ៅ

ឧបាសក ហុក សឹងហួត

ឧបាសក កើត ទិត្យ

ឧបាសក ហាយ ចំរើន

ឧបាសក សុក្រ ហ៊ត

ឧបាសក ម៉ៅ ផុន

ឧបាសិកា ថាប់ លឿម

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា ពូ ហ៊ាង

ឧបាសិកា ប៉ែន រម្មណីយ

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

## ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

ព្រះភិក្ខុអគ្គទិន្នោ នូវ បូរ៉ា ប្រធានអាស្រម

ព្រះភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ធម្មាចារ្យ

ព្រះភិក្ខុធម្មប្បញ្ញោ ឆ្នំ សារឿន ធម្មាចារ្យ

ព្រះភិក្ខុវរធម្មោ ផុត តៅ ធម្មាចារ្យ

ព្រះភិក្ខុសារញ្ញាណោ ស សត្ថា ធម្មាចារ្យ

ព្រះភិក្ខុកល្យាណធម្មោ យឿន កល្យាណ វិនយាចារ្យ

សាមណេរ អគ្គកាមោ អ៊ឹម សុជាន សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិនោ ចាន់ បូណា សមណសិស្ស សាលាសតិប្បដ្ឋាន

## ផ្នែកឧបាសក

ឧបាសក ក្អាត ហ៊ន ឧបាសក ហាយ ចំរើន

ឧបាសក សន ម៉ារឌី ឧបាសក អ៊ឹម វ៉ៃយ៉ា

ឧបាសក ទុំ ទូន ឧបាសក ហុក សឹងហួត

ឧបាសក ឈួន សំណាង ឧបាសក ឃឿម សារ៉េន

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវរក្សត្រ និងមហាវរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រៃភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះបានស្មើ ៗ គ្នា

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

*ឈ្មោះធម៌* | *ទំព័រ*

## ព្រាហ្មណវគ្គ


| | |
|---|---|
| អដ្ឋកថា ព្រហ្មាយុសូត្រ ទី១ | ១ |
| *វេទ ៣ ប្រការ* | *២* |
| *តម្រាទាយលក្ខណៈ* | *៣* |
| *វិនិច្ឆ័យ ពាក្យថា រតនៈ* | *៨* |
| *បទថា ធម្មេន* | *១១* |
| *ព្រះលក្ខណៈ ២ ប្រការ* | *១៣* |
| *ពុទ្ធកិច្ច ៥ យ៉ាង* | *១៩* |
| *លក្ខណៈព្រះបាទ* | *២៤* |
| *លក្ខណៈព្រះកាយ* | *៣១* |
| *លក្ខណៈព្រះទន្ត* | *៣៦* |
| *លក្ខណៈព្រះសូរសេង* | *៣៧* |
| *រឿងព្រះនាងអសន្ធិមិត្តា* | *៣៩* |
| *លក្ខណៈព្រះនេត្រ* | *៤០* |
| *ព្រះឧណ្ណាលោម* | *៤១* |
| *លក្ខណៈព្រះនលាដ៍* | *៤២* |
| *លក្ខណៈនៃពុទ្ធដំណើរ* | *៤៤* |
| *លក្ខណៈប្រថាប់អង្គុយ* | *៤៨* |
| *លក្ខណៈទទួលបិណ្ឌបាត្រ* | *៥០* |
| *លក្ខណៈនៃការអនុមោទនាគាថា* | *៥៣* |
| *លក្ខណៈនៃការស្លៀកដណ្តប់* | *៥៤* |

លក្ខណៈសំឡេង ៥៦
កាលត្រូវទូលសួរ ៥៩
អ្នកនឹងដល់ត្រើយ ៦០

អដ្ឋកថា សេលសូត្រ ទី ២ ៦៤
ពាក្យថា ពុទ្ធោ ៦៧
ព្រះសាស្ដាទ្រង់ជាព្រះរាជា ៧១
បុត្រ ៣ ពួក ៧៤

អដ្ឋកថា អស្សលាយនសូត្រ ទី ៣ ៨០
វណ្ណៈ ៤ ៨៤

អដ្ឋកថា ឃោដមុខសូត្រ ទី ៤ ៨៨

អដ្ឋកថា ចង្កីសូត្រ ទី ៥ ៩២
ប្រវត្តិចង្កីព្រាហ្មណ៍ ៩២
អំបូរនៃវង្ស ៩៦
វាចាពីរោះ ១០០
ការពោលគុណព្រះមានព្រះភាគរបស់ចង្កីព្រាហ្មណ៍ ១០១
កម្ពស់ព្រះមានព្រះភាគមិនអាចវាស់បាន ១០៤
ឧបមាដូចមនុស្សខ្វាក់ក្អែក ១១១
បទថា បធានៈ ១១៥

អដ្ឋកថា ឯសុការីសូត្រ ទី ៦ ១១៧

អដ្ឋកថា ធនញ្ជានិសូត្រ ទី ៧ ១២០

ក្រុងរាជគ្រឹះ ១២០
ពាក្យថា អធម៌ ១២២

**អដ្ឋកថា វាសេដ្ឋសូត្រ ទី ៨** ១២៤
ព្រែតប្ចានផ្លែៈ ១២៤
វាសេដ្ឋមាណព ១២៦
ការត្រាស់តាមលំដាប់ ១២៧
ឈ្មោះថា ព្រាហ្មណ៍ ១៣៤
ឧបមាដូចរថ ១៤៤

**អដ្ឋកថា សុភសូត្រ ទី ៩** ១៤៧
ឧបមាការធ្វើស្រែ និងធ្វើជំនួញ ១៤៨
អធិប្បាយធម៌ ៥ ប្រការ ១៥០
បោក្ខរសាតិព្រាហ្មណ៍ ១៥២
បទថា ស្វាស្ស .... ១៥៥
ប្រៀបដូចជាអ្នកផ្លុំស័ង្ខ ១៥៩

**អដ្ឋកថា សគារវសូត្រ ទី ១០** ១៦២
វាទៈរបស់ព្រាហ្មណ៍ ១៦៤
ពាក្យថា ទេវៈ ទេវី ១៦៨

# អដ្ឋកថា ព្រះសុត្តន្តបិដក

## មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ

ឈ្មោះ បបញ្ចសូទនី

ឆដ្ឋភាគ

## ភាគ ២៥

# ព្រាហ្មណវគ្គ

## អ ដ្ឋ ក ថា

## ព្រហ្មាយុសូត្រទី ១

**[១]** *ព្រហ្មាយុសូត្រ មានបទផ្តើមថា ឯវម្មេ សុតំ ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ៖*

*ក្នុងព្រហ្មាយុសូត្រនោះ ពាក្យថា ធំ ក្នុងបទថា ជាមួយនឹងភិក្ខុសង្ឃច្រើននោះ ឈ្មោះថា ធំ ព្រោះធំដោយគុណខ្លះ ធំដោយចំនួនខ្លះ ។*

*ពិតណាស់ ពួកភិក្ខុនោះ ជាពួកធំ សូម្បីដោយគុណទាំងឡាយ ។ រាប់ថា ធំ ព្រោះប្រកបដោយគុណ មានសេចក្តីប្រាថ្នាតិចជាដើម និងព្រោះរាប់បាន ៥០០ រូប ។ ពួកនៃភិក្ខុ ឈ្មោះថា ភិក្ខុសង្ឃ ។ អធិប្បាយថា ពួក*

សមណៈដែលមានទិដ្ឋិសាមញ្ញតា និងសីលសាមញ្ញតា ស្មើគ្នា ។ ពាក្យថា ព្រម គឺ ជាមួយគ្នា ។ ពាក្យថា ភិក្ខុប្រមាណ ៥០០ រូប គឺ ឈ្មោះថា មានប្រមាណប្រាំ ព្រោះប្រមាណប្រាំនៃរយរបស់ភិក្ខុទាំងនោះ ។ ប្រមាណ លោកហៅថា មាត្រា ។ ព្រោះដូច្នោះ ទើបមានពាក្យអធិប្បាយថា ភិក្ខុ ស្គាល់មាត្រា គឺ ដឹងប្រមាណក្នុងភោជន ដែលត្រាស់ថា ជាអ្នកដឹងប្រមាណ ក្នុងភោជន យ៉ាងណា សូម្បីក្នុងទីនេះក៏គប្បីឃើញសេចក្ដីយ៉ាងនេះថា ប្រមាណ ៥ បានដល់ ប្រមាណប្រាំនៃរយរបស់ភិក្ខុទាំងនោះ ដូច្នោះ ។ រយទាំង ឡាយនៃពួកភិក្ខុ ឈ្មោះថា រយនៃភិក្ខុទាំងឡាយ ។ និងរយនៃភិក្ខុទាំងឡាយ មានប្រមាណប្រាំទាំងនោះ ។

ពាក្យថា **មានឆ្នាំ ១២០** គឺ មានអាយុ ១២០ ឆ្នាំ ។ ពាក្យថា **នៃ វេទទាំងបី** គឺ ឥរុវេទ យជុវេទ និងសាមវេទ ។ ឈ្មោះថា **អ្នកដល់ត្រើយ** ព្រោះដល់ត្រើយ ដោយអំណាចការស្ទាត់ជំនាញរត់មាត់ ។ ព្រមដោយ និឃណ្ឌុ និងកេដុភៈ ឈ្មោះថា ព្រមដោយនិឃណ្ឌុ និងកេដុភៈ ។ សាស្ត្រ ដែលប្រកាសពាក្យសម្រាប់ប្រើជំនួស និឃណ្ឌុសាស្ត្រ និងរុក្ខសាស្ត្រជាដើម ឈ្មោះ សនិឃណ្ឌុ ។ កេដុភៈ បានដល់ ការកំណត់កិរិយាអាការ ដែលជា

សាស្ត្រសម្រាប់ប្រើជាគ្រឿងដៃរបស់ពួកកវី ។ ឈ្មោះថា **ព្រមទាំងប្រភេទអក្សរ** គឺ បានដល់ អក្ខរប្បភេទ ។ ពាក្យថា **អក្ខរប្បភេទ** បានដល់ សិក្ខា និងនិរុត្តិ ។

ពាក្យថា **មានឥតិហាសៈជាគម្រប់ ៥** គឺ ជាឥតិហាសៈ ដែលបានដល់ រឿងចាស់ៗ ដែលប្រកបដោយពាក្យដូច្នេះថា ជាយ៉ាងនេះ ដំណាលមកថា ដូច្នេះ ជាគម្រប់ ៥ នៃវេទ ដែលមានអាថព្វណវេទ ជាទីបួននោះដូច្នោះ ទើបឈ្មោះថា មានឥតិហាសៈជាគម្រប់ ៥ ។ មានឥតហាិសៈជាគម្រប់ ៥ នៃវេទទាំងនោះ ។ ឈ្មោះថា អ្នកយល់បទ ឆ្លាតក្នុងវេយ្យាករណ៍ ព្រោះកាន់យក ឬសម្ដែងបទ និងវេយ្យាករណ៍ដែលក្រៅអំពីបទនោះបានយ៉ាងជាក់ច្បាស់ ។ វិតណ្ឌវាទសាស្ត្រ ហៅថា លោកាយតៈ ។ ពាក្យថា **លក្ខណមហាបុរស** បានដល់ តម្រា (ក្បួនច្បាប់) ប្រមាណ ១២.០០០ ក្បាល ដែលសម្ដែងលក្ខណៈបុរសជាអ្នកធំក្រៃលែង មានព្រះពុទ្ធជាដើម មានបទគាថា ប្រមាណ ១៦,០០០ បទ ដែលមានឈ្មោះថា **ពុទ្ធមន្ត** ដែលជាហេតុឲ្យដឹងសេចក្ដីផ្សេងគ្នាយ៉ាងនេះ គឺ អ្នកប្រកបដោយលក្ខណៈនេះជាព្រះពុទ្ធ ជាព្រះបច្ចេកពុទ្ធ ដោយលក្ខណៈនេះ ជាព្រះអគ្គសាវកទាំងពីរ

ដោយលក្ខណៈនេះ ជាព្រះមហាសាវក ៨០ ដោយលក្ខណៈនេះ ជាព្រះ-ពុទ្ធមាតា ។ ជាព្រះពុទ្ធបិតា , ជាអគ្គឧបដ្ឋាក , ជាអគ្គឧបដ្ឋាយិកា , ជាស្តេចចក្រពត្តិ ដោយលក្ខណៈនេះ ។ ពាក្យថា **ជាអ្នកជំនាញ** បានដល់អ្នកធ្វើឲ្យបរិបូណ៌មិនខ្វះក្នុងគម្ពីរលោកាយតៈ និងតម្រា (ក្បួនច្បាប់) ទាយលក្ខណៈមហាបុរស អធិប្បាយថា បានដល់ ជាអ្នកមិនខ្វះខាត ។ អ្នកដែលមិនអាចទ្រទ្រង់ចាំទាំងសេចក្តី និងគម្ពីរបាន ឈ្មោះថា ជាអ្នកខ្វះខាត ។ ពាក្យដែលនឹងត្រូវពោលក្នុងបទជាដើមថា បានឮហើយ ក៏បានពោលស្រេចហើយក្នុងសាលេយ្យកសូត្រនោះឯង ។

ពាក្យថា **នែ៎ បា** គឺ ព្រហ្មាយុព្រាហ្មណ៍នេះ ព្រោះជាមនុស្សចាស់មិនអាចទៅបាន ទើបហៅមាណពមកពោលយ៉ាងនោះ ។ មួយ៉ាងទៀត ព្រាហ្មណ៍នេះគិតថា ក្នុងលោកនេះ អ្នកដែលកាន់យកឈ្មោះរបស់អ្នកដែលល្បីល្បាញថា យើងជាព្រះពុទ្ធ យើងជាព្រះពុទ្ធ មកពោលមានច្រើនណាស់ ព្រោះដូច្នោះ ត្រឹមតែបានឮមកប៉ុណ្ណោះ យើងទើបមិនទាន់គួរទៅរក និងកាលចូលទៅរក បុគ្គលខ្លះក៏មិនចៀសចេញទៅ ព្រោះជារឿងដែលធ្ងន់ចិត្ត (ប្រកបដោយប្រយោជន៍) និងរឿងមិនមានប្រយោជន៍ ព្រោះជាផ្លូវដែលល្អ យើង

គួរបញ្ជូនសិស្សយើង កាលដឹងថា ជាព្រះពុទ្ធ ឬមិនមែនព្រះពុទ្ធហើយ ចាំចូលទៅរក ព្រោះដូច្នោះ ទើបហៅមាណពមក ពោលពាក្យជាដើមថា នែ៎ បា ដូច្នេះ ។ បទថា **តំ ភគវន្តំ** បានដល់ អ្នកដ៏ចម្រើននោះ ។ ក៏ពាក្យថា **តថា សន្តំ យេវ** នេះ ជាទុតិយាវិភត្តិចុះក្នុងអត្ថថា ជាដូច្នេះ ។ ក្នុងពាក្យថា **លោកអាចារ្យធ្វើយ៉ាងណាដល់ខ្ញុំ** គឺ លោកអាចារ្យនឹងស្គាល់ព្រះគោតមនោះ បានយ៉ាងណា អធិប្បាយថា លោកអាចារ្យចូរប្រាប់ខ្ញុំ ដោយប្រការដែលខ្ញុំអាចស្គាល់ព្រះគោតមនោះ ។

ម្យ៉ាងទៀត បទថា **ដោយប្រការណា** នេះត្រឹមតែជាពាក្យដែលចុះជ្រៀតចូលមកជាកណ្តាលក៏បាន ។ ពាក្យថា **យ៉ាងណា** នេះជាពាក្យសួរអាការ សេចក្តីថា ខ្ញុំនឹងស្គាល់ព្រះគោតមដោយអាការយ៉ាងណា ។ បានឮថា កាលកូនសិស្សពោលយ៉ាងនោះ អាចារ្យពោលនឹងសិស្សជាដើមថា បា! ឯងឈរលើផែនដី ហើយមកនិយាយថា ខ្ញុំមើលមិនឃើញផែនដី ឈរក្រោមពន្លឺព្រះចន្ទ និងព្រះអាទិត្យហើយ ត្រឡប់ជាមកនិយាយថា ខ្ញុំមើលមិនឃើញព្រះចន្ទ និងព្រះអាទិត្យឬ កាលនឹងសម្តែងឲ្យល្អិតល្អន់នូវសេចក្តីដឹង ទើបពោលពាក្យជាដើមថា មកបា ។ ក្នុងពាក្យទាំងនោះ ពាក្យថា **មន្ត្**

សំដៅដល់វេទ ។ ពួកទេវតាជាន់សុទ្ធាវាសពួកខ្លះ លោកជ្រាបថា ន័យថា ព្រះតថាគតទ្រង់នឹងឧប្បត្តិ ទើបយកលក្ខណៈមកដាក់ទុកក្នុងវេទ ហើយក្លែងខ្លួនជាព្រាហ្មណ៍ មកបង្រៀនវេទថា ទាំងនេះ ឈ្មោះពុទ្ធមន្ត ពោលដោយទំនងនោះ ពួកសត្វទាំងឡាយអ្នកចេះនូវវេទ នឹងស្គាល់ព្រះតថាគតបាន ។ ព្រោះហេតុនោះ មហាបុរិសលក្ខណៈ ទើបមកក្នុងវេទតាំងពីក្នុងកាលមុន ។ តែកាលព្រះតថាគតបរិនិព្វានហើយ ក៏អន្តរធានទៅម្តងបន្តិចៗ ។ ដូច្នោះ ឥឡូវនេះទើបមិនមាន ។ ពាក្យថា **របស់មហាបុរស** គឺ របស់បុរសអ្នកជាំក្រៃលែង ដោយការតាំងព្រះទ័យ ការសមាទានសេចក្តីដឹង និងសេចក្តីអាណិតជាដើម ។ ពាក្យថា **គតិពីរប៉ុណ្ណោះ** គឺ ទីបំផុតពីរយ៉ាងនោះ ។ ក្នុងសេចក្តីដឹងទូទៅ គតិស័ព្ទ ប្រព្រឹត្តទៅក្នុងប្រភេទភព ក្នុងពាក្យជាដើមថា សារីបុត្រ ក៏គតិ ៥ យ៉ាងទាំងនេះឯង ។ ប្រព្រឹត្តទៅក្នុងទីជាទីនៅ ក្នុងពាក្យជាដើមថា ព្រៃធំជាគតិ (ទីនៅ) របស់ពួកម្រឹគ ។ ប្រព្រឹត្តទៅក្នុងបញ្ញា ក្នុងពាក្យជាដើមថា មានគតិ (បញ្ញា) មានប្រមាណក្រៃលែងយ៉ាងនេះ ។ ប្រព្រឹត្តទៅក្នុងសេចក្តីលះបង់ ក្នុងពាក្យជាដើមថា ដល់គតិ (សេចក្តីលះបង់) ។ តែក្នុងទីនេះ គប្បីជ្រាបថា ប្រព្រឹត្តទៅក្នុងការសម្រេច

(ឬទីបំផុត) ។ សូម្បីដូច្នោះ ក្នុងលក្ខណៈទាំងនោះ អ្នកប្រកបដោយលក្ខណៈពួកណា ជាព្រះរាជាក៏មិនមែន ជាព្រះពុទ្ធដោយលក្ខណៈទាំងនោះឡើយ ។ តែលោកហៅលក្ខណៈទាំងនោះ សេចក្តីស្មើគ្នាដោយជាតិប៉ុណ្ណោះ ។ ព្រោះហេតុនោះ ។ ព្រហ្មាយុព្រាហ្មណ៍ ទើបពោលថា អ្នកប្រកបដោយលក្ខណៈពួកណា ។

ពាក្យថា **បើនៅគ្រប់គ្រងផ្ទះ** គឺ បើនៅក្នុងផ្ទះ ។ ពាក្យថា **ជាស្តេចចក្រពត្តិ** សេចក្តីថា ព្រោះធ្វើឲ្យលោកត្រេកអរដោយវត្ថុអស្ចារ្យ ៤ យ៉ាង និងវត្ថុសម្រាប់សង្គ្រោះ ៤ យ៉ាង ទើបឈ្មោះថា ព្រះរាជា ។ ព្រោះមានចក្ករតន៍ វិលទៅដោយសម្បត្តិចក្រទាំង ៤ ឲ្យអ្នកដទៃវិលទៅដោយសម្បត្តិចក្រទាំង ៤ នោះផង និងព្រោះទ្រង់ប្រព្រឹត្តប្រយោជន៍ដល់អ្នកដទៃ និងប្រព្រឹត្តដើម្បីចក្រដែល បានដល់ ឥរិយាបថ ទើបឈ្មោះថា ចក្រពត្តិ ។ និងក្នុងទីនេះ ពាក្យថា **រាជា** ជាពាក្យទូទៅ ។ ពាក្យថា ចក្រពត្តិ ជាពាក្យវិសេសនៈ (គុណស័ព្ទពង្រីករាជា) ។ ព្រោះទ្រង់ប្រព្រឹត្តធម៌ ទើបឈ្មោះថា អ្នកប្រកបដោយធម៌ មានន័យថា ទ្រង់ប្រព្រឹត្តដោយការឈ្លាសវៃត្រឹមត្រូវ ។ ព្រោះទ្រង់បានទទួលរាជ្យដោយធម៌ហើយ ទើបជារាជា ទើបឈ្មោះ

ថា ធម្មរាជា ។ ម្យ៉ាងទៀត ព្រោះហេតុព្រះអង្គទ្រង់ជាអ្នកមានធម៌ជួយជាប្រយោជន៍សង្គ្រោះអ្នកដទៃ ទើបឈ្មោះថា ទ្រង់ប្រកបដោយធម៌ ព្រោះហេតុនៃធម៌ជួយជាប្រយោជន៍ដល់ព្រះអង្គ ទើបឈ្មោះថា ព្រះធម្មរាជា ។ ព្រោះជាធំក្នុងផែនដីដែលមានសមុទ្រទាំង ៤ ជាព្រំដែន ទើបឈ្មោះថា ចាតុរន្តោ អធិប្បាយថា ជាធំក្នុងផែនដីដែលប្រដាប់ដោយទ្វីបទាំងបួន ដែលមានសមុទ្រទាំង ៤ ទិសជាទីបំផុត ។ ព្រោះទ្រង់ឈ្នះសត្រូវ មានសេចក្ដីក្រោធជាដើមក្នុងខាងក្នុង និងព្រះរាជាទាំងអស់ក្នុងខាងក្រៅ ទើបឈ្មោះថា អ្នកឈ្នះពិសេស ។

ពាក្យថា ដល់សេចក្ដីរឹងមាំក្នុងជនបទ សេចក្ដីថា ដល់សេចក្ដីពិតប្រាកដ សេចក្ដីរឹងមាំក្នុងជនបទ មិនមានអ្នកណាធ្វើឲ្យកម្រើកបាន ម្យ៉ាងទៀត ឈ្មោះថា ទ្រង់ដល់សេចក្ដីរឹងមាំក្នុងជនបទ ព្រោះទ្រង់មានជនបទដែលដល់សេចក្ដីរឹងមាំ ទ្រង់មិនមានសេចក្ដីខ្វល់ខ្វាយ មិនត្រេកអរក្នុងការងាររបស់ព្រះអង្គ មិនញាប់ញ័រ មិនកម្រើកក្នុងជនបទនោះ ។ បទថា យ៉ាងណា នេះជាពាក្យសម្រាប់ជ្រៀតចូលមក ។ សេចក្ដីថា រតនៈទាំងនោះ របស់ស្ដេចចក្រពត្តិនោះ គឺ អ្វីខ្លះ ។ ក្នុងពាក្យថា ចក្ករតន៍ ជាដើម

ឈ្មោះថា ចក្ករតន៍ ព្រោះវត្ថុនោះជាចក្ក និងឈ្មោះថា ជារតនៈ ព្រោះអត្ថថា ញ៉ាំងសេចក្តីត្រេកអរឲ្យកើត ។ ក្នុងគ្រប់បទ ក៏ដូច្នេះទាំងអស់ ។ ក៏ក្នុងបណ្តារតនៈទាំងនេះ ស្តេចចក្រពត្តិ ទ្រង់ឈ្នះព្រំដែនដែលនៅមិនទាន់ឈ្នះដោយចក្ករតន៍ ។ ទ្រង់ត្រាច់ទៅតាមសប្បាយក្នុងព្រំដែន ដោយដំរីកែវ និងសេះកែវ ទ្រង់រក្សាព្រំដែនបានដោយបរិនាយកកែវ ។ ទ្រង់សោយឧបភោគជាសុខដោយរតនៈក្រៅពីនេះ ។ ការប្រកបដោយអំណាចនៃការមានឧស្សាហ៍នៃស្តេចចក្រពត្តិនោះ រមែងបរិបូណ៌ល្អដោយរតនៈទី ១ ការប្រកបដោយសក្តិនៃស្តេច រមែងបរិបូណ៌ដោយដំរីកែវ សេះកែវ និងគហបតីកែវ ការប្រកបដោយអំណាចនៃសេចក្តីឆ្លាត រមែងបរិបូណ៌ល្អដោយបរិនាយកកែវជាទីបំផុត ។ ស្តេចចក្រពត្តិនោះ ទ្រង់សោយសេចក្តីសុខក្នុងការប្រើប្រាស់ដោយស្ត្រីកែវ និងកែវមណី ។ ទ្រង់សោយឥស្សរិយសុខដោយរតនៈក្រៅពីនេះ ។ មយ៉ាងទៀត រតនៈ ៣ ខាងដើម របស់ស្តេចចក្រពត្តិនោះ រមែងសម្រេចដោយអានុភាពនៃកម្មដែលជាកុសលមូល គឺអទោសៈឲ្យកើតហើយ ដោយពិសេស ។ រតនៈកណ្តាលៗ រមែងសម្រេចដោយអានុភាពនៃកម្មដែលជាកុសលមូល គឺ អលោភៈឲ្យកើតហើយ ។

រតនៈបទតែមួយ គប្បីជ្រាបថា សម្រេចដោយអានុភាពនៃកម្មដែលជាកុស-លមូល គឺ អមោហៈ ឲ្យកើតហើយ ។ សេចក្តីសង្ខេបក្នុងរតនៈទាំងនេះប៉ុណ្ណេះ ។ ចំណែកសេចក្តីពិស្តារ គប្បីកាន់យកដោយឧបទេសនៃរតន-សូត្រ ក្នុងពោជ្ឈង្គសំយុត្ត ។

ម្យ៉ាងទៀត ការពណ៌នាព្រមទាំងលំដាប់នៃការកើតរបស់រតនៈទាំងនេះ នឹងមកក្នុងពាលបណ្ឌិតសូត្រ ។

[២] បទថា *បរោសហស្សំ* ប្រែថា ច្រើនជាងពាន់ ។ បទថា *សូរា* សេចក្តីថា អ្នកមានជាតិជាអ្នកក្លៀវក្លា ។ បទថា *វីរង្គរូបា* សេចក្តីថា មានកាយស្រដៀងទេវបុត្រ ។ អាចារ្យពួកមួយពណ៌នាទុកយ៉ាងនេះមុន ។ តែក្នុងរឿងនេះមានសភាវៈដូចតទៅនេះ ៖

បទថា *វីរា* លោកពោលថា មានសេចក្តីក្លាហានដ៏ប្រសើរបំផុត ។ គុណនៃអ្នកក្លាហាន ឈ្មោះថា *វីរង្គំ* លោកពោលអធិប្បាយថា ហេតុនៃអ្នកក្លៀវក្លា ឈ្មោះវីរិយៈ ។ ឈ្មោះថា *វីរង្គរូបា* ព្រោះអត្ថថា អ្នកមានរូបរាងអង់អាចក្លាហាន លោកអធិប្បាយថា មានរាងកាយដូចអ្នកក្លាហាន ។ បទថា *បរសេនប្បមទ្ទនា* អធិប្បាយថា បើកងទ័ពដទៃឈរប្រឈមមុខហើយ

ក៏អាចញ៉ាំញីកងទ័ពនោះបាន ។ បទថា ធម្មេន សេចក្តីថា ដោយធម៌ គឺសីលប្រាំ មានពាក្យថា មិនគួរសម្លាប់សត្វ ដូច្នេះជាដើម ។ ក្នុងពាក្យថា នឹងបានជាព្រះអរហន្តសម្មាសម្ពុទ្ធ បើកដំបូល (គឺកិលេស) ក្នុងលោកហើយនេះ ឈ្មោះថា មានដំបូលដែលបើកហើយ ព្រោះបើកដំបូលក្នុងលោកដែលងងឹតស្ងប់ដោយកិលេស ដែលត្រូវកិលេស គឺ រាគៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ អវិជ្ជា និងទុច្ចរិតដែលដូចជាដំបូលទាំង ៧ បិទហើយនោះ ធ្វើឲ្យកើតពន្លឺដោយជុំវិញតាំងនៅហើយ ។ ក្នុងបណ្តាបទប៉ុណ្ណោះ បណ្ឌិតគប្បីជ្រាបថា លោកពោលនូវភាពជាអ្នកគួរដល់ការបូជា ដោយបទដំបូង ពោលហេតុនៃភាពជាអ្នកគួរដល់ការបូជានោះ ដោយបទទី ២ ព្រោះទ្រង់ជាព្រះសម្មាសម្ពុទ្ធ ត្រាស់ដោយភាពជាអ្នកមានដំបូលបើកហើយ ដោយភាវៈនៃព្រះពុទ្ធ ដោយបទទី ៣ ។ ន័យម្យ៉ាងទៀត ឈ្មោះថា មានដំបូលដែលបើកហើយ ព្រោះអត្ថថា ទាំងបើកហើយ ទាំងមិនមានគ្រឿងប្រក់ លោកអធិប្បាយថា វៀរចាកវដ្តៈ និងវៀរចាកគ្រឿងប្រក់បាំង ។ ដោយពាក្យនោះ រមែងជាការពោលហេតុទាំង ២ នៃបទក្នុងខាងដើមទាំង ២ យ៉ាងនេះថា ឈ្មោះថា ជាព្រះអរហន្ត ព្រោះមិនមានវដ្តៈ ឈ្មោះថា ជាព្រះសម្មា-

សម្ពុទ្ធ ព្រោះមិនមានគ្រឿងប្រក់បាំង (ដំបូល) ។ ក៏ក្នុងសេចក្ដីនោះ សេចក្ដីសម្រេចផ្នែកខាងដើម រមែងមានដោយវេសារជ្ជញ្ញាណ ២ សេចក្ដីសម្រេចទី ២ រមែងមានដោយវេសារជ្ជញ្ញាណទី ១ សេចក្ដីសម្រេចទី ៣ រមែងមានដោយវេសារជ្ជញ្ញាណទី ៣ និងទី ៤ ។

គប្បីជ្រាបថា ប្រការទី ១ ឲ្យសម្រេចធម្មចក្ខុ , ប្រការទី ២ ឲ្យសម្រេចពុទ្ធចក្ខុ , ប្រការទី ៣ ឲ្យសម្រេចសមន្តចក្ខុ ដូច្នេះខ្លះ ។ ដោយពាក្យថា **តំ មន្ទានំ បដិគ្គហេតា** នេះ រមែងឲ្យកើត សេចក្ដីក្លៀវក្លាដល់មាណពនោះ ។

សូម្បីឧត្តរមាណពនោះ ប្រាសចាកសេចក្ដីងឿងឆ្ងល់ក្នុងលក្ខណៈទាំងឡាយតាមពាក្យរបស់អាចារ្យនោះ កាលត្រួតមើលក្នុងពុទ្ធមន្តហើយដូចជាកើតពន្លឺមួយ ទើបពោលថា យ៉ាងនោះឯង ដូច្នេះ ។ សេចក្ដីនៃពាក្យនោះ ដូចតទៅនេះ ៖

បពិត្រលោកអាចារ្យដ៏ចម្រើន ខ្ញុំនឹងធ្វើដូចលោកអាចារ្យប្រាប់ខ្ញុំ ។

**[៣]** បទថា **សមន្នេសិ** សេចក្ដីថា បានត្រួតមើលហើយ ម្យ៉ាងទៀតត្រួតមើលរាប់ថា ១,២ ដូច្នេះ ។ ពាក្យថា **អទ្ទសា ខោ** សួរថា បានឃើញ

យ៉ាងណា ។ ឆ្លើយថា ក៏នរណាៗ រមែងមិនអាចស្វែងរកលក្ខណៈនៃព្រះពុទ្ធ ដែលប្រថាប់គន់ ឬផ្ទុំបាន តែកាលទ្រង់ប្រថាប់ឈរ ឬទ្រង់ចង្រ្កមហើយ ទើបនឹងអាចដឹងបាន ។ ព្រោះដូច្នោះ ព្រះពុទ្ធទាំងឡាយ កាលឃើញអ្នក មកដើម្បីនឹងត្រួតមើលលក្ខណៈ ទើបទ្រង់ក្រោកពីអាសនៈ ប្រថាប់ឈរខ្លះ ទ្រង់អធិដ្ឋានចង្រ្កមខ្លះ ។ ឧត្តរមាណពបានឃើញហើយនូវលក្ខណៈរបស់ ព្រះអង្គ ដែះទ្រង់ញុំាងឥរិយាបថដ៏សមគួរ ដល់ការឃើញលក្ខណៈ ប្រព្រឹត្ត ទៅ ដោយប្រការដូច្នេះ ។

[៤] បទថា **យេភុយ្យេន** គឺ ដោយច្រើន មានសេចក្តីថា បាន ឃើញលក្ខណៈច្រើន មិនបានឃើញតិច ។ តពីនោះ មិនបានឃើញលក្ខណៈ យ៉ាងណា ទើបពោលថា **ឋបេត្វា ទ្វេ** វៀរ ២ លក្ខណៈ ដើម្បីសម្តែងដល់ លក្ខណៈ ២ ប៉ុណ្ណោះ ។ បទថា **កង្ខតិ** សេចក្តីថា ឧត្តរមាណពកើតសេចក្តី ប្រាថ្នាឡើងថា គួរអស្ចារ្យហ្ន៎ យើងគប្បីបានឃើញ (លក្ខណៈ ២ ប្រការ ទៀត) ។ បទថា **វិចិកិច្ឆតិ** សេចក្តីថា កាលជ្រើសរើសនូវលក្ខណៈទាំង នោះ អំពីលក្ខណៈនោះៗ រមែងលំបាក គឺ មិនអាចដើម្បីនឹងឃើញបាន ។ បទថា **នាធិមុច្ចតិ** សេចក្តីថា រមែងមិនដល់ការដាច់ស្រេច ព្រោះសេចក្តី

សង្ស័យយ៉ាងនោះ ។

បទថា **ន សម្បសីទតិ** សេចក្តីថា តពីនោះ ទើបមិនកើតសេចក្តីជ្រះថ្លាក្នុងព្រះមានព្រះភាគថា ព្រះអង្គមានព្រះលក្ខណៈសម្បូរណ៍ ។

ម្យ៉ាងទៀត ឧត្តរមាណពពោលនូវសេចក្តីសង្ស័យមានកម្លាំងខ្សោយ សេចក្តីសង្ស័យយ៉ាងកណ្តាល និងសេចក្តីសង្ស័យយ៉ាងខ្លាំង ព្រោះការមិនបង្អោនចិត្តជឿ ។ ព្រោះមិនទាន់មានសេចក្តីជ្រះថ្លា ទើបមានចិត្តស្ទាក់ស្ទើរ ដោយហេតុបីយ៉ាងទាំងនោះ ។ បទថា **កោសោហិតេ** បានដល់ ស្រោមថ្ងាស់បិទបាំងហើយ ។ បទថា **វត្ថគុយ្ហេ** បានដល់ អង្គជាតិ ។ ពិតហើយ គុយ្ហឋានដែលនៅក្នុងស្រោមរបស់ព្រះមានព្រះភាគ ស្មើដោយបទុមបទុមមានពណ៌ដូចមាស ដូចគុយ្ហឋានរបស់ដំរី ។ ឧត្តរមាណពនោះ កាលមិនឃើញព្រះគុយ្ហឋាននោះ ព្រោះសំពត់បិទទុក និងព្រះជិវ្ហានៅក្នុងព្រះទន្ត ទើបមិនបានកំណត់ ក៏មានសេចក្តីសង្ស័យ ងឿងឆ្ងល់ក្នុងព្រះលក្ខណៈ ២ នោះ ។ ពាក្យថា **គ្រានោះឯង ព្រះមានព្រះភាគ** សេចក្តីថា គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ទើបត្រិះរិះថា បើតថាគតមិនសម្តែងលក្ខណៈទាំង ២ នេះ ដល់ឧត្តរមាណពនេះ មាណពនេះក៏នឹងមិនអស់សេចក្តីសង្ស័យ កាល

គេនៅមានសេចក្ដីសង្ស័យហើយ សូម្បីអាចារ្យរបស់គេ ក៏នឹងមិនអស់ការសង្ស័យ ហេតុនោះគេនឹងមិនមករកតថាគត កាលមិនមក ក៏នឹងមិនបានស្ដាប់ធម៌ កាលមិនបានស្ដាប់ធម៌ ក៏នឹងមិនបានធ្វើឲ្យច្បាស់នូវសាមញ្ញផល ៣ តែកាលមាណពនោះអស់សេចក្ដីសង្ស័យហើយ ទាំងអាចារ្យរបស់គេ ក៏អស់សេចក្ដីសង្ស័យនឹងចូលមករកតថាគត ហើយស្ដាប់ធម៌ ក៏នឹងធ្វើឲ្យជាក់ច្បាស់នូវផល ៣ បាន ម្យ៉ាងទៀត តថាគតបំពេញបារមីមកក៏ដើម្បីប្រយោជន៍យ៉ាងនេះ តថាគតនឹងសម្ដែងលក្ខណៈទាំងនោះ ដល់ឧត្តរមាណពនោះ ដូច្នេះ ។ ព្រះដ៏មានព្រះភាគ ទើបទ្រង់បណ្ដាលឥទ្ធាភិសង្ខារមានសភាពបែបនោះ ។

ទ្រង់បណ្ដាលមានរូបយ៉ាងណា ក្នុងរឿងនេះ មានពាក្យដែលបុគ្គលដទៃគប្បីពោលបានយ៉ាងណា ។ ពាក្យនោះព្រះនាគសេនត្ថេរ ដែលព្រះបាទក្រុងមិលិន្ទសួរហើយ វិសជ្ជនាទុកហើយ ។

ព្រះរាជា- ព្រះនាគសេនដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ធ្វើនូវវត្ថុដែលធ្វើបានលំបាក ។

ព្រះនាគសេន- ទ្រង់ធ្វើអ្វី មហាបពិត្រ ។

ព្រះរាជា- លោកម្ចាស់ ព្រះអង្គទ្រង់សម្តែងឱកាសដែលធ្វើឲ្យបុគ្គលជាច្រើនអៀនខ្មាសដល់នាយឧត្តរៈសិស្សព្រហ្មាយុព្រាហ្មណ៍ ដល់ពួកព្រាហ្មណ៍ ១៦ នាក់ សិស្សរបស់ពាវរី និងដល់មាណព ៣០០ នាក់ សិស្សរបស់សេលព្រាហ្មណ៍ទៀត ។

ព្រះនាគសេន- មហាបពិត្រ ព្រះដ៏មានព្រះភាគ ទ្រង់មិនបានសម្តែងព្រះអង្គជាតិទេ ទ្រង់សម្តែងតែស្រមោល គឺ ព្រះអង្គទ្រង់សាងឡើងដោយព្រះឫទ្ធិ ហើយទ្រង់សម្តែងត្រឹមតែរូបជាស្រមោល ដែលនៅក្នុងសំពត់រឹតខ្សែវត្ថពន្ធបង្អែះទុក ហើយឃ្លុំចីវរ ។

ព្រះរាជា- កាលឃើញស្រមោល ក៏ឈ្មោះថា ឃើញព្រះអង្គជាតិមិនមែនឬ លោកម្ចាស់ ។

ព្រះនាគសេន- ប្រការនោះ លើកទុកសិនចុះ មហាបពិត្រ មនុស្សយើងត្រូវមើលបេះដូងឲ្យឃើញហើយ ទើបនឹងត្រាស់ដឹងបាន ព្រះសម្មាសម្ពុទ្ធក៏នឹងត្រូវយកសាច់បេះដូងចេញមកសម្តែងផង ដូច្នោះឬ ។

ព្រះរាជា- ព្រះនាគសេនដ៏ចម្រើន ឆ្លាតមែន ។

បទថា **និន្នាមេត្វា** បានដល់ ទ្រង់លៀន (ព្រះជិវ្ហា) ចេញ ។ បទថា

ទ្រង់ស៊ក បានដល់ ទ្រង់ស៊កចូល ធ្វើដូចស៊កម្ជុលដេរសំពត់កឋិន ដូច្នោះ ។ ក៏ក្នុងសេចក្តីនោះ គប្បីជ្រាបថា បង្ហាញសភាពទន់ដោយការធ្វើយ៉ាងនោះ បង្ហាញសភាពវែង ដោយការស៊កចូលប្រហោងព្រះកាណ៌ បង្ហាញសភាពតូច ដោយការស៊កចូលប្រហោងព្រះនាសិក បង្ហាញសភាពធំ ដោយការបិទព្រះនលាដ ។ មយ៉ាងទៀត ក្នុងពាក្យថា ប្រហោងព្រះកាណ៌ទាំងពីរជាដើម គប្បីជ្រាបវិនិច្ឆ័យថា មន្ទិលក្តី ក្រមរក្តី ក្នុងប្រហោងព្រះកាណ៌របស់ព្រះពុទ្ធទាំងឡាយមិនមាន រមែងដូចជាបំពង់ប្រាក់ ដែលគេលាងហើយទុកដាក់ ។ ក្នុងប្រហោងព្រះនាសិកក៏ដូចគ្នា ។ សូម្បីប្រហោងទាំងនោះ រមែងដូចជាបំពង់មាស ដែលគេធ្វើការត្រៀមទុកយ៉ាងល្អ និងដូចគ្នានឹងបំពង់កែវមណី ដូច្នោះ ។ ព្រោះដូច្នោះ ទើបទ្រង់លៀនព្រះជិវ្ហាចេញ ចូលទៅក្នុងទីបំផុតព្រះឱស្ឋ ទៅខាងលើធ្វើដូចម្ជុលដេរសំពត់កឋិន ស៊កចូលកាន់ប្រហោងព្រះកាណ៌ខាងស្តាំ នាំចេញពីប្រហោងស្តាំនោះ ស៊កចូលក្នុងប្រហោងព្រះកាណ៌ឆ្វេង ។ នាំចេញពីប្រហោងព្រះកាណ៌ឆ្វេង ស៊កចូលប្រហោងព្រះនាសិកស្តាំ នាំចេញពីប្រហោងព្រះនាសិកស្តាំ ស៊កចូលក្នុងប្រហោងព្រះនាសិកឆ្វេងបាន ។ គ្រានាំចេញចាកប្រហោងព្រះនាសិកឆ្វេង

ហើយ កាលនឹងសម្តែងសភាពធំ ទើបបិទមណ្ឌលព្រះនលាដ រហូតអស់ទាំងអស់ដោយព្រះជិវ្ហា ដូចជាផ្តេកបន្ទោរ ដែលរុងរឿងដោយផ្ទាំងសំពត់កម្ពលក្រហម ដូចព្រះចន្ទពាក់កណ្តាលវង់ ត្រូវពពកវលាហកៈពណ៌ក្រហមបិទទុកពាក់កណ្តាល និងដូចផែនមាស ដូច្នោះ ។

**[៥]** បទថា **យន្នូនាហំ** សួរថា ហេតុអ្វី ឧត្តរមាណពទើបគិត ។ ឆ្លើយថា ឧត្តរមាណពគិតថា ក៏យើងពិនិត្យមើលមហាបុរិសលក្ខណៈហើយត្រឡប់ទៅ បើអាចារ្យសួរថា បាឧត្តរៈ អ្នកបានឃើញមហាបុរិសលក្ខណៈហើយឬ ក៏នឹងអាចប្រាប់បានថា ករុណាលោកអាចារ្យ តែបើអាចារ្យនឹងសួរយើងថា ព្រះមានព្រះភាគទ្រង់ធ្វើកិរិយាយ៉ាងណា យើងក៏មិនអាចតបពាក្យសួរនោះបាន តែកាលយើងឆ្លើយថា មិនដឹង អាចារ្យក៏ក្រោធថា យើងបញ្ជូនអ្នកទៅ ដើម្បីពិនិត្យមើលឲ្យដឹងលក្ខណៈទាំងអស់នេះ មិនមែនឬ ហេតុអ្វីមិនដឹង ហើយទើបត្រឡប់មក ដូច្នោះ ទើបគិតថា ធ្វើដូចម្តេចហ្ន៎ ? ហើយត្រាច់តាមទៅ ។

ព្រះមានព្រះភាគ ទ្រង់ធ្វើឱកាសក្នុងទីដ៏សេសទាំងឡាយ វៀរឋានៈ ៤ ទាំងនេះ គឺ កន្លែងស្រង់ទឹក កន្លែងជម្រះព្រះឱស្ឋ កន្លែងបដិបត្តិចំពោះ

ព្រះសរីរៈ ព្រមទាំងការហែហមដោយព្រះរាជា និងមហាមាត្ររបស់ព្រះ-រាជាជាដើម ដោយហោចទៅ សូម្បីក្នុងព្រះគន្ធកុដិកន្លែងមួយ ។

កាលកន្លងទៅៗ ក៏ប្រាកដថា បានឮថា មាណពរបស់ព្រហ្មាយុ-ព្រាហ្មណ៍ឈ្មោះឧត្តរៈនោះ ត្រាច់សង្កេតមើលភាពជាព្រះពុទ្ធ របស់ព្រះ-តថាគតថា ជាព្រះពុទ្ធ ឬមិនមែនជាព្រះពុទ្ធ ឧត្តរមាណពនេះ ឈ្មោះថាជាអ្នកសាកសួរព្រះពុទ្ធ ។ ព្រះពុទ្ធទាំងឡាយ ទ្រង់ប្រថាប់នៅក្នុងទីណាៗទ្រង់រមែងញុំាងកិច្ច ៥ ប្រការតែម្យ៉ាង កិច្ចទាំងនោះ បានសម្ដែងទុកហើយក្នុងខាងក្រោយនោះឯង ។

ក្នុងបណ្ដាកិច្ចទាំងនោះ ក្នុងវេលាបច្ឆាភត្ត កាលព្រះដ៏មានព្រះភាគប្រថាប់គង់លើធម្មាសនៈ ដែលគេតាក់តែងហើយ ទ្រង់ចាប់ផ្លិតដ៏វិចិត្រដែលរចនាដោយភ្លុក សម្ដែងធម៌ដល់មហាជន សូម្បីឧត្តរមាណពក៏អង្គុយនៅក្នុងទីមិនឆ្ងាយ ។ ក្នុងទីបំផុតនៃការស្ដាប់ធម៌ ពួកអ្នកមានសទ្ធា ក៏និមន្តព្រះមានព្រះភាគដើម្បីសោយព្រះក្រយាហារ ដែលនឹងមានក្នុងថ្ងៃស្អែកនេះក៏ចូលទៅរកមាណព ដោយពោលយ៉ាងនេះថា បា! ពួកយើងនិមន្តព្រះ-មានព្រះភាគហើយ លោកក៏ចូរមកទទួលភត្តក្នុងផ្ទះរបស់ពួកយើង ព្រមជា

មួយនឹងព្រះមានព្រះភាគ ។ ក្នុងថ្ងៃស្អែក ព្រះតថាគតដែលភិក្ខុសង្ឃហែ-ហមហើយ ស្ដេចចូលទៅកាន់ស្រុក ។ សុម្បីឧត្តរមាណព ក៏ជាប់តាមទៅគ្រប់ៗ ជំហាន ។ ក្នុងវេលាដែលទ្រង់ចូលទៅកាន់ផ្ទះនៃត្រកូល មាណពអង្គុយសង្កេតមើលគ្រប់ប្រការ តាំងពីការកាន់យកទឹកដើម្បីទក្ខិណាជាដើមទៅ ។ ក្នុងវេលាសម្រេចភត្តកិច្ច ក្នុងវេលាព្រះតថាគតប្រថាប់គង់ ដាក់បាត្រទុកលើជើងបាត្រ ពួកមនុស្សក៏ចាត់ចែងអាហារព្រឹកដល់មាណព ។ មាណពនោះអង្គុយបរិភោគក្នុងចំណែកទីបំផុតម្ខាង ហើយត្រឡប់មកឈរក្នុងទីជិតព្រះសាស្ដា ស្ដាប់ភត្តានុមោទនា ត្រឡប់ទៅកាន់វិហារព្រមជាមួយនឹងព្រះមានព្រះភាគតែម្ដង ។ ព្រះមានព្រះភាគទ្រង់រង់ចាំឲ្យភិក្ខុទាំងឡាយសម្រេចភត្តកិច្ច ប្រថាប់គង់ក្នុងសាលាគន្ធមណ្ឌលនោះ ។ កាលភិក្ខុទាំងឡាយធ្វើភត្តកិច្ចស្រេច នាំគ្នារក្សាបាត្រ និងចីវរ មកថ្វាយបង្គំក្រាបទូលកាល ព្រះមានព្រះភាគទើបស្ដេចចូលព្រះគន្ធកុដិ ។ សុម្បីមាណពក៏ចូលទៅជាមួយនឹងព្រះមានព្រះភាគ ។ ព្រះមានព្រះភាគប្រថាប់ឈរត្រង់មុខព្រះគន្ធកុដិ ទ្រង់ប្រៀនប្រដៅពួកភិក្ខុដែលមកហែហមហើយ ក៏បែកគ្នាទៅទើបស្ដេចចូលកាន់ព្រះគន្ធកុដិ ។ មាណពក៏ចូលទៅផង ។ ព្រះមានព្រះភាគ

ទើបប្រថាប់គង់លើគ្រែតូចមួយក្លែត ។ សុម្បីមាណព ក៏អង្គុយសង្កេតមើលនៅក្នុងទីមិនឆ្ងាយ ។ ព្រះមានព្រះភាគប្រថាប់គង់មួយក្លែត ទ្រង់ទើបសម្តែងការឱនព្រះសិរសា ។ មាណពគិតថា នឹងជាវេលាប្រថាប់សម្រាករបស់ព្រះគោតមដ៏ចម្រើន ហើយបិទទ្វារព្រះគន្ធកុដិ ចេញទៅអង្គុយក្នុងចំណែកទីបំផុតម្ខាង ។ ពួកអ្នកថ្វាយទានក្នុងកាលមុននៃភត្ត បរិភោគអាហារព្រឹកហើយ សមាទានអង្គឧបោសថដណ្តប់សំពត់ស្អាត កាន់ផ្កាឈើ និងគ្រឿងក្រអូបជាដើមមកកាន់វិហារ ដោយគិតថា នឹងស្តាប់ធម៌ ដូចគ្នានឹងមកកាន់បន្ទាយរបស់ស្តេចចក្រពត្តិ ដូច្នោះ ។

ព្រះមានព្រះភាគ ទ្រង់សម្រេចសីហសេយ្យាសនៈមួយក្លែត ទ្រង់ក្រោកឡើង ទ្រង់កំណត់ដោយចំណែកខាងដើម ចូលសមាបត្តិ ។ គ្រាចេញចាកសមាបត្តិហើយ ជ្រាបថា មហាជននាំគ្នាមក ទើបទ្រង់ចេញចាកព្រះ-គន្ធកុដិ ដែលមហាជនចោមរោមហើយ ស្តេចទៅកាន់សាលាគន្ធមណ្ឌលប្រថាប់លើពុទ្ធាសនៈដ៏ប្រសើរដែលគេក្រាលទុកហើយ ទ្រង់សម្តែងធម៌ដល់បរិស័ទ។ ចំណែកមាណពអង្គុយនៅក្នុងទីមិនឆ្ងាយ កំណត់អក្ខរៈនិងអក្ខរៈបទនិងបទ ដោយគិតថា ព្រះសមណគោតមសម្តែងធម៌ លើកតម្កើង ឬរុក

កួនដល់បរិស័ទដោយអំណាចអាស្រ័យផ្ទះឬ ឬថា ទ្រង់មិនសម្ដែងយ៉ាង នោះ ៗ ព្រះមានព្រះភាគ មិនត្រាស់កថាយ៉ាងនោះឡើយ ទ្រង់ជ្រាបកាល ទ្រង់បញ្ឈប់ទេសនា ៗ មាណពកំណត់ហើយ ដោយទំនងនេះ ត្រាច់ទៅ តែម្នាក់ឯងរហូតអស់ ៧ ខែ មិនបានឃើញកំហុសសូម្បីមានប្រមាណតិច ក្នុងកាយទ្វារជាដើម របស់ព្រះមានព្រះភាគ ៗ ក៏ប្រការនេះមិនគួរអស្ចារ្យ ដែលឧត្តរមាណពជាមនុស្សមិនបានឃើញកំហុសរបស់ព្រះពុទ្ធ ៗ កាល ព្រះអង្គនៅជាព្រះពោធិសត្វ ទេវបុត្រមារ ជាអមនុស្ស ក៏មិនបានឃើញ សូម្បត្រឹមតែការត្រិះរិះ (វិតក្កៈ) អាស្រ័យផ្ទះ ក្នុងស្ថានដែលទ្រង់បំពេញ សេចក្ដីព្យាយាមដល់ ៦ ឆ្នាំ និងជាប់តាមព្រះអង្គដែលជាព្រះពុទ្ធហើយ អស់មួយឆ្នាំ ក៏មិនបានឃើញកំហុសណាៗ ទើបពោលគាថា មានជាដើមថា

យើងជាប់តាមស្នាមព្រះបាទព្រះមានព្រះភាគ ដល់ ៧ ឆ្នាំ
ក៏មិនបានប្រសព្វកំហុសរបស់ព្រះសម្ពុទ្ធអ្នកមានសតិ ដូច្នេះ
ហើយចៀសទៅ ៗ

អំពីនោះ មាណពទើបគិតថា យើងជាប់តាមព្រះគោតមដ៏ចម្រើន ដល់ ៧ ខែ ក៏មិនបានឃើញទោសណាៗ តែបើយើងនឹងគប្បីជាប់តាមទៅ

សូម្បីត្រឹមតែ ៧ ខែ ឬ៧ ឆ្នាំ ឬ ១០០ ឆ្នាំ ឬ ១,០០០ ឆ្នាំ ទៀត ក៏គង់នឹងមិនបានឃើញទោសរបស់ព្រះអង្គ ក៏ប៉ុន្តែថា អាចារ្យរបស់យើងនោះក៏ចាស់ទ្រុឌទ្រោម គង់នឹងមិនអាចជ្រាបសេចក្តីក្សេមចាកយោគៈ យើងនឹងប្រាប់ថា ព្រះសមណគោតមជាព្រះពុទ្ធ ដោយព្រះគុណតាមសេចក្តីពិតតែម្តងចុះដល់អាចារ្យរបស់យើង ដូច្នេះ ហើយទូលលាព្រះមានព្រះភាគ ថ្វាយបង្គំភិក្ខុសង្ឃរួចចេញទៅ ។

ឯឧត្តរមាណពត្រឡប់ទៅកាន់សម្នាក់របស់អាចារ្យហើយ ត្រូវអាចារ្យសួរថា បា!ឧត្តរៈ កិត្តិស័ព្ទរបស់ព្រះគោតមដ៏ចម្រើនដែលល្បីល្បាញទៅមានដូច្នោះពិតឬ ទើបពោលថា បពិត្រលោកអាចារ្យ លោកនិយាយអ្វីចក្រវាឡក៏ចង្អៀត ភវគ្គព្រហ្មក៏នៅទាប ប្រជុំនៃគុណរបស់ព្រះគោតមដ៏ចម្រើននោះ រកទីបំផុតមិនបាន ដូចជាអាកាស បពិត្រលោកអាចារ្យដ៏ចម្រើន កិត្តិស័ព្ទរបស់ព្រះគោតមដ៏ចម្រើននោះ មានហើយ ដូច្នោះពិតមែន ដូច្នេះជាដើម ទើបប្រាប់មហាបុរិសលក្ខណៈ ៣២ ប្រការ តាមដែលខ្លួនឃើញហើយដោយលំដាប់ ប្រាប់ដល់កិរិយសមាចារ ។ ព្រោះដូច្នោះព្រះសង្គីតិកាចារ្យ ទើបពោលថា គ្រានោះឯង ឧត្តរមាណព ។ល។ ព្រះ-

គោតមដ៏ចម្រើនជាដូច្នេះផង ជាដូច្នេះផង និងក្រៃលែងជាងនោះ ដូច្នេះ ។

[៦] ក្នុងបណ្ដាបទទាំងនោះ បទថា **សុបតិដ្ឋិតបាទោ** សេចក្ដីថា ដូចជាបុគ្គលទាំងឡាយពួកដទៃ ដាក់ជើងលើផែនដី ចុងជើងក្ដី កែងជើងក្ដី ផ្នែកខាងក្ដី និងត្រូវផែនដីមុន ឬថា កណ្ដាលជើង កាលលើកឡើងចំណែកមួយត្រង់ចុងជើងជាដើម ក៏លើកឡើងមុន តែព្រះបាទរបស់ព្រះអង្គមិនបាន ដូច្នោះ ។ បាតព្រះបាទទាំងអស់របស់ព្រះអង្គ និងត្រូវផែនដីព្រមគ្នាតែម្ដង ដូចផ្ទៃស្បែកជើងមាស ដូច្នោះ លើកអំពីផែនដីក៏ព្រមគ្នា ព្រោះដូច្នោះ លោកទើបពោលថា ព្រះគោតមដ៏ចម្រើនព្រះអង្គនោះ មានព្រះបាទប្រតិស្ឋានទៅលើផែនដីស៊ប់ល្អ ។ ក្នុងកន្លែងដែលព្រះមានព្រះភាគមានព្រះបាទប្រតិស្ឋានស៊ប់ល្អនោះ មានសេចក្ដីដែលគួរអស្ចារ្យដូចតទៅនេះ ៖

ប្រសិនបើ ព្រះមានព្រះភាគទ្រង់ឈានព្រះបាទ ដោយតាំងព្រះទ័យថា តថាគតនឹងជាន់ជ្រោះជ្រៅសូម្បីច្រើនរយជួរបុរស ក្នុងខណៈនោះ ទីដែលកន្ទុកក៏នឹងពេញឡើងមកស្មើផែនដី ដូចជាគ្រឿងសប់របស់ជាងមាសពេញដោយខ្យល់ ដូច្នោះ ។

សូម្បីទឹកទួលក៏លិចទៅខាងក្រោម កាលទ្រង់ឈានព្រះបាទដោយតាំងព្រះទ័យថា តថាគតនឹងជាន់ក្នុងទីឆ្ងាយ ភ្នំសូម្បីមានប្រមាណប៉ុនសិនេរុ-បព៌ត ក៏បង្អោនមកជិតព្រះបាទ ដូចបំពង់ផ្កាដែលដោកដោយទឹកហើយដូច្នោះ ។ ពិតយ៉ាងនោះ កាលព្រះអង្គទ្រង់ធ្វើយមកបាដិហារ្យ ទ្រង់ឈានព្រះបាទដោយតាំងព្រះទ័យថា នឹងជាន់ភ្នំយុគន្ធរ ភ្នំក៏បង្អោនមកជិតព្រះបាទ ។ ព្រះអង្គទ្រង់ជាន់ភ្នំនោះ ទ្រង់ឈានព្រះបាទជាន់កពតាវត្តឹង្ស ដោយព្រះបាទទីពីរ ។ ព្រះចក្រលក្ខណៈនឹងគប្បីប្រតិស្ឋានមិនស្មើគ្នា រមែងមិនមាន ។ ជន្លត់ក្តី បន្ទាក្តី ដុំគ្រួសក្តី ក្បឿងក្តី ឧច្ចារៈបស្សាវៈក្តី ទឹកមាត់ ទឹកសម្បោរជាដើមក្តី ដែលមាននៅមុនស្តេចយាង ក៏បាត់ទៅ ឬលិចចូលផែនដីក្នុងទីនោះៗ ។ ពិតណាស់ ដោយតេជៈនៃសីល បញ្ញា ធម៌ អានុភាពនៃបារមី ១០ ប្រការ របស់ព្រះតថាគត មហាប្រថពីនេះ រមែងស្មើ ទន់ ពោរពេញដោយបុប្ផជាតិ ។ ព្រះតថាគតទ្រង់ដាក់ព្រះបាទស្មើ (និង) ទ្រង់លើកព្រះបាទក៏ស្មើគ្នា ទ្រង់សម្ផស្សផែនដីដោយផ្ទៃព្រះបាតគ្រប់ចំណែក ។ បទថា ចក្កានិ បានដល់ ព្រះបាទទាំង ២ ដែលមានចក្រត្រង់ព្រះបាតទាំងពីរ ។ លោកពោលទុកក្នុងព្រះបាលីថា ចក្រនោះមានកាំ ខ្នងកង់ និងដុំ ។ ក៏បទថា

បរិបូណ៌ដោយអាការទាំងពួងនេះ គប្បីជ្រាបសេចក្ដីផ្សេងគ្នា ដូចតទៅនេះ បានឮថា ចក្រទាំងនោះ រមែងប្រាកដជុំត្រង់កណ្ដាលនៃផ្ទៃព្រះបាត ។ ប្រាកដស្នាមគំនូសជារង្វង់មូលជុំវិញដុំ ។ ត្រង់មាត់ដុំ ក៏ប្រាកដវង់មូលព័ទ្ធជុំវិញ ។ ប្រាកដជាប្រហោងមាត់ ។ ប្រាកដជាកាំ ។ ប្រាកដជាក្បាច់មូលត្រង់កាំទាំងឡាយ ។ ប្រាកដជាកង់ ។ ប្រាកដជាកង់កែវ ។ នេះមកតាមព្រះបាលីមុននោះឯង ។

តែវារៈចំណែកច្រើនមិនបានមកហើយ ។ ក៏វារៈនោះ គប្បីជ្រាបដូច្នេះ ។

រូបលំពែង ១ រូបគោ ១ កញ្ចក់ ១ រូបស័ង្ខទក្ខិណាវដ្ដ ១ រូបមក្កុដផ្កា ១ រូបឈ្នួត ១ រូបត្រីទាំងគូ ១ រូបកៅអី ១ រូបប្រាសាទ ១ រូបផ្ចិតស្លឹកត្នោត ១ រូបផ្ចិតស្លាបក្ងោក ១ រូបផ្ចិតកន្ទុយសត្វ ១ រូបស្វេតឆត្រ ១ រូបព្រះខ័ន ១ រូបមក្កុដ ១ រូបបាត្រ ១ រូបកែវមណី ១ រូបកម្រងផ្កាឈើ ១ រូបឧប្បលខៀវ ១ រូបឧប្បលស ១ រូបឧប្បលក្រហម ១ រូបផ្កាឈូក ១ រូបផ្កាឈូកស ១ រូបឆ្នាំងពេញដោយទឹក ១ រូបថាសពេញដោយទឹក ១ រូបសមុទ្រ ១ រូបចក្រវាឡ ១ រូបព្រៃហិមពាន្ត

១ រូបក្អមសិនេរុ ១ រូបព្រះចន្ទ ១ រូបព្រះអាទិត្យ ១ រូបពួកផ្កាយ ១ រូបទ្វីបធំទាំងបួន ទ្វីបតូច ២ ពាន់ ១ ។ ដោយទីបំផុត បរិវារនៃចក្រលក្ខណៈទាំងអស់ សំដៅយកបរិស័ទរបស់ស្តេចចក្រពត្តិ ។ បទថា **អាយតបណ្ហិ** គឺ ព្រះកែងវែង មានសេចក្តីថា មានព្រះកែងបរិបូណ៌ ។ ដូចជាចុងជើងរបស់មនុស្សដទៃវែង តាំងនៅក្នុងទីបំផុតកែងជើងកែង ស្នងជើងរមែងប្រាកដដូចតាំងទុក តែរបស់ព្រះតថាគតមិនដូច្នោះ ។ ឯរបស់ព្រះតថាគត ក្នុង ៤ ចំណែក ខាងចុងជើង ២ ចំណែក ។ ស្នងតាំងនៅក្នុងចំណែកទីបី ។ ក្នុងចំណែកទី ៤ កែងជើងដូចកូនមូលធ្វើ ដោយសំពត់កម្ពលក្រហម ដូចវិលជាប់នៅលើចុងដែកស្រួច ដូច្នោះ ។ បទថា **មានព្រះអង្គុលីវែង** សេចក្តីថា ដូចជាមនុស្សដទៃ មនុស្សខ្លះមានម្រាមវែង មនុស្សខ្លះមានម្រាមខ្លី ចំណែកម្រាមរបស់ព្រះតថាគត មិនដូច្នោះ ។ ចំណែកម្រាមរបស់ព្រះតថាគត ម្រាមព្រះហស្ត និងម្រាមព្រះបាទវែង គល់ធំ រៀវតូចឡើងទៅដោយលំដាប់ដរាបដល់ចុង ដូចម្រាមពានរ ដូចទៀនដែលមូលនាំទៅលុញនឹងប្រេង ។ ព្រោះដូច្នោះ លោកទើបពោលទុកថា ព្រះអង្គុលីវែង ។ បទថា **ទ្រង់មានបាតព្រះហស្ត និងបាតព្រះបាទទន់ល្មៃ** បានដល់

ឈ្មោះថា មានបាតព្រះហស្ត និងបាតព្រះបាទទន់ល្មៃ ព្រោះអត្ថថា ទន់ដូចសំឡីគ ដែលគេថ្លៃចដល់ ១០០ ដង ជ្រលក់ដោយទឹកដោះថ្លាទុក និងមានព្រះហស្ត និងព្រះបាទទន់ល្មៃជានិច្ច ដូចដៃជើងរបស់ទារកកើតក្នុងថ្ងៃដំបូង ។ បទថា **ទ្រង់មានបាតព្រះហស្ត និងបាតព្រះបាទដូចជាក្រឡាសំណាញ់** បានដល់ ចន្លោះម្រាមមិនជាប់នឹងស្បែក ។ ក៏បុគ្គលមានដៃដូចពពារពស់ ដោយទោសនៃបុរស រមែងមិនបានសូម្បីការបព្វជ្ជា ។ តែម្រាមរបស់ព្រះតថាគត ម្រាមព្រះហស្តទាំង ៤ ម្រាមព្រះបាទទាំង ៥ មានសណ្ឋានតែម្យ៉ាង ។ ព្រោះម្រាមទាំងនោះ មានសណ្ឋានតែមួយដូចគ្នា លក្ខណៈជាចន្លោះគ្នានិងគ្នាតាំងនៅ ។ ក៏ព្រះហស្ត និងព្រះបាទរបស់ព្រះតថាគតនោះ ដូចជាក្រឡាសំណាញ់នៃបន្ទះទ្វារបង្អួចដែលជាងឈើអ្នកឆ្លាតប្រកបទុក ។ ព្រោះដូច្នោះ លោកទើបពោលថា មានបាតព្រះហស្ត និងបាតព្រះបាទជាក្រឡាសំណាញ់ ។ ឈ្មោះថា **ទ្រង់មានព្រះបាទអណ្តែតឡើង** ព្រោះអត្ថថា ព្រះបាទរបស់ព្រះអង្គខ្ពស់កំពុង ព្រោះសភាពព្រះបាទតាំងនៅត្រង់ខាងលើ ។ ពិតហើយ កជើងរបស់មនុស្សដទៃមានត្រង់ខ្នងជើង ។ ព្រោះដូច្នោះ ជើងរបស់មនុស្សដទៃ រឹងដូចបោះស្នៀត មិនផ្លាស់ប្តូរបានតាមស្រួល ។ កាល

ដើរទៅផ្ទៃជើងមិនប្រាកដ ។ តែព្រះបាទរបស់ព្រះតថាគត កព្រះបាទតាំងឡើងនៅខាងលើ ។ ព្រោះដូច្នោះ ព្រះកាយខាងលើតាំងពីព្រះនាភិទៅ ទើបមិនញ័រ ដូចសុវណ្ណបដិមានៅលើទូក ព្រះកាយខាងក្រោមប៉ុណ្ណោះញ័រ ។ ព្រះបាទរមែងផ្លាស់ប្តូរទៅបានដោយងាយ ។ កាលមនុស្សឈរមើលត្រង់ខាងមុខក្តី ខាងក្រោយក្តី ត្រង់ខាងទាំងពីរក្តី ផ្ទៃជើងរមែងប្រាកដ ។ មិនប្រាកដខាងក្រោយដូចជើងរបស់ដំរី ដូច្នោះ ។ បទថា **ទ្រង់មានព្រះជង្ឃាវៀវដូចស្មងសត្វទ្រាយ** គឺ មានព្រះជង្ឃាពេញ ព្រោះភាពកំពុងរបស់សាច់ ឈ្មោះថា មានព្រះជង្ឃាដូចសត្វទ្រាយ មិនមានសាច់ជាដុំជាប់តែម្យ៉ាង ។ សំដៅសេចក្តីថា ប្រកបដោយស្មង ដែលមានសាច់បានចំណែកគ្នាដណ្តប់ហើយ មូលល្អដូចជាពោះស្រូវសាលី ដូច្នោះ ។ បទថា **អនោនមន្តោ** គឺ មិនឱនចុះ ។ ដោយបទនេះ លោកសម្តែងដល់ភាពដែលព្រះអង្គមិនជាមនុស្សតឿ មិនជាមនុស្សគម ។ គឺ មនុស្សដទៃៗ ជាមនុស្សតឿក៏មាន ជាមនុស្សគមក៏មាន ។ កាយខាងមុខរបស់មនុស្សតឿមិនបរិបូណ៌ ។ កាយពាក់កណ្តាលខ្នងរបស់មនុស្សគមមិនបរិបូណ៌ ។ អ្នកទាំងនោះ ឱនចុះមិនបាន មិនអាចនឹងស្ទាបជង្គង់បាន ព្រោះកាយមិនបរិបូណ៌ ។ សម្រាប់ព្រះតថាគត

ឈ្មោះថា អាចស្គាបបាន ព្រោះមានព្រះកាយទាំងពីរចំណែកបរិបូណ៌ ។ ឈ្មោះថា ទ្រង់មានព្រះគុយ្ហឋានស្ថិតនៅក្នុងស្រោម ព្រោះអត្ថថា គុយ្ហឋានតាំងចុះ គឺ បិទនៅក្នុងស្រោម ដូចជាត្របកបទុមមាស និងផ្កាកណ្ណិកា ដូចគុយ្ហឋានរបស់គោឧសុភៈ និងដំរីជាដើម ។ បទថា **វត្ថគុយ្ហំ** បានដល់ វត្ថុដែលនឹងគប្បីបិទបាំងដោយសំពត់ លោកហៅថា អង្គជាតិ ។ បទថា **ទ្រង់មានព្រះឆវីវណ្ណដូចមាស** សេចក្តីថា ដូចនឹងរូបបដិមាមាស ដែលគេលាបផាត់ដោយជាតក្រហម ខាត់ដោយចង្កូមខ្លា ធ្វើការលាបផាត់ពណ៌ក្រហមទុក ។ ដោយពាក្យនេះ ព្រះសង្គីតិកាចារ្យសម្តែងសភាពដែលព្រះ-អង្គមានសរីរៈល្អិតស្និទ្ធដូចជាដុំហើយ ទើបពោលថា ទ្រង់មានពណ៌សម្បុរថ្លាផូរផង់ដូចមាស ក៏ដើម្បីសម្តែងដល់ព្រះឆវីវណ្ណ ។ ន័យម្យ៉ាងទៀត ពាក្យនេះ ជាវេវចនៈនៃពាក្យមុននោះ ។ បទថា **រជោជល្លំ** បានដល់ ធូលីឬមន្ទិល ។ បទថា **ន ឧបលិម្បតិ** បានដល់ មិនជាប់ រមែងបាត់ទៅ ដូចតំណក់ទឹករមៀលលើស្លឹកឈូក ។ ទោះជាយ៉ាងនោះ ព្រះពុទ្ធទាំងឡាយ រមែងទ្រង់ធ្វើការលាងព្រះហស្ត និងលាងព្រះបាទជាដើម ដើម្បីទទួលភាពក្តៅត្រជាក់ និងដើម្បីផលបុណ្យដល់ទាយកទាំងឡាយ ម្យ៉ាងទៀត រមែង

ទ្រង់ធ្វើជាកិច្ចវត្តតែម្តង ។ ធម្មតាកិក្ខុដែលនឹងចូលទៅកាន់សេនាសនៈ ត្រូវលាងជើងហើយទើបចូលទៅ លោកពោលទុកដូច្នេះ ដោយប្រការដូច្នេះ ។ បទថា **ឧទ្ធគ្គលោមោ** សេចក្តីថា ឈ្មោះថា មានចុងព្រះលោមា.ងឡើង ព្រោះអត្ថថា ព្រះលោមារបស់ព្រះអង្គមានចុង.ងឡើង វិលជារង្វង់មូល តាំងនៅដូចជាសម្លឹងមើលសកាពល្អនៃផ្ទៃមុខ ។ បទថា **ទ្រង់មានព្រះកាយត្រង់ដូចព្រហ្ម** សេចក្តីថា មានព្រះកាយត្រង់ដូចព្រហ្ម គឺ មានព្រះសរីរៈខ្ពស់ឡើងទៅត្រង់តែម្តង ។ ធម្មតាសត្វដោយច្រើនមានកាយបង្អោនចុះ ក្នុងទី ៣ កន្លែង គឺ ត្រង់ក ត្រង់ចង្កេះ ត្រង់ជង្គង់ ។ សត្វទាំងនោះ កាលឱនទៅត្រង់ចង្កេះ ក៏នឹងទ្រេតទៅខាងក្រោយ ។ កាលឱនទៅត្រង់ចំណែកទាំងពីរក្រៅពីនេះក៏នឹងទ្រេតទៅខាងមុខ ។ ពួកសត្វខ្លះមានរាងកាយខ្ពស់ តែកោង ។ ពួកសត្វខ្លះមុខងើយត្រាច់ទៅ ដូចជាប់រាប់ពួកផ្កាយនក្សត្រ ។ ពួកសត្វខ្លះមានសាច់ និងឈាមតិច ដូចលំពែង ដើរញ័រៗ ។ តែព្រះតថាគត មានព្រះសរីរៈខ្ពស់ត្រង់ល្មមប្រមាណ ដូចជាសសរបន្ទាយមាស ដែលគេលើកឡើងក្នុងទេវនគរ ដូច្នោះ ។ បទថា **ទ្រង់មានព្រះកាយពេញក្នុងទីទាំង ៧** គឺ ព្រះតថាគតនោះ មានព្រះមំសៈពេញក្នុងទី ៧ កន្លែង ទាំងនេះ

គឺ ខ្នងព្រះហស្ដទាំង ២ ខ្នងព្រះបាទទាំង ២ និងព្រះស្មូរង ដូច្នោះទើប ឈ្មោះថា មានព្រះកាយពេញក្នុងទី ៧ កន្លែង ចំណែកសត្វពួកដទៃ ប្រាកដ សរសៃដូចសំណាញ់ត្រង់ខ្នងដៃខ្នងជើង ត្រង់ចន្លោយស្មាជាឆ្អឹង និងត្រង់ក ។ មនុស្សទាំងនោះ រមែងប្រាកដដូចជាមនុស្សប្រេត ។ ព្រះតថាគត មិន ដូច្នោះទេ ។ គឺ ព្រះតថាគត ទ្រង់មានព្រះស្មូរងដូចស្នែងសត្វមាស ដែល ខាត់ដោយដៃហើយ ដាក់ទុកដោយសំណាញ់ជាគ្រឿងបិទបាំង ឈ្មោះថា រមែងប្រាកដដូចរូបសិលា និងរូបចិត្រកម្ម ព្រោះមានព្រះមំសៈពេញក្នុង ទី ៧ កន្លែង ។ ឈ្មោះថា មានព្រះកាយ ដូចកាយពាក់កណ្ដាលខាងមុខនៃ សត្វសីហៈ ព្រោះកាយរបស់ព្រះអង្គដូចកំណាត់មុខនៃសីហៈ ។ គឺ កាយ កំណាត់មុខនៃសីហៈបរិបូណ៌ កាយកំណាត់ក្រោយមិនបរិបូណ៌ ។ ចំណែក កាយរបស់ព្រះតថាគត ព្រះកាយទាំងអស់បរិបូណ៌ដូចកាយកំណាត់ខាងមុខ របស់សីហៈ ។ សូម្បីព្រះកាយនោះ នឹងតាំងនៅល្អ ឬមិនល្អ ព្រោះឱន ទៅទ្រេតទៅជាដើម ក្នុងទីនោះៗ ដូចកាយរបស់សីហៈក៏មិនមែន ។ តែ វែងក្នុងទីដែលគួរវែង ។ ខ្លីក្នុងទីដែលគួរខ្លី គួរក្រាស់ គួរមូល ក៏យ៉ាង នោះតែម្យ៉ាង ។ សមដូចដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ កាលផលរបស់កម្មជាទីពេញចិត្ត ប្រាកដហើយ រមែងល្អដោយអវយវៈវែងពួកណា អវយវៈវែងទាំងនោះក៏តាំងនៅ រមែងល្អដោយអវយវៈខ្លីពួកណា អវយវៈខ្លីទាំងនោះក៏តាំងនៅ រមែងល្អដោយអវយវៈក្រាស់ពួកណា អវយវៈក្រាស់នោះក៏តាំងនៅ រមែងល្អដោយអវយវៈពួកខ្វះណា អវយវៈពួកខ្វះនោះក៏តាំងនៅ រមែងល្អដោយអវយវៈមូលពួកណា អវយវៈមូលពួកនោះក៏តាំងនៅ អត្តភាពរបស់ព្រះតថាគត មានសភាពវិចិត្រផ្សេងៗ សន្សំហើយ ដោយសភាពវិចិត្រនៃបុណ្យ ដែលបារមី ១០ តាក់តែងហើយ ដោយប្រការដូច្នេះ ជាងសិល្បៈទាំងពួង ឬអ្នកមានឫទ្ធិទាំងពួងក្នុងលោក ក៏មិនអាចធ្វើ សូម្បីរូបប្រៀបផ្ទឹមនឹងព្រះតថាគតបានដូច្នេះ ។ បទថា **ចិតន្តរំសោ** សេចក្តីថា ចន្លោះបួនខាងទាំងពីរ លោកហៅថា សាច់ជាចន្លោះនៃស្មាបប្រចៀវទាំងពីរ ។ ចន្លោះព្រះអង្សានោះ គឺ មានសាច់ពេញស្មើល្អ ។ ចំណែកស្មាបប្រចៀវរបស់មនុស្សដទៃនោះ មិនស្មើល្អ ។ ស្មាបប្រចៀវទាំងពីរ រមែងប្រាកដដោយឡែកពីគ្នា ។ ចំណែកព្រះអង្សារបស់ព្រះតថាគត មានសាច់តាំងពីចង្កេះរហូតដល់ព្រះសូរង បិទខ្នងតាំងនៅ ដូចផែនមាសដែលគេលើកឡើងទុកខ្ពស់ ។ បទថា **ទ្រង់មានបរិ-**

មណ្ឌលដូចដើមជ្រៃ សេចក្តីថា ទ្រង់មានបរិមណ្ឌលដូចដើមជ្រៃ ដើមជ្រៃមានដើម និងមែកប៉ុនគ្នា ៥០ ហត្ថខ្លះ ១០០ ហត្ថខ្លះ មានប្រមាណប៉ុនគ្នាទាំងប្រវែង ទាំងទទឹង យ៉ាងណា សូម្បីព្រះកាយ និងព្យាមរបស់ព្រះអង្គមានប្រមាណប៉ុនគ្នា ដូច្នោះ ។ របស់មនុស្សពួកដទៃ ទាំងកាយទាំងព្យាមមានប្រមាណវែងមិនប៉ុនគ្នា យ៉ាងនោះ ។ ព្រោះដូច្នោះឯង លោកទើបពោលថា **យាវតក្វស្ស កាយោ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **យាវតក្វស្ស** កាត់ជា **យាវតកោ អស្ស** (របស់ព្រះអង្គប៉ុនណា) ។ បទថា **ទ្រង់មានព្រះសូរង់មូលស្មើ** គឺ មានព្រះសូរង់មូលស្មើគ្នា ។ មនុស្សពួកខ្លះមានកវែង មានកខ្លី និងមានកក្រាស់ ដូចសត្វក្រៀល និងសត្វកុក ក្នុងវេលាយំ សរសៃពួរត្រង់.កររមែងប្រាកដ សំឡេងចេញមកមួយៗ ។ ព្រះសូរង់របស់ព្រះតថាគតនោះមិនយ៉ាងនោះ គឺ កាយរបស់ព្រះតថាគត មានព្រះសូរង់ប្រាកដដូចជាស្នែងសត្វមាស មូលល្អ ។

ក្នុងវេលាត្រាស់សរសៃពួរមិនប្រាកដ ។ មានសំឡេងខ្លាំងដូចផ្គរលាន់ ដូច្នោះ ។ បទថា **រសគ្គសគ្គី** សេចក្តីថា ឈ្មោះថា **រសគ្គសា** ព្រោះអត្ថថា សរសៃល្អសម្រាប់ទទួលរស ។ ពាក្យនោះ ជាឈ្មោះរបស់សរសៃ

ជាគ្រឿងទទួលនូវរសអាហារ ។ ឈ្មោះថា **រសគ្គសគ្គី** ព្រោះអត្ថថា សរសៃទទួលរសអាហារទាំងនោះរបស់ព្រះអង្គជាកំពូលលើស ។ ក៏សរសៃសម្រាប់ទទួលរសអាហារ ៧,០០០ របស់ព្រះតថាគត មានចុងតាំងឡើងចំពោះត្រង់កន្ទុះឯង ។ អាហារ សូម្បីមានប្រមាណប៉ុនគ្រាប់ល្ងដាក់លើចុងអណ្ដាតរមែងផ្សាយទៅទូទាំងព្រះកាយទាំងអស់ ។ ព្រោះហេតុនោះឯង កាលព្រះអង្គទ្រង់តាំងសេចក្ដីព្យាយាមធំ ទ្រង់ញ៉ាំងព្រះកាយឲ្យប្រព្រឹត្តទៅ សូម្បីបាយមួយគ្រាប់ជាដើមខ្លះ ដោយអាហារប្រមាណមួយទូកដៃនៃសណ្ដែកខ្មៅខ្លះ ។ សូម្បីអាហារមានប្រមាណមួយទូកដៃនៃសណ្ដែកខ្មៅ តែសម្រាប់មនុស្សដទៃ ឱជាមិនផ្សាយទៅសព្វកាយទាំងអស់ទេ ព្រោះមិនមានដូច្នោះ ។ ព្រោះហេតុនោះ ជនទាំងនោះ ទើបមានរោគច្រើន ។ លក្ខណៈនេះ រមែងប្រាកដដោយអំណាចនៃផលដែលហូរចេញ គោលគឺ ការមានអាពាធតិច ។ ឈ្មោះថា **ទ្រង់មានព្រះហនុដូចចង្កាកាជសីហ៍** ព្រោះអត្ថថា ចង្ការបស់ព្រះអង្គ ដូចចង្កានៃសីហៈ ។ ក្នុងបទនោះ ចង្កាក្រោមរបស់រាជសីហ៍ រមែងពេញ ចង្កាលើមិនពេញ ។ ចំណែករបស់ព្រះតថាគត រមែងពេញទាំង ២ ខាង ដូចចង្កាក្រោមរបស់រាជសីហ៍ រមែងដូចព្រះចន្ទនៃបក្ខតិថីទី ១២ កើត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទ មានព្រះទន្ត ៤០ ជាដើម ឈ្មោះថា ទ្រង់មានព្រះទន្ត ៤០ គត់ ព្រោះអត្ថថា មាន ២០ គត់ នៅត្រង់ព្រះហនុខាងលើ ២០ គត់ នៅត្រង់ព្រះហនុផ្នែកខាងក្រោម ។ តែធ្មេញរបស់មនុស្សពួកដទៃសូម្បីមានធ្មេញពេញ ក៏មានធ្មេញ ៣២ ប៉ុណ្ណោះ ។ ចំណែកព្រះទន្តព្រះតថាគតមាន ៤០ គត់ ។

មនុស្សពួកដទៃ មានធ្មេញមិនស្មើគ្នា គឺ ពួកខ្លះមានធ្មេញវែង ពួកខ្លះមានធ្មេញខ្លី ។ ចំណែកព្រះទន្តរបស់ព្រះតថាគតស្មើគ្នា ដូចស័ង្ខដែលគេខាត់ទុកដោយល្អ ។

មនុស្សពួកដទៃ មានធ្មេញឃ្លាតពីគ្នា ដូចធ្មេញក្រពើ កាលស៊ីត្រីនិងសាច់ជាដើម ក៏សៀតជាប់ពេញចន្លោះធ្មេញ ។ ចំណែកព្រះតថាគតមានព្រះទន្តមិនឃ្លាតពីគ្នា ដូចជួរពេជ្រដែលគេរៀបទុកល្អ ត្រង់ផែនមាស ដូចការកំណត់ដែលប្រាកដដោយរន្ទាស់ ។

ចំណែកធ្មេញរបស់មនុស្សដទៃ ធ្មេញពុកតាំងឡើង ។ ព្រោះហេតុនោះ អ្នកខ្លះមានចង្កូមខ្មៅខ្លះ មានពណ៌ផ្សេងៗ ខ្លះ ។ ចំណែកព្រះតថាគតមានព្រះចង្កូមសស្និទ្ធ ព្រះចង្កូមប្រកបដោយពន្លឺ កន្លងផុតសូម្បីផ្កាយព្រឹក ។

ព្រោះដូច្នោះ លោកទើបពោលថា **សុសុក្កទាឋោ** ទ្រង់មានព្រះចង្កូមដែលសល្អ ។ បទថា **បហុតជិវ្ហោ** សេចក្ដីថា អណ្ដាតរបស់មនុស្សដទៃ ក្រាស់ខ្លះ ស្ដើងខ្លះ ខ្លីខ្លះ មិនស្មើខ្លះ ។ ចំណែកព្រះជិវ្ហារបស់ព្រះតថាគតទន់ វែង ធំ សម្បូរណ៍ដោយវណ្ណៈ ។ ព្រះអង្គមួរព្រះជិវ្ហានោះ ដូចម្ជុលកឋិន ស៊កចូលប្រហោងនាសិកទាំងអស់បាន ព្រោះជាជិវ្ហាទន់ ដើម្បីបន្ទោបង់សេចក្ដីសង្ស័យរបស់អ្នកមកមើលលក្ខណៈនោះ ។ នឹងស៊កប្រហោងព្រះកាណ៌ទាំងពីរបាន ព្រោះព្រះជិវ្ហាវែង ។ នឹងបិទព្រះនលាដសូម្បីទាំងអស់ ដែលមានជាយព្រះកេសាជាទីបំផុតបាន ព្រោះព្រះជិវ្ហាធំ ។ កាលប្រកាសថា ព្រះជិវ្ហានោះទន់ វែង និងធំ រមែងបន្ទោបង់សេចក្ដីសង្ស័យបាន ដោយប្រការដូច្នេះ ។ ព្រះសង្គីតិកាចារ្យ អាស្រ័យព្រះជិវ្ហាដែលសម្បូរណ៍ដោយលក្ខណៈបីប្រការដូច្នេះ ទើបពោលថា **បហុតជិវ្ហោ** ដូច្នេះ ។

បទថា **ព្រហ្មស្សរោ** សេចក្ដីថា មនុស្សដទៃ មានសំឡេងដាច់ខ្លះ មានសំឡេងបែកខ្លះ មានសំឡេងដូចក្អែកខ្លះ ។ ចំណែកព្រះតថាគត ទ្រង់ប្រកបដោយសំឡេងខ្លាំងដូចនឹងសំឡេងមហាព្រហ្ម ។ គឺ សំឡេងរបស់មហាព្រហ្ម ឈ្មោះថា ប្រាសចាកទោស ព្រោះមិនត្រូវប្រម៉ាត់ និងស្លេស្ម

រុំព័ទ្ធ ។ កម្មដែលព្រះតថាគតទ្រង់បំពេញ រមែងញុំាងវត្ថុនៃសំឡេងនោះឲ្យបរិសុទ្ធិ ។ សំឡេងតាំងឡើងតាំងពីព្រះនាភិ រមែងប្រាសចាកទោសប្រកបដោយអង្គ ៨ តាំងឡើង ព្រោះវត្ថុបរិសុទ្ធិ ។ ឈ្មោះថា ទ្រង់មានព្រះតម្រាស់ដូចសំឡេងសត្វការវិក ព្រោះត្រាស់ដូចសត្វការវិក ។ មានន័យថា មានព្រះសូរសៀងពីរោះដូចសត្វការវិកស្រែកយំ មានសំឡេងដ៏ពីរោះ ។ ក្នុងសេចក្ដីនោះ ការបន្លឺសំឡេងស្រែករបស់សត្វការវិក ជាឧទាហរណ៍ ។

បានឮថា កាលសត្វការវិកចឹកស្វាយទុំដែលមានរសផ្អែមឆ្ងាញ់ដោយចំពុះ ភ្លក់រសដែលហូរចេញហើយ ញុំាងចង្វាក់ភ្លេងដោយស្លាបកងរំពងសត្វចតុបាទជាដើម រមែងរំភើបកាំងស្មារតី ។ សត្វចតុបាទសូម្បីខ្វល់ខ្វាយស្វែងរកអាហារ ក៏ខ្ជាក់ចោលស្មៅដែលនៅក្នុងមាត់ចេញ ស្ដាប់សំឡេងសត្វនោះ ។ សូម្បីពួកម្រឹគកំពុងដេញតាមម្រឹគតូចៗ ក៏មិនញុំាងជំហានជើងដែលលើកឡើងហើយ ក៏ឈប់ ។

សូម្បីម្រឹគដែលត្រូវដេញតាម ក៏លែងខ្លាចស្លាប់ ឈប់(ស្ដាប់) ។ សូម្បីសត្វដែលហើរទៅក្នុងអាកាសក៏សំកាំងស្លាប ឈប់ហើរ ។ សូម្បីត្រី

ក្នុងទឹកក៏មិនហែលទៅមុខ ស្តាប់តែសំឡេងនោះ ។ សត្វការវិក មានសំឡេងដ៏ពីរោះ ដោយប្រការដូច្នេះ ។ សូម្បីព្រះទេវីរបស់ព្រះបាទធម្មាសោក ព្រះនាមថា **អសន្ធិមិត្តា** សួរព្រះសង្ឃថា លោកម្ចាស់ដ៏ចម្រើន សំឡេងរបស់អ្នកណា ដូចគ្នានឹងព្រះសូរសៀងរបស់ព្រះពុទ្ធមានខ្លះឬ ។

ព្រះសង្ឃ- មានសំឡេងសត្វការវេក ។

ព្រះនាង- លោកម្ចាស់ដ៏ចម្រើន សត្វទាំងនោះ នៅទីណា ។

ព្រះសង្ឃ- នៅត្រង់ព្រៃហិមពាន្ត ។

ព្រះនាងនោះ ក្រាបទូលព្រះរាជាថា បពិត្រសម្មតិទេព ខ្ញុំម្ចាស់ប្រាថ្នានឹងឃើញសត្វការវិក ។ ព្រះរាជាទ្រង់ត្រាស់ថា សូមសត្វការវិកចូរមកទំនៅក្នុងទ្រុងនេះ ។ ទ្រុងទើបទៅនៅខាងមុខសត្វការវិក ។ សត្វនោះគិតថា ទ្រុងមកតាមព្រះរាជឱង្ការ មិនអាចដើម្បីនឹងមិនទៅ ទើបទំនៅក្នុងទ្រុងនោះ ។ ទ្រុងទើបមកនៅត្រង់ព្រះភ័ក្ត្ររបស់ព្រះរាជា ។ តែអ្នកណាៗក៏មិនអាចឲ្យសត្វការវិកបញ្ចេញសំឡេងបាន ។ លំដាប់នោះព្រះរាជាត្រាស់ថា នែនាយ សត្វនេះនឹងបញ្ចេញសំឡេងស្រែកបានយ៉ាងណា ។ អាមាត្រទូលថា បពិត្រព្រះអង្គ សត្វនេះ ឃើញពួកញាតិហើយនឹងបញ្ចេញសំឡេង

ស្រែកបាន ។ ពេលនោះ ព្រះរាជាទើបទ្រង់ត្រាស់ឲ្យព័ទ្ធវង់ជុំវិញ ដោយកញ្ចក់ ។ សត្វនោះ កាលឃើញស្រមោលរបស់ខ្លួនឯង សម្គាល់ថា ញាតិរបស់យើងមកហើយ ទើបញ៉ាំងចង្វាក់ភ្លេងដោយមាត់ ស្រែកដោយសំឡេងដ៏ពីរោះ ដូចអ្នកផ្លុំប៉ីកែវ ដូច្នោះ ។ ពួកមនុស្សក្នុងព្រះនគរទាំងអស់ការាំងស្មារតី ដូចជាអ្នកស្រវឹង ។ ព្រះនាងអសន្ធិមិត្តា គិតថា សត្វតិរច្ឆាននេះនៅមានសំឡេងពីរោះ ដូច្នេះ សំឡេងរបស់ព្រះមានព្រះភាគ អ្នកដល់សិរីនៃសព្វញ្ញុតញ្ញាណ នឹងពីរោះយ៉ាងណាហ្ន៎ ទើបកើតបីតិ មិនលះបីតិនោះ ទ្រង់តាំងនៅក្នុងសោតាបត្តិផល ព្រមទាំងនាងស្នំ ៧០០ នាក់ ។ សំឡេងរបស់សត្វការវិកពីរោះ ដោយប្រការដូច្នេះ ។ ព្រះសូរសៀងរបស់ព្រះតថាគតនៅពីរោះជាងនោះដល់រយដង ពាន់ដង ។ តែព្រោះមិនមានសំឡេងពីរោះយ៉ាងដទៃពីសត្វការវិកក្នុងលោក លោកទើបពោលថា **ករវិកភាណី** ដូច្នេះ ។ បទថា **ទ្រង់មានព្រះនេត្រខៀវយង់** សេចក្តីថា មិនមែនមានព្រះនេត្រខៀវទាំងអស់ឡើយ ។ តែព្រះនេត្ររបស់ព្រះអង្គ ប្រកបដោយពណ៌ខៀវក្នុងទីដែលគួរខៀវ បរិសុទ្ធិក្រៃលែងដូចផ្កាត្រកៀត ។ ប្រកបដោយពណ៌លឿងដូចផ្កាកណ្ណិកា ក្នុងទីដែលគួរលឿង ។ ប្រកបដោយពណ៌ក្រហម ដូច

ផ្កាចង្ក្រាក្នុងទីដែលគួរក្រហម ។ ប្រកបដោយពណ៌សដូចផ្កាយព្រឹក្ស ក្នុងទីដែលគួរស ។ ប្រកបដោយពណ៌ខ្មៅដូចទឹងគ្រាប់ផ្កាំ ក្នុងទីដែលគួរខ្មៅ រមែងប្រាកដដូចទឹងសីហបញ្ជរកែវ ដែលលើកឡើងព្យួរទុកក្នុងវិមានមាស ។ បទថា **បខុមំ** ក្នុងពាក្យថា **គោបខុមោ** នេះ លោកបំណងយកដួងព្រះនេត្រទាំងអស់ ។ ដួងព្រះនេត្រនោះ មានសភាពក្រាស់ដូចកូនគោខ្មៅ ថ្លាច្បាស់ ស្រដៀងគ្រាប់ភ្នែករបស់គោក្រហម មានន័យថា ភ្នែកកូនគោក្រហមដែលកើតមួយភ្លែតនោះឯង ។

ក៏គ្រាប់ភ្នែករបស់មនុស្សពួកដទៃមិនពេញ មានភ្នែកស្រលៀងខ្លះ ជ្រៅទៅខ្លះ ដូចគ្នានឹងភ្នែករបស់ដំរី កណ្ដុរ និងភ្អែកជាដើម ។ ចំណែកព្រះតថាគតមានព្រះនេត្រស្រទន់ខ្មៅស្និទ្ធ សុខុម តាំងនៅដូចដុំកែវមណីដែលគេលាងទុក ដូច្នោះ ។

បទថា **ឧណ្ណា** បានដល់ ព្រះឧណ្ណាលោម (រោមពណ៌ស) ។ បទថា **ភមុកន្តរេ** សេចក្ដីថា ព្រះឧណ្ណាលោម កើតលើនាសិក ត្រង់កណ្ដាលចិញ្ចើមទាំងពីរនោះ តែកើតត្រង់កណ្ដាលព្រះនលាដខ្ពស់ឡើងទៅ ។ បទថា **ឱទាតា** បានដល់ បរិសុទ្ធិ មានពណ៌ដូចផ្កាយព្រឹក ។

*បទថា **មុទុ** សេចក្តីថា ដូចជាសំឡីដែលគេជ្រលក់ក្នុងទឹកដោះថ្លា ហើយរលាស់ដល់មួយរយដងតាំងទុក ។ បទថា **តូលសន្និភា** សេចក្តីថា ស្មើដោយសំឡីផ្ការកា និងសំឡីលតា ។ នេះជាការឧបមាព្រះឧណ្ណាលោមនោះ មានពណ៌ស ។ ក៏ព្រះឧណ្ណាលោមនោះ កាលចាប់ត្រង់ចុងទាញមក និងមានប្រមាណស្មើកន្លះហត្ថ ។ ទៅហើយ នឹងមូលមានចុង.ងឡើងជាទក្ខិណាវដ្ដ ។ រមែងរុងរឿងដោយសិរី ជាទីរីករាយក្រៃលែងដូចគ្នានឹងពងប្រាក់ដែលគេដាក់ទុកត្រង់កណ្តាលផែនមាស ដូចខ្សែទឹកដោះ ដែលហូរចេញចាកផ្ទាំងមាស និងដូចផ្កាយព្រឹកក្នុងផ្ទៃអាកាសដែលរុងរឿងដោយពន្លឺអរុណ ដូច្នោះ ។*

*ពាក្យថា **ឧណ្ហិសសីសោ** នេះ លោកពោលអាស្រ័យអំណាចប្រយោជន៍ ២ ប្រការ គឺ មានព្រះនលាដពេញ ១ មានព្រះសិរសាពេញ ១ ។ គឺ ព្រះមំសៈតាំងឡើង តាំងពីព្រះកាណ៌ខាងស្តាំទៅបិទព្រះនលាដទាំងអស់ពេញទៅដរាបព្រះកាណ៌ខាងឆ្វេង រុងរឿងដូចមកុដ ដែលព្រះរាជាទ្រង់ពាក់ ។ បានឮថា អ្នកប្រាជ្ញជ្រាបព្រះលក្ខណៈនេះ របស់ព្រះពោធិសត្វក្នុងបច្ឆិមភព ទើបបានធ្វើមកុដថ្វាយព្រះរាជា ។ ដោយអត្ថប្រការមួយប៉ុណ្ណោះ ។*

ចំណែកមនុស្សពួកដទៃ មានសីសៈមិនពេញ ។ អ្នកខ្លះមានសីសៈដូចក្បាលស្វា អ្នកខ្លះមានសីសៈដូចផ្លែឈើ អ្នកខ្លះមានសីសៈដូចឆ្អឹង អ្នកខ្លះមានសីសៈដូចក្អម អ្នកខ្លះមានសីសៈពយ ។ ចំណែកព្រះតថាគត មានព្រះសិរសាដូចជុំទឹកពេញល្អ ដូចវត្ថុដែលមូលស្ថិតនៅលើចុងដែកស្រួច ។ ឈ្មោះថា **មានព្រះសិរសាមូលដូចប្រដាប់ដោយមកុដ** ព្រោះអត្ថថា មានព្រះសីសៈជាបរិមណ្ឌល ក្នុងទីគ្រប់កន្លែង ដូចឧណ្ហិសៈ តាមន័យទីពីរ ។ ក៏មហាបុរិសលក្ខណៈទាំងនេះ គឺ លោកសម្ដែងចំណែកទាំង ៤ នេះ គឺ កម្ម ១ , ផលដែលបុគ្គលគប្បីឃើញស្មើដោយកម្ម ១ , លក្ខណៈ ១ , អានិសង្សនៃលក្ខណៈ ១ ។ ក្នុងលក្ខណៈតែនីមួយៗ លោកលើកយកមកសម្ដែងទុក ជាការពោលទុកល្អហើយ ។ ព្រោះដូច្នោះ បណ្ឌិតគប្បីសម្ដែងកម្មជាដើមទាំងនេះ ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងលក្ខណសូត្រហើយពោលចុះ ។ កាលមិនអាចវិនិច្ឆ័យដោយអំណាចនៃព្រះសូត្រ ក៏គប្បីកាន់យកដោយន័យដែលពោលទុកក្នុងអដ្ឋកថានៃព្រះសូត្រ ក្នុងអដ្ឋកថានិកាយឈ្មោះ សុមង្គលវិលាសិនីនោះចុះ ។

បទថា **ឥមេហិ ខោ សោ ភោ ភវំ គោតមោ** សេចក្ដីថា ឧត្ត-

មាណពពោលពាក្យជាដើមថា **គច្ឆន្តោ ខោ បន** ដូច្នេះ ដើម្បីនឹងសម្តែងសូម្បីសេចក្តីនេះ ហើយប្រាប់ដល់កិរិយា និងអាចារៈថា បពិត្រលោកអាចារ្យដ៏ចម្រើន ព្រះគោតមដ៏ចម្រើនព្រះអង្គនោះ ទ្រង់ប្រកបដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការទាំងនេះ ទ្រង់ត្រាច់ទៅដូចជាសសរបន្ទាយមាសដែលវិចិត្រដោយកែវ ដែលបុគ្គលលើកឡើងក្នុងទេវនគរ ដូចដើមបារិឆត្តមានផ្ការីកស្គុះស្គាយខ្ពស់ដល់ ១០០ យោជន៍ ដូចដើមសាលៈមានផ្ការីកពេញក្នុងចន្លោះភ្នំ ដូចផ្ទៃអាកាសដែលពាសពេញដោយពួកផ្កាយ ដូចធ្វើលោកឲ្យភ្លឺដោយសិរីសម្បត្តិរបស់ព្រះអង្គ ដូច្នោះ ។

បទថា **ទក្ខិណេន** សេចក្តីថា កាលព្រះពុទ្ធទាំងឡាយប្រថាប់ឈរក្តី ប្រថាប់អង្គុយក្តី ផ្ទំក្តី កាលនឹងទ្រង់ព្រះដំណើរ ទ្រង់ឈានព្រះបាទខាងស្តាំមុន ។ បានឮថា នេះជាព្រះបាដិហារ្យដោយ ៧ ចំណែក ។ បទថា **នាតិទូរេបាទំ ឧទ្ធរតិ** សេចក្តីថា ទ្រង់លើកព្រះបាទខាងស្តាំនោះ ទ្រង់ព្រះតម្រិះថា នឹងមិនដាក់ព្រះបាទឲ្យឆ្ងាយពេក ។ គឺ កាលទ្រង់លើកព្រះបាទស្តាំឆ្ងាយពេក ព្រះបាទឆ្វេងនឹងត្រូវទាញទៅ សូម្បីព្រះបាទខាងស្តាំ ក៏ទៅឆ្ងាយមិនបាន នឹងគប្បីដាក់នៅជិតៗ គ្នាតែម្យ៉ាង ។

បើដូច្នេះ រមែងឈ្មោះថា ជាការកំណត់ឈានទៅ ។ តែកាលឈាន ព្រះបាទខាងស្តាំល្មមប្រមាណ សូម្បីព្រះបាទខាងឆ្វេង ក៏រមែងលើកឡើងល្មមប្រមាណដូចគ្នា ។ កាលបើលើកល្មមប្រមាណ សូម្បីទ្រង់ ក៏ដាក់បានល្មមប្រមាណដូចគ្នា ។ ព្រោះការដែលទ្រង់កំណត់យ៉ាងនេះ នាទីព្រះបាទខាងស្តាំរបស់ព្រះតថាគត ក៏រមែងជាការកំណត់ហើយ នាទីព្រះបាទឆ្វេង ក៏ជាការកំណត់ហើយដោយព្រះបាទខាងស្តាំ បណ្ឌិតគប្បីជ្រាប ដោយប្រការដូច្នេះ ។

បទថា **នាតិសីឃំ** សេចក្តីថា ទ្រង់មិនព្រះដំណើររហ័សពេក ដូចភិក្ខុដើរទៅដើម្បីទទួលភត្តក្នុងវិហារ កាលវេលាប្រញាប់ហើយ ។ បទថា **នាតិសណិកំ** សេចក្តីថា ទ្រង់មិនព្រះដំណើរយឺត ដូចភិក្ខុដែលមកក្រោយរមែងមិនបានឱកាស ដូច្នោះ ។ ពាក្យថា **អទ្ធុវេន អទ្ធុវំ** គឺ ព្រះជន្នុមិនប៉ះខ្ទប់នឹងព្រះជន្នុ ជង្គង់នឹងជង្គង់មិនប៉ះខ្ទប់គ្នា ។ បទថា **ន សត្ថឹ** សេចក្តីថា ទ្រង់មិនលើកព្រះឧរុខ្ពស់ឡើង ដូចដើរទៅក្នុងទឹកជ្រៅ ។ បទថា **ន ឱនាមេតិ** សេចក្តីថា ទ្រង់មិនសណ្តូកព្រះឧរុទៅខាងក្រោយ ដូចការសណ្តូកជើងទៅខាងក្រោយរបស់អ្នកកាត់មែកឈើ ។ បទថា **ទ្រង់មិនរឹងស្តូក** គឺ

ទ្រង់មិនធ្វើឲ្យជាប់គ្នា ដូចជាន់ជើងនឹងកន្ទែងដែលសើមហើយ ។ បទថា **ទ្រង់មិនកែក្រោយ** គឺ ទ្រង់មិនយោលយោគទៅមក ដូចនាំរូបយន្ត ។ បទថា **អារទ្ធកាយោវ** សេចក្តីថា ព្រះកាយផ្នែកខាងក្រោមប៉ុណ្ណោះកម្រើកទៅ ។ ព្រះកាយចំណែកខាងលើមិនញ័រ ដូចរូបមាសដែលគេតម្កល់ទុកក្នុងទូក ។ ក៏កាលបុគ្គលឈរក្រឡេកមើលនៅក្នុងទីឆ្ងាយនឹងមិនដឹងថា ព្រះពុទ្ធទាំងឡាយប្រថាប់ឈរ ឬទ្រង់ព្រះដំណើរ ។ បទថា **កាយពលេន** សេចក្តីថា ទ្រង់មិនបង់បោយ ស្តេចព្រះដំណើរទៅដោយកម្លាំងកាយ ទាំងដែលមានព្រះសេទោហូរចេញចាកព្រះសរីរៈ ។ បទថា **សព្វកាយេន វា** សេចក្តីថា មិនបែរព្រះកគ្រក្រឡេកមកក្រោយមើល ដោយអំណាចនៃការក្រឡេកមើលដូចស្តេចដំរី បានពោលទុកក្នុងរាហុលោវាទសូត្រនុ៎ះឯង ។ ក្នុងពាក្យថា **ន ឥទ្ធំ** ជាដើម គឺ ទ្រង់មិនងើយមើលខាងលើ ដូចកំពុងងើយរាប់ផ្កាយនក្សត្រ ទ្រង់មិនឱនមើលខាងក្រោម ដូចកំពុងស្វែងរកប្រាក់កាកណិក ឬមាសកៈដែលបាត់ ទ្រង់មិនងាកទៅខាងឯណេះខាងឯណោះ ដូចកំពុងសម្លឹងមើលដំរី និងសេះជាដើម ។ បទថា **យុគមត្តំ** សេចក្តីថា កាលទ្រង់ព្រះដំណើរទតព្រះចក្ខុប្រមាណ ៩ ចំអាម ឈ្មោះថា មើលប្រមាណមួយជួរនឹម ។

សូម្បីព្រះមានព្រះភាគ ក៏ទ្រង់ព្រះដំណើរទៅតមានប្រមាណប៉ុណ្ណោះ ដូចសត្វអាជានេយ្យដែលទូន្មានល្អហើយ ដែលគេទឹមទុក ដូច្នោះ ។ បទថា **តតោ ចស្ស ឧត្តរឹ** សេចក្ដីថា តែមិនគួរពោលថា ទ្រង់មិនមើលលើសពីមួយទឹមទៅ ។ ព្រោះជញ្ជាំងក្ដី សន្ទះទ្វារក្ដី គល់ឈើក្ដី វល្លិ៍ក្ដី រមែងមិនអាចបាំងបាន ។ ពាន់នៃចក្រវាឡមិនមែនតិច រមែងជាទីទូលតែមួយជាមួយគ្នាតែម្យ៉ាង ដល់អនាវរណញ្ញាណនោះ ដោយព្រះអង្គឯង ។ បទថា **អន្តរឃរំ** គប្បីជ្រាបតាំងពីសសរខឿនទៅ ឈ្មោះថា លង្វែកស្រុក ក្នុងមហាសកុលុទាយិសូត្រក្នុងខាងក្រោយ តែក្នុងទីនេះ គប្បីជ្រាបថា តាំងពីធរណីទ្វារស្រុកទៅ ឈ្មោះថា លង្វែកស្រុក ។ បទថា **ន កាយំ** ជាដើម លោកពោលដើម្បីសម្ដែងថា ទ្រង់រមែងចូលទៅដោយឥរិយាបថតាមប្រក្រតីនុ៎ះឯង ។ សូម្បីកាលព្រះតថាគត ទ្រង់ស្ដេចចូលទៅកាន់ផ្ទះរបស់អ្នកក្រ ដំបូលរមែងខ្ពស់ឡើងខ្លះ ផែនដីរមែងស្រុតចុះខ្លះ ។ ចំណែកព្រះមានព្រះភាគ ក៏ទ្រង់ព្រះដំណើរទៅ ដោយព្រះដំណើរតាមប្រក្រតីនុ៎ះឯង ។ បទថា **នាតិទូរេ** សេចក្ដីថា ក្នុងទីឆ្ងាយពេក ក៏ទ្រង់ត្រឡប់ថយក្រោយមួយជំហាន ឬពីរជំហាន ហើយទើបប្រថាប់គង់ចុះសន្សឹមៗ ។ ក្នុងទីជិតពេក ក៏ទ្រង់ឈាន

ទៅខាងមុខមួយជំហាន ពីរជំហាន ហើយប្រថាប់គង់ចុះសន្សឹមៗ ។ ព្រោះ ដូច្នោះ កាលប្រថាប់ឈរត្រង់ជំហានព្រះបាទណា ស្តេចទ្រង់ឈានទៅខាង មុខ ឬថយខាងក្រោយហើយ ទើបនឹងប្រថាប់គង់ ទ្រង់ក៏នឹងផ្លាស់ជំហាន ព្រះបាទនោះ ។ បទថា **បាណិនា** សេចក្តីថា ទ្រង់មិនយកព្រះហស្តចាប់ អាសនៈមកប្រថាប់គង់ដូចអ្នកជម្ងឺ ព្រោះរោគខ្យល់ ។ បទថា **បក្ខិបតិ** សេចក្តីថា បុគ្គលណាធ្វើការផ្សេងៗ នឿយហត់រៀបនឹងដួលទៅទាំងឈរ សូម្បីបុគ្គលណាអង្គុយផ្អែក អវយវៈផ្នែកខាងមុខទ្រេតកាយទៅ ដរាបដល់ អវយវៈផ្នែកខាងខ្នង ឬអង្គុយផ្អែកអវយវៈផ្នែកខាងខ្នង ទ្រេតកាយយ៉ាង នោះដរាបដល់អវយវៈផ្នែកខាងមុខ ទាំងអស់នោះឈ្មោះថា ផ្អែកកាយត្រង់ អាសនៈ ។ ចំណែកព្រះមានព្រះភាគ ទ្រង់មិនធ្វើយ៉ាងនោះ ប្រថាប់គង់ សន្សឹមៗ ដូចការពាររបស់ដែលព្យួរនៅត្រង់កណ្តាលអាសនៈ ដូចដាក់សំឡីគ ទុក ដូច្នោះ ។ បទថា **ហត្ថកុក្កុច្ចំ** សេចក្តីថា ធ្វើការជូតទឹកត្រង់កណ្តាប់ មាត់បាត្រ គឺ ធ្វើការដែលមិនបានប្រុងប្រយ័ត្ន ដូចបក់រុយ និងដូចប្រើ ដៃក្តិះត្រចៀកជាដើម ។ បទថា **បាទកុក្កុច្ចំ** គឺ ការមិនប្រុងប្រយ័ត្នជើង ដូចយកជើងគូសផែនដីជាដើម ។ បទថា **ន ឆម្ភតិ** ប្រែថា មិនខ្លាច ។ បទ

ថា **ន កម្បតិ** ប្រែថា មិនលិចចុះ ។ បទថា **ន វេធតិ** គឺ មិនញាប់ញ័រ ។ បទថា **ន បរិតស្សតិ** ប្រែថា មិនតក់ស្លុត ដោយសេចក្ដីតក់ស្លុត ព្រោះខ្លាចខ្លះ ដោយការតក់ស្លុត ព្រោះតណ្ហាខ្លះ ។ គឺ ភិក្ខុរូបខ្លះ រមែងតក់ស្លុត ដោយសេចក្ដីតក់ស្លុត ព្រោះខ្លាចថា កាលពួកមនុស្សមកដើម្បីប្រយោជន៍ធម្មកថាជាដើម សំពះហើយឈរ យើងនឹងអាចដើម្បីយកចិត្តរបស់មនុស្សពួកនោះ ពោលធម៌ឬហ្ន៎ កាលត្រូវសួរបញ្ហាហើយ នឹងអាចវិសជ្ជនាបាន ឬនឹងអាចធ្វើអនុមោទនាបានឬ ។ ភិក្ខុរូបខ្លះ ក៏គិតថា បាយយាគូដែលពេញចិត្តនឹងមកដល់យើងឬហ្ន៎ ឬថា ប្រភេទរបស់ទំពារដែលពេញចិត្តនឹងមកដល់យើង និងតក់ស្លុតដោយសេចក្ដីតក់ស្លុត ព្រោះតណ្ហា ។ ព្រោះសេចក្ដីតក់ស្លុត ២ យ៉ាងនោះ របស់ព្រះគោតមដ៏ចម្រើននោះ មិនមាន ព្រោះដូច្នោះ ព្រះគោតមដ៏ចម្រើន ទើបទ្រង់មិនតក់ស្លុត ។ បទថា **វិវេកាវត្តោ** សេចក្ដីថា ជាអ្នកមានចិត្តវិលមកក្នុងវិវេក គឺ ព្រះនិព្វាន បាឋៈថា **វិវេកវត្តោ** ដូច្នេះ ក៏មាន ។ សេចក្ដីថា ជាអ្នកប្រកបដោយវត្ត គឺ សេចក្ដីស្ងាត់ ។ ការរៀនមូលកម្មដ្ឋានហើយ អង្គុយស្ងៀមស្ងាត់ក្នុងទីសម្រាកក្នុងវេលាពេលថ្ងៃរបស់ភិក្ខុដែលធ្វើភត្តកិច្ចហើយ ដោយអំណាចនៃសមថៈ និងវិបស្សនា

ឈ្មោះថា **វិវេកវត្ត** ។ ព្រោះឥរិយាបថរបស់ភិក្ខុដែលអង្គុយយ៉ាងនេះ រមែងចូលទៅស្ងប់រម្ងាប់ ។

ក្នុងបទថា **ន បត្តំ ឧន្នាមេតិ** ជាដើម មានវិនិច្ឆ័យថា ភិក្ខុរបខ្វះរមែងលើកបាត្រឡើង ដូចត្រងទឹកអំពីកណ្ដាប់មាត់បាត្រ ភិក្ខុរបខ្វះបន្ទាបបាត្រចុះ ដូចដាក់ទុកលើខ្នងជើង ។ ភិក្ខុរបខ្វះ រមែងទទួលធ្វើឲ្យជាប់គ្នា ។ ភិក្ខុរបខ្វះ ស្ទុះទៅផ្ទុវឯណេះស្ទុះទៅឯណោះ ។ សេចក្ដីថា ទ្រង់មិនធ្វើយ៉ាងនោះ ទ្រង់ទទួលដោយព្រះហស្តទាំងពីរ បង្អោនទៅបន្តិចទទួលទឹក ។ បទថា **ន សម្បរិវត្តកំ** សេចក្ដីថា មិនបង្វិលបាត្រ លាងខាងក្រៅបាត្រជាមុន ។ បទថា **នាតិទូរេ** សេចក្ដីថា មិនចាក់ទឹកលាងបាត្រ ឲ្យធ្លាក់ទៅឆ្ងាយចាកអាសនៈដែលអង្គុយ ។ បទថា **ន អច្ចាសន្នេ** សេចក្ដីថា មិនបោលក្នុងទីជិតជើង ។ បទថា **វិច្ឆឌ្ឌិយមានោ** សេចក្ដីថា មិនខ្ចាតទៅ គឺ មិនចាក់ដោយអាការដែលអ្នកទទួលនឹងសើម ។

បទថា **នាតិថោកំ** សេចក្ដីថា មិនទទួលដូចភិក្ខុខ្វះជាអ្នកមានសេចក្ដីប្រាថ្នាលាមក សម្ដែងថា ជាអ្នកមានសេចក្ដីប្រាថ្នាតិច ទទួលត្រឹមតែល្មមនឹងបាយតែមួយក្ដាប់ ប៉ុណ្ណោះ ។ បទថា **នាតិពហុំ** គឺ ទទួលច្រើនជាងការ

ដែលញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ។ បទថា **ព្យញ្ជនមត្តាយ** សេចក្តីថា ចំណែកទី ៤ នៃបាយ ឈ្មោះថា ល្មមប្រមាណដល់បាយ ។ គឺ ភិក្ខុខ្លះ កាលកត្តត្រូវចិត្តក៏ទទួលកត្តច្រើន កាលនឹងបាយត្រូវចិត្តក៏ទទួលបាយច្រើន តែព្រះសាស្តាទ្រង់មិនទទួលយ៉ាងនោះ ។ បទថា **ន ចព្យញ្ជនេន** សេចក្តីថា បរិភោគកត្តតែម្យ៉ាង វៀរបាយដែលមិនពេញចិត្ត ឬបរិភោគបាយតែម្យ៉ាង វៀរកត្ត ឈ្មោះថា បង្អោនដុំបាយច្រើនជាងកត្ត ។ ព្រះសាស្តា ទ្រង់ទទួលកត្ត មានវត្ថុដទៃលាយគ្នា ទាំងកត្តទាំងបាយ ល្មមប្រមាណ ។ បទថា **ទ្វត្តិក្ខត្តុំ** សេចក្តីថា ភោជនដែលព្រះជិវ្ហារបស់ព្រះតថាគតនាំចូលទៅ រមែងវីដូចម្សៅ ដែលគេធ្វើឲ្យល្អិតដោយព្រះទន្តពាល់ត្រូវ ២-៣ ដង ប៉ុណ្ណោះ ។ ដូច្នោះ លោកទើបពោលយ៉ាងនោះ ។ បទថា **មុខេ អវសិដ្ឋា** សេចក្តីថា រមែងកន្លងចូលទៅកាន់ដើម.ក ដូចតំណក់ទឹកដែលធ្លាក់ចុះក្នុងស្លឹកឈូក ព្រោះដូច្នោះ ទើបមិនសល់នៅ ។

បទថា **រសប្បដិសំវេទី** គឺ ទ្រង់ជ្រាបរសមានផ្អែម ល្វីង និងហិល ជាដើម ។

ក៏សម្រាប់ព្រះពុទ្ធទាំងឡាយ រមែងដូចគ្នានឹងដាក់ទិព្វឱជាចុះ ដោយ

ហោចទៅសូម្បីទឹកសោយ ។ ព្រោះដូច្នោះ រមែងប្រាកដរសក្នុងអាហារទាំងអស់ពិត ដល់ព្រះពុទ្ធទាំងឡាយ ។ តែសេចក្តីប្រាថ្នាក្នុងរសមិនមាន ។ បទថា **អដ្ឋង្គសមន្នាគតំ** គឺ ប្រកបដោយអង្គ ៨ ប្រការ ដែលពោលទុកថា មិនសោយដើម្បីលេងជាដើម ។ ពាក្យវិនិច្ឆ័យរបស់បទនោះ មកហើយក្នុងវិសុទ្ធិមគ្គ ដូច្នោះ ពាក្យនេះលោកពោលទុកក្នុងសព្វាវសូត្រ ។ សួរថា កាលទ្រង់លាងព្រះហស្តហើយ ព្រះសាស្តាទ្រង់ធ្វើយ៉ាងណា ។ ឆ្លើយថា ព្រះសាស្តាទ្រង់លាងចំណែកដែលព្រះហស្តចាប់បាត្រមុន ។ ទ្រង់ចាប់បាត្រត្រង់នោះហើយ ដុសទីងបាតព្រះហស្តដែលមានក្រឡាសំណាញ់ ត្រឡប់ទៅមក ២ ដង ។ អាមិសទាំងអស់ក្នុងបាត្រក៏ជ្រះទៅ ដូចទឹកលើស្លឹកឈូកដែលធ្លាក់ទៅដោយអាការត្រឹមតែប៉ុណ្ណេះ ។

បទថា **ន ច អនត្ថិកោ** សេចក្តីថា ដូចភិក្ខុរូបខ្លះដាក់បាត្រទុកលើជើងបាត្រ មិនជូតទឹកបាត្រ សម្លឹងមើលតែធូលីដែលធ្លាក់ទៅ យ៉ាងណា ព្រះអង្គទ្រង់មិនធ្វើយ៉ាងនោះ ។ បទថា **ន ច អតិវេលានុរក្ខី** សេចក្តីថា ដូចភិក្ខុរូបខ្លះ តាំងការរក្សាទុកលើសប្រមាណ ឬធាន់ហើយជូតទឹកបាត្រ ហើយស៊ិកចូលទៅក្នុងចន្លោះផ្នត់ចីវរ កាន់បាត្រត្រង់ពោះទ្រុំះឯង តែព្រះ-

សាស្តាទ្រង់មិនធ្វើដូចយ៉ាងនោះ ។

បទថា **ន ច អនុមោទនស្ស** សេចក្តីថា ក៏ភិក្ខុណាឆាន់រួចហើយ កាលពួកក្មេងៗ ស្រេកឃ្លាំដើម្បីនឹងបរិភោគបាយ កាលពួកអ្នកដែលឃ្លាន មិនទាន់មក ក្មេងៗ បរិភោគហើយ ក៏ផ្តើមអនុមោទនា ។ តអំពីនោះ ពួកខ្លះក៏ចោលការងារទាំងអស់មក ពួកខ្លះនៅមិនទាន់មក ។ ភិក្ខុនេះ រមែងញុំាងវេលាឲ្យកន្លងទៅរហ័សពេក ។ សូម្បីភិក្ខុរូបខ្លះ កាលពួកមនុស្សមកសំពះហើយអង្គុយចុះ ដើម្បីប្រយោជន៍ដល់ការអនុមោទនា ក៏មិនទាន់ធ្វើអនុមោទនា តាំងពាក្យចំពោះជាដើមថា ជាយ៉ាងណា តិស្ស: បុស្ស: សុមន: ជាយ៉ាងណា ពួកលោកមិនឈឺដោយជម្ងឺឬ សន្ទនបរិបូរណ៍ឬ ដូច្នេះ ភិក្ខុនេះឈ្មោះថា ធ្វើវេលានៃការអនុមោទនាឲ្យអស់ទៅ ។ តែកាលពោលក្នុងវេលាដែលពួកអ្នកដឹងវេលាអារាធនាហើយ ឈ្មោះថា មិនធ្វើវេលាឲ្យអស់ទៅ ព្រះសាស្តាទ្រង់ធ្វើយ៉ាងនោះ ។

បទថា **ន តំ ភត្តំ** សេចក្តីថា មិនពោលតិះដៀលជាដើមថា នេះបាយអ្វី ស្រួយពេក ជ្រាយពេក ។ បទថា **ន អញ្ញំ ភត្តំ** សេចក្តីថា កាលនឹងធ្វើអនុមោទនា ដោយគិតថា យើងនឹងញុំាងភត្តឲ្យកើតឡើងដើម្បី

ការបរិភោគ ដែលនឹងមានក្នុងថ្ងៃស្អែកនេះ ឬដើម្បីថ្ងៃតទៅ ឈ្មោះថា រមែងប្រាថ្នាកត្តដទៃ ។ ឬភិក្ខុណាគិតថា យើងនឹងធ្វើអនុមោទនា កាលពួកមាតុគ្រាមដាំបាយហើយ អំពីនោះជាកាលអនុមោទនារបស់យើង ពួកគេនឹងឲ្យបាយបន្តិចបន្តួចអំពីបាយដែលគេដាំ ហើយទើបពង្រីកការអនុមោទនា សូម្បីភិក្ខុនេះ ក៏ឈ្មោះថា រមែងប្រាថ្នា ។ ព្រះសាស្តាទ្រង់មិនធ្វើយ៉ាងនោះ ។ បទថា **ន ច មុញ្ចិត្តុកាមោ** សេចក្តីថា ក៏ភិក្ខុរូបខ្វះលះបង់បរិស័ទចេញទៅ ពួកភិក្ខុទាំងឡាយនឹងត្រូវជាប់តាមទៅដោយរហ័ស ។ តែព្រះសាស្តាទ្រង់មិនដំណើរទៅយ៉ាងនោះ ។ ទ្រង់ដំណើរទៅកណ្តាលបរិស័ទ ។ បទថា **អច្ចុក្កដ្ឋំ** សេចក្តីថា ក៏ភិក្ខុរូបណាឃ្លុំចីវរលើកឡើង ដរាបដល់ទល់ចង្កា ភិក្ខុរូបនោះ ឈ្មោះថា មិនរៀបរយ ។ ភិក្ខុរូបណាដណ្តប់ដរាបដល់កជើង ចីវររបស់ភិក្ខុរូបនោះ ឈ្មោះថា មិនរៀបរយ ។ សូម្បីភិក្ខុរូបណាឃ្លុំលើកឡើងអំពីខាងទាំងពីរ បើកពោះ ចីវររបស់ភិក្ខុរូបនោះ ក៏ឈ្មោះថា មិនរៀបរយ ។ ភិក្ខុរូបណាធ្វើចៀងស្មាម្ខាងបើកដោះ ភិក្ខុរូបនោះក៏ឈ្មោះថា មិនរៀបរយ ។ ព្រះសាស្តាទ្រង់មិនធ្វើអាការយ៉ាងនោះគ្រប់យ៉ាង ។ បទថា **អល្លីនំ** សេចក្តីថា ចីវររបស់ភិក្ខុពួកដទៃជាប់ដោយ

ញើសជាប់នៅយ៉ាងណា ចីវររបស់ព្រះសាស្តា រមែងមិនជាយ៉ាងនោះ ។ បទថា **អបក្កដ្ឋំ** សេចក្តីថា មិនរបូតចាកកាយ ។ បទថា **វាតោ** បានដល់ សូម្បីខ្យល់កំបុតត្បូងតាំងឡើង ក៏មិនអាចនឹងធ្វើឲ្យកម្រើកបាន ។ បទថា **បាទមណ្ឌនានុយោគំ** សេចក្តីថា ប្រកបគ្រឿងប្រដាប់ព្រះបាទ ឲ្យស្អាតល្អ មានការដុសខាត់ព្រះកាយដោយដីស្អិតជាដើម ។ បទថា **បក្ខាលិត្វា** (ទ្រង់ លាងហើយ) សេចក្តីថា ទ្រង់លាងព្រះបាទដោយព្រះបាទនោះឯង ។ លោក ពោលបទថា **សោ នេវ អត្តព្យាពាធាយ** មិនដើម្បីបៀតបៀនព្រះអង្គឯង ជាដើម ព្រោះមានបុព្វេនិវាសញ្ញាណ និងចេតោបរិយញ្ញាណ ។ តែឃើញ នូវឥរិយាបថស្ងប់ ទើបពោលដោយការប៉ាន់ស្មាន ។ បទថា **ធម្មំ** គឺ បរិ- យត្តិធម៌ ។ បទថា **ន ឧស្សាទេតិ** សេចក្តីថា មិនពោលពាក្យមានជាដើម ថា សូម្បីព្រះរាជា មហាកដុម្ពីជាដើម ហើយបញ្ចោរដោយអំណាចនៃសេចក្តី ស្រឡាញ់ ព្រោះអាស្រ័យផ្ទះ ។ បទថា **ន ឱបសាទេតិ** សេចក្តីថា មិន ពោលពាក្យជាដើមថា ឧបាសក លោកដឹងផ្លូវទៅវិហារហើយឬ លោកមក ព្រោះខ្លាចឬ ។ ភិក្ខុមិនប្ចូន់យករបស់អ្វីទេ លោកកុំខ្លាច ឬថា លោកមាន ជីវិតកំណាញ់ស្វិតស្វាញអ្វីយ៉ាងនេះ ហើយតិះដៀលដោយសេចក្តីស្រឡាញ់

អាស្រ័យផ្ទះ ។ បទថា **វិស្សដ្ឋោ** សេចក្តីថា ជ្រះស្រឡះ គឺ មិនទាស់ ។ បទថា **វិញ្ញេយ្យោ** គឺ គប្បីដឹងបានច្បាស់ប្រាកដ ។ គឺ ព្រះសូរសៀងនោះ ដឹងបានច្បាស់ ព្រោះសំឡេងជ្រះស្រឡះ ។

បទថា **មញ្ជុ** គឺ ពីរោះ ។ បទថា **សវនីយោ** គឺ ស្រួលត្រចៀក ក៏សំឡេងនោះ ឈ្មោះថា គួរស្តាប់ ព្រោះពីរោះនុ៎ះឯង ។ បទថា **ពិន្ទុ** គឺ មូលក្លំ ។ បទថា **អវិសារី** គឺ មិនគ្រាវ មិនបែក ។ ក៏សំឡេងនោះ មិនបែក ព្រោះមានសភាពមូលក្លំនុ៎ះឯង ។ បទថា **គម្ភីរោ** គឺ កើតពីចំណែកជ្រៅ ។ បទថា **និន្នាទី** គឺ មានសភាពកងរំពង ។ ក៏សំឡេងនោះ ឈ្មោះថា មានសភាពកងរំពង ព្រោះកើតពីចំណែកជ្រៅ ។ បទថា **យថា បរិសំ** គឺ រមែងញ៉ាំងបរិស័ទដែលជាប់គន្លា សូម្បីមានចក្រវាឡជាទីបំផុត ឲ្យយល់បាន ។ បទថា **ពហិទ្ធា** សេចក្តីថា រមែងមិនទៅក្រៅអំពីបរិស័ទ សូម្បីមានប្រមាណប៉ុនម្រាមដៃ ។ ព្រោះហេតុអ្វី ព្រោះសំឡេងដ៏ពីរោះបែបនោះ មិនបានសូន្យទៅដោយមិនមានហេតុ ។ សំឡេងរបស់ព្រះមានព្រះភាគ រមែងខ្ចរខ្ចាយទៅដោយទីបំផុតនៃបរិស័ទដោយប្រការ ដូច្នេះ ។

បទថា **អវលោកយមានា** សេចក្តីថា មនុស្សទាំងឡាយដាក់អញ្ជលី

ទុកលើសិរសា ក្រឡេកមើលព្រះមានព្រះភាគ ហើយបែរត្រឡប់មកសំពះ ក្នុងទីដែលនឹងលះការឃើញហើយ ទើបទៅ ។ បទថា **អវិជហន្តា** សេចក្តីថា ក៏បុគ្គលណាស្តាប់ព្រះតម្រាស់ហើយក្រោកឡើង នៅពេលពាក្យដែលបានឃើញ និងបានស្តាប់ជាដើមយ៉ាងដទៃ ទើបទៅ នេះឈ្មោះថា លះទៅដោយការៈរបស់ខ្លួន ។ បុគ្គលណាពោលសរសើរគុណធម្មកថា ដែលបានស្តាប់ហើយទើបទៅ បុគ្គលនេះឈ្មោះថា មិនលះបង់ ឈ្មោះថា រមែងចៀសទៅដោយមិនលះបង់ទៅ ដោយអាការយ៉ាងនេះ ។ បទថា **គច្ឆន្តំ** សេចក្តីថា ស្តេចទៅដូចដុំមាសខ្ពស់ត្រដែតដល់ ១០០ ហត្ថ ដោយអំណាចនៃវិស្សយន្ត ។ បទថា **អទ្ទសាមបិតំ** សេចក្តីថា យើងបានឃើញព្រះអង្គប្រថាប់ឈរ ដូចជាក្អមមាសដែលគេលើកឡើងតាំងទុក ។

បទថា **តតោ ច ភិយ្យោ** សេចក្តីថា កាលមិនអាចនឹងពោលគុណឲ្យពិស្តារ ទើបសង្ខេបគុណដ៏សេស ធ្វើដូចបំពង់ព្រួញ ទើបពោលយ៉ាងនោះ រកទីបំផុតមិនមាន រកប្រមាណមិនបាន ។ ក្នុងសេចក្តីនេះ មានអធិប្បាយដូចតទៅនេះ ៖

ព្រះគុណរបស់ព្រះគោតមដ៏ចម្រើននោះ មិនទាន់បានពោល មាន

ច្រើនជាងគុណដែលខ្ញុំពោលហើយ ប្រៀបដូចមហាប្រថពី និងមហាសមុទ្រជាដើម រកទីបំផុតមិនបាន រកប្រមាណមិនបាន ធំទូលាយដូចជាអាកាសដូច្នោះឯង ។

[៩] បទថា *អប្បដិសំវិទិតោ* សេចក្ដីថា ការមកដោយមិនបានទូលឲ្យទ្រង់ជ្រាប ។

អ្នកនឹងចូលទៅរកបព្វជិត ចូលទៅរកក្នុងវេលាដែលបរិកម្មចីវរជាដើម ឬក្នុងវេលាដែលស្លៀកសំពត់ផ្ទាំងតែមួយកំពុងពត់សរីរៈ ក៏នឹងត្រូវថយត្រឡប់អំពីហេតុនោះតែម្ដង ។ សូម្បីការបដិសណ្ឋារៈ ក៏នឹងមិនកើតឡើង ។ តែកាលឱកាសលោកធ្វើមុនហើយ កិច្ចបោសសម្អាតដែលសម្រាកក្នុងពេលថ្ងៃ ដណ្ដប់ចីវរអង្គុយក្នុងទីស្ងាត់ ។ អ្នកដែលមកឃើញហើយក៏នឹងជ្រះថ្លាសូម្បីដោយការឃើញលោក ការបដិសណ្ឋារៈក៏នឹងកើតឡើង ។ ក៏នឹងបានទាំងបញ្ហាព្យាករណ៍ ទាំងធម្មកថា ។ ព្រោះដូច្នោះ បណ្ឌិតទាំងឡាយ ទើបត្រូវវេចាំឱកាស ។ នោះក៏ជាឱកាសយ៉ាងណាមួយរបស់អ្នកទាំងនោះ ។ ព្រោះដូច្នោះ គេទើបមានសេចក្ដីគិតយ៉ាងនោះ ។ ព្រហ្មាយុ-ព្រាហ្មណ៍ មិនពោលដល់សភាពនៃខ្លួនជាអ្នកខ្ពស់ជាដើម ពោលយ៉ាងនេះ

ថា **ជិណ្ណោ វុឌ្ឍោ** ព្រោះហេតុអ្វី ។ ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់មានព្រះករុណា កាលទ្រង់ជ្រាបថា ជាមនុស្សចាស់ហើយ នឹងប្រទានឱកាសឲ្យដោយរហ័ស ដូច្នោះ ទើបពោលយ៉ាងនោះ ។

**[១១]** បទថា **ឱរមត្ត ឱកាសមកាសិ** សេចក្តីថា បរិស័ទនោះប្រញាប់ក្រោកឡើងចែកចេញជា ២ ចំណែក ឲ្យឱកាស ។ បទថា **យេ មេ** ស្មើនឹង **យេ មយា** ។ បទថា **នាវីសមានសន្នាយា** សេចក្តីថា មានឈ្មោះស្មើដោយនារីជាស្ត្រីភេទ ឈ្មោះថា **នាវីសមានសន្នាយា** ព្រោះអត្ថថា ហៅតាមភេទនៃស្ត្រីនោះ គប្បីពោលតាមភេទនៃស្ត្រី ដូច្នោះ លោកទើបពោលយ៉ាងនេះព្រោះជាអ្នកច្លាតក្នុងវោហារ ។ បទថា **បហុតជិវ្ហោ** បានដល់ មានព្រះជិវ្ហាធំ ។ បទថា **និន្នាមយេតំ** ប្រែថា សូមព្រះអង្គមេត្តានាំព្រះលក្ខណៈនោះចេញ ។

**[១២]** បទថា **កេវលី** គឺ ទ្រង់សម្បូរណ៍ ដោយព្រះគុណទាំងអស់ ។

**[១៤]** បទថា **បច្ចភាសិ** សេចក្តីថា កាលត្រូវសួរត្រឹមតែមួយ ទ្រង់ក៏ព្យាករណ៍ គឺ បានត្រាស់ឆ្លើយបញ្ហាដល់ ៨ ប្រការ ។ បទថា **យោ វេទី** សេចក្តីថា នរណាដឹង គឺ ជ្រាបកពជាទីនៅអាស្រ័យក្នុងកាលមុន របស់

អ្នកណាប្រាកដហើយ ។ បទថា **សគ្គាបាយញ្ច បស្សតិ** សេចក្តីថា លោក ពោលដល់ទិព្វចក្ខុញ្ញាណ ។ បទថា **ជាតិក្ខយំ បត្តោ** បានដល់ សម្រេច ព្រះអរហត្តហើយ បទថា **អភិញ្ញាវោសិតោ** បានដល់ ដឹងក្រៃលែងហើយ ដោយព្រះអរហត្តនោះ សម្រេចកិច្ចហើយ គឺ ដល់ទីបំផុតហើយ ។ បទថា **មុនី** បានដល់ អ្នកប្រកបដោយធម៌ជាមុនី គឺ អរហត្តញ្ញាណ ។

បទថា **វិសុទ្ធំ** បានដល់ ភាពថ្លាផូរផង់ ។ បទថា **មុត្តំ រាគេហិ** សេចក្តីថា ផុតអំពីរាគកិលេសទាំងឡាយ ។ បទថា **បហីនជាតិមរណោ** បានដល់ ឈ្មោះថា អ្នកលះបង់ការកើតបាន ព្រោះដល់ការអស់ទៅនៃជាតិហើយ ឈ្មោះថា អ្នកលះមរណៈបានហើយ ព្រោះលះជាតិបានទុះឯង ។

បទថា **ព្រហ្មចរិយស្ស កេវលី** សេចក្តីថា អ្នកប្រកបដោយគុណនៃព្រហ្មចារ្យទាំងអស់ សំដៅសេចក្តីថា អ្នកមានប្រក្រតីប្រព្រឹត្តព្រហ្មចរិយៈ គឺ មគ្គ ៤ ទាំងនោះឯង ។

បទថា **បារគូ សព្វធម្មានំ** សេចក្តីថា អ្នកដល់ត្រើយដោយសេចក្តីដឹងក្រៃលែងនូវលោកិយធម៌ និងលោកុត្តរធម៌ទាំងពួង អធិប្បាយថា ដឹងក្រៃលែងដល់ធម៌ទាំងពួង ។ ន័យម្យ៉ាងទៀត បទថា **បារគូ** លោកពោល

អត្ថទុកដូច្នេះថា អ្នកដល់នូវត្រើយដោយការកំណត់ដឹងខន្ធ ៥ អ្នកដល់ត្រើយដោយការលះកិលេសទាំងពួង អ្នកដល់ត្រើយដោយការនាំនូវមគ្គ ៤ អ្នកដល់ត្រើយដោយការធ្វើឲ្យច្បាស់នូវនិរោធ អ្នកដល់ត្រើយ ដោយការដល់ព្រមនូវសមាបត្តិទាំងពួង ដោយពាក្យត្រឹមតែប៉ុណ្ណោះ ។ លោកពោលការដល់ត្រើយដោយអភិញ្ញា ដោយពាក្យថា ធម៌ទាំងពួងទៀត ។ បទថា **ពុទ្ធោ តាទី បវុច្ចតិ** សេចក្តីថា បុគ្គលដូច្នោះ គឺ អ្នកដល់ត្រើយ ដោយអាការ ៦ លោកហៅថា ព្រះពុទ្ធ ព្រោះជាអ្នកត្រាស់ដឹងហើយនូវសច្ចធម៌ទាំង ៤ ដោយអាការទាំងពួង ។

ក៏បញ្ហា ដែលព្រះមានព្រះភាគ ទ្រង់វិសជ្ជនាហើយដោយព្រះតម្រាស់ត្រឹមតែប៉ុណ្ណោះឬ ។ ត្រូវហើយ ជាការវិសជ្ជនាស្រេចគ្រប់ប្រការ ។ គឺ ទ្រង់វិសជ្ជនាបញ្ហាប្រការទីមួយ ព្រោះជាអ្នកមានបាបដែលបន្សាត់ចេញហើយឈ្មោះថា ព្រាហ្មណ៍ ដោយព្រះតម្រាស់ថា មុនីនោះ ដឹងចិត្តដែលបរិសុទ្ធិដែលរួចផុតហើយចាករាគៈទាំងឡាយ ដូច្នេះ ។

ដោយព្រះតម្រាស់ថា ដល់ត្រើយ ឈ្មោះថា ដល់វេទ ព្រោះចប់វេទហើយនេះ រមែងជាការវិសជ្ជនាបញ្ហាប្រការទីពីរ ។ ដោយបទជាដើមថា

*បុព្វេនិវាសំ ឈ្មោះថា អ្នកមានវិជ្ជាបី ព្រោះមានវិជ្ជាបីទាំងនេះ រមែងជាការវិសជ្ជនាបញ្ហាប្រការទីបី ។ ដោយព្រះតម្រាស់នេះថា ផុតចាករាគៈទាំងឡាយដោយប្រការទាំងពួង នេះឈ្មោះថា អ្នកមានសេចក្ដីស្អស្អី ព្រោះលះបាបធម៌ចេញបាន រមែងជាការវិសជ្ជនាបញ្ហាប្រការទីបួន ។ម្យ៉ាងទៀត ដោយព្រះតម្រាស់នេះថា សម្រេចដល់ការអស់ជាតិ នេះឈ្មោះថា រមែងជាការវិសជ្ជនាបញ្ហាប្រការទី ៥ ព្រោះត្រាស់ដល់ព្រះអរហត្តនោះឯង ។ រមែងជាការវិសជ្ជនាបញ្ហាប្រការទី ៦ ដោយព្រះតម្រាស់ទាំងនេះ គឺថា ជាអ្នកសម្រេចកិច្ចហើយ និងថា ឈ្មោះថា អ្នកមាននូវព្រហ្មចរិយៈបរិបូរណ៍ ។ ដោយព្រះតម្រាស់នេះថា អ្នកនោះឈ្មោះថា មុនី អ្នកដឹងក្រៃលែងដល់ទីបំផុតហើយ រមែងជាការវិសជ្ជនាបញ្ហាប្រការទី ៧ ដោយព្រះតម្រាស់នេះថា ឈ្មោះថា ដល់ត្រើយនៃធម៌ទាំងពួង បណ្ឌិតពោលថា ព្រះពុទ្ធ ជាតាទិបុគ្គល រមែងជាការវិសជ្ជនាបញ្ហាប្រការទី ៨ ។ បទថា* ***ទានកថំ*** *ជាដើម លោកឲ្យពិស្ដារហើយក្នុងព្រះសូត្រមុននោះឯង ។ បទថា* ***បានសម្រេច*** *គឺ ដល់ចំពោះហើយ ។*

**[២០]** *បទថា* ***ធម្មំ សានុធម្មំ*** *សេចក្ដីថា អរហត្តមគ្គ ឈ្មោះថា*

ធម៌ក្នុងព្រះសូត្រនេះ មគ្គ ៣ និងសាមញ្ញផល ៣ ខាងក្រោម ឈ្មោះ អនុធម៌ សមគួរដល់ធម៌ អធិប្បាយថា បានមគ្គ និងផលទាំងនោះ តាមលំដាប់ ។ ប្រការថា មិនបៀតបៀនយើងឲ្យលំបាក ព្រោះហេតុនៃធម៌ឡើយ សេចក្តីថា មិនញុាំងយើងឲ្យលំបាក ព្រោះហេតុនៃធម៌ឡើយ អធិប្បាយថា មិនឲ្យយើងពោលរឿយៗ ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ទាំងអស់ ។ ក៏ដោយបទថា **បរិនិព្វាយិ** ក្នុងបទនោះ ព្រះអង្គទ្រង់កាន់យកកំពូលនៃទេសនាដោយព្រះអរហត្តតែម្យ៉ាង ។

“ ចប់អដ្ឋកថា ព្រហ្មាយុសូត្រទី ១ ”

# អ ដ្ឋ ក ថា

## សេលសូត្រទី ២

[២១] *សេលសូត្រ មានពាក្យផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ៖*

*ក្នុងសេលសូត្រនោះ ពាក្យថា **ក្នុងអង្គុត្តរាបជនបទ** ជាដើម លោកពោលឲ្យពិស្ដារហើយក្នុងបោតលិយសូត្រនោះឯង ។ បទថា **អឌ្ឍតេរសេហិ** បានដល់ ១៣ កន្លះ លោកពោលអធិប្បាយថា ព្រមទាំងភិក្ខុ ១,២៥០ រូប ។ ក៏ភិក្ខុទាំងឡាយ ដែលប្រជុំគ្នាក្នុងសាវកសន្និបាតនោះ សុទ្ធតែជាព្រះខីណាស្រព បព្វជ្ជាដោយឯហិភិក្ខុបព្វជ្ជាទាំងអស់ ។ ពាក្យថា **កេណិយោ** ជាឈ្មោះរបស់ជដិលនោះ ។ ពាក្យថា **ជដិលោ** បានដល់ តាបស ។*

*បានឮមកថា តាបសនោះជាព្រាហ្មណ៍មហាសាល តែបួសជាតាបសដើម្បីត្រូវការរក្សាទ្រព្យ ថ្វាយបណ្ណាការចំពោះព្រះរាជា កាន់យកភូមិភាគមួយកន្លែង សាងអាស្រមនៅក្នុងភូមិភាគនោះ ប្រកបការធ្វើជំនួញដោយរទេះ ៥០០ ជាទីអាស្រ័យរបស់ត្រកូល ១,០០០ ត្រកូល ។ មយ៉ាងទៀត*

ព្រះបុរាណាចារ្យពោលថា ទីអាស្រមរបស់តាបសនោះ មានដើមត្នោតមួយដើម ផ្លែត្នោតសម្រេចដោយមាស ជ្រុះមកមួយថ្ងៃមួយផង ៗ តាបសនោះពេលថ្ងៃស្លៀកដណ្ដប់សំពត់កាសាយៈ និងពាក់ជដា ពេលយប់សោយកាមសម្បត្តិ ។

**[២២]** ពាក្យថា **ធម្មិយា កថាយ** បានដល់ ដោយធម្មីកថា ដែលប្រកបដោយអានិសង្សនៃទឹកបានៈ ។ ក៏កេណិយៈនេះ ខ្មាស់ត្រង់មានដៃទទេ ទៅគាល់ព្រះមានព្រះភាគ គិតថា ទឹកសម្រាប់ផឹករមែងគួរស្មើដល់អ្នកវៀរវិកាលភោជន ទើបឲ្យរែកទឹកបានៈផ្លែពុទ្រា ដែលផ្សំជាយ៉ាងល្អមក ៥០០ អម្រែក ។ ក៏រៀងដែលជដិលនោះទៅហើយ ដូច្នេះ ។ ព្រះសង្គីតិកាចារ្យលើកឡើងកាន់ព្រះបាលីក្នុងភេសជ្ជក្ខន្ធកៈថា គ្រានោះឯង កេណិយជដិល បានគិតដូច្នេះថា យើងគួរនាំទៅដើម្បីព្រះសមណគោតមឬទេហ្ន៎ ដូច្នេះ ។ ពាក្យថា **ទុតិយំបិ ខោ ភគវា** សួរថា ទ្រង់បដិសេធរឿយៗ ព្រោះហេតុអ្វី ។

ឆ្លើយថា ព្រោះពួកតិរ្ថិយមានសេចក្ដីជ្រះថ្លាក្នុងការបដិសេធ ។ ប្រការនោះមិនមែនជាហេតុ ការកុហកបែបនេះ រមែងមិនមានដល់ព្រះពុទ្ធទាំងឡាយព្រោះបច្ច័យជាហេតុ ។ តែតាបសនេះឃើញភិក្ខុ ១,២៥០ រូប ចាត់ចែងភិក្ខា

ដើម្បីភិក្ខុមានប្រមាណប៉ុណ្ណោះឯង ។ ថ្ងៃស្អែក សេលព្រាហ្មណ៍នឹងចេញបួសជាមួយនឹងបុរស ៣០០ ។ ឯតថាគត នឹងបញ្ជូនភិក្ខុនវកៈទៅផ្លូវដទៃ ហើយទៅជាមួយនឹងភិក្ខុទាំងនេះប៉ុណ្ណោះ ឬថា បញ្ជូនភិក្ខុទាំងនេះទៅផ្លូវដទៃ ហើយទៅជាមួយនឹងភិក្ខុនវកៈទាំងឡាយមិនគួរ ។ ប្រសិនបើ តថាគតនាំភិក្ខុទាំងអស់ទៅ ភិក្ខាហារក៏នឹងមិនល្មម ។

តពីនោះ កាលភិក្ខុទាំងឡាយត្រាច់ទៅដើម្បីបិណ្ឌបាត មនុស្សទាំងឡាយនឹងតិះដៀលថា យូរណាស់កេណិយៈ និមន្តព្រះសមណគោតម តែមិនអាចនឹងថ្វាយអាហារឲ្យល្មមញ៉ាំងអត្តភាពប្រព្រឹត្តទៅបាន ។ កេណិយៈខ្លួនឯងនឹងមានសេចក្តីក្តៅក្រហាយ ។ តែកាលទ្រង់ធ្វើការបដិសេធ កេ-ណិយៈក៏នឹងគិតថា ព្រះសមណគោតមនឹងកាន់យកឈ្មោះរបស់ព្រាហ្មណ៍ទាំងឡាយរឿយៗ ថា ក៏ខ្លួនលោកជ្រះថ្លាក្រៃលែងក្នុងពួកព្រាហ្មណ៍ហើយប្រាថ្នានឹងនិមន្តសូម្បីពួកព្រាហ្មណ៍ផង បន្ទាប់ពីនោះ ព្រាហ្មណ៍ក៏នឹងនិមន្តដោយឡែកវិញ ។ ភិក្ខុទាំងនោះ ដែលព្រាហ្មណ៍នោះនិមន្តហើយ ក៏នឹងឆាន់ដោយអាការយ៉ាងនេះ នឹងជាការរក្សាសទ្ធារបស់ព្រាហ្មណ៍នោះទុក ដូច្នោះទើបទ្រង់បដិសេធរឿយៗ ។ ដោយពាក្យថា **ភិញ្ចាបិ ភោ** នេះ រមែងសម្តែង

ដល់ប្រការនេះថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីកើតឡើង ប្រសិនបើថា ខ្ញុំព្រះអង្គជ្រះថ្លាក្រៃលែងហើយក្នុងព្រាហ្មណ៍ទាំងឡាយ បពិត្រព្រះគោតមដ៏ចម្រើន សូមទ្រង់ទទួលនិមន្ត ខ្ញុំព្រះអង្គអាចថ្វាយសូម្បីដល់ព្រាហ្មណ៍ ទាំងដល់ព្រះអង្គ ។ បទថា **កាយវេយ្យាវត្តិកំ** បានដល់ ការខ្វល់ខ្វាយដោយកាយ ។

បទថា **មណ្ឌមាឡំ** បានដល់ មណ្ឌបដែលធ្វើដោយសំពត់ ។

**[២៣]** បទថា **អាវាហ** បានដល់ ការទទួលកូនក្រមុំមក ។ បទថា **វិវាហ** បានដល់ ការបញ្ជូនកូនក្រមុំទៅ ។ ពាក្យថា **សោ មេ និមន្តិតោ** សេចក្ដីថា ព្រះសមណគោតមនោះ យើងនិមន្តហើយ ។ គ្រានោះ ព្រាហ្មណ៍ពេលបានស្ដាប់ថា ពុទ្ធ: ដូចជាអ្នកស្រោចហើយដោយទឹកអម្រឹត ព្រោះជាអ្នកមានឧបនិស្ស័យចាស់ក្លាហើយ ។ កាលនឹងធ្វើឲ្យច្បាស់នូវសេចក្ដីជ្រះថ្លា ទើបពោលថា ម្នាលកេណិយ: អ្នកពោលថា **ពុទ្ធោ** ឬ ។ កេណិយ: កាលនឹងប្រាប់តាមសេចក្ដីពិត ទើបពោលថា បពិត្រសេល: ខ្ញុំពោលថា **ពុទ្ធោ** ។ តពីនោះ សេលព្រាហ្មណ៍ ទើបសួរកេណិយព្រាហ្មណ៍នោះទៀត ដើម្បីឲ្យជាក់ច្បាស់ ។ សូម្បីកេណិយ:នេះ ក៏ពោលយ៉ាងនោះនោះឯង ។

គ្រានោះ កាលព្រាហ្មណ៍ឃើញថា សំឡេងថា ពុទ្ធោ ដែលបុគ្គលគប្បីបាន ដោយលំបាកសូម្បីដោយពាន់នៃកប្ប ទើបមានការគិតយ៉ាងនោះ គឺ មាន ការគិតយ៉ាងនេះថា សូម្បីសំឡេងនោះឯងជាដើម ។

[២៤] បទថា **នីលវនរាជី** បានដល់ ជួរដើមឈើមានពណ៌ខៀវ ។ ពាក្យថា **បទេ បទំ** គឺ ជើងដែលឈានទៅតាមធម្មតា កាលឈានជិតពេក ឬឆ្ងាយពេក សំឡេងនឹងខ្លាំងឡើង កាលនឹងហាមមិនឲ្យមានសំឡេងខ្លាំង នោះ ទើបពោលយ៉ាងនោះ ។ ពាក្យថា **សីហាវ ឯកចរា** សេចក្តីថា សីហៈ មានប្រក្រតីនៅជាពួក រមែងមានសេចក្តីប្រមាទដោយកូនសីហៈតូចៗ ជាដើម ។ ត្រាច់ទៅតែម្នាក់ឯង ក៏ជាអ្នកមិនប្រមាទ ។ កាលនឹងសម្តែងការនៅដោយ សេចក្តីមិនប្រមាទ ទើបធ្វើការប្រៀបធៀបដោយសីហៈដែលត្រាច់ទៅតែម្នាក់ ឯង ដោយប្រការដូច្នេះ ។ កាលនឹងឲ្យសិក្សាអាចារៈ ទើបពោលថា **មា មេ ភោន្តោ** ។

ក្នុងពាក្យនេះមានអធិប្បាយដូចតទៅនេះ ៖

បើលោកមិនបានវារៈដែលនឹងនិយាយ ស៊កពាក្យចូលទៅក្នុងចន្លោះ ពាក្យរបស់យើង ការរិះគន់ក៏នឹងកើតឡើងដល់យើងថា មិនអាចឲ្យអន្តេវាសិក

សិក្សាបានដូច្នេះ ព្រោះដូច្នោះ ឃើញឱកាសហើយទើបនិយាយខ្សិបៗ ។

[២៦] ពាក្យថា **នោ ច ខោ នំជានាមិ** សេចក្តីថា សូម្បីព្រះពោធិ-សត្វព្រះនាមថា វិបស្សី មានបព្វជិតត្រូវៈដល់ ៨៤,០០០ ជាបរិវារ ទ្រង់ប្រព្រឹត្តពេលនៅជាព្រះពោធិសត្វដល់ ៧ ខែ ក៏បានត្រាស់ដឹង ដូចជាពុទ្ធុប្បាទកាល ។ សូម្បីព្រះពោធិសត្វរបស់ពួកយើង ទ្រង់ប្រព្រឹត្តកាលនៅជាព្រះពោធិសត្វរហូតអស់ ៦ ឆ្នាំ ។ សូម្បីអ្នកដែលប្រកបព្រមហើយដោយលក្ខណៈនៃសរីរៈ ដែលបរិបូរណ៍យ៉ាងនេះ ក៏មិនទាន់ជាព្រះពុទ្ធ ព្រោះដូច្នោះ ព្រាហ្មណ៍ទើបពោលថា យើងមិនដឹងព្រះពុទ្ធអង្គនោះ ដូច្នេះ ។ បទថា **បរិបុណ្ណកាយោ** សេចក្តីថា ជាអ្នកមានសរីរៈបរិបូណ៌ ព្រោះភាពបរិបូណ៌ដោយលក្ខណៈទាំងឡាយ និងមានអវយវៈមិនថោកថយ ។ បទថា **សុរុចិ** សេចក្តីថា មានរស្មីនៃព្រះសរីរៈល្អ ។ បទថា **សុជាតោ** បានដល់ កើតល្អហើយ ដោយការដល់ព្រមនៃកម្ពស់ ទំហំ និងដល់ព្រមដោយទ្រង់ទ្រាយ ។ បទថា **ចារុទស្សនោ** បានដល់ ការមើលយូរៗ ក៏ញុំាងចិត្តឲ្យមើលមិនចេះឆ្អែតឆ្អន់ ។ បទថា **សុវណ្ណវណ្ណោ** គឺ មានសម្បុរដូចមាស ។ បទថា **សុសុក្កទាឋោ** បានដល់ មានព្រះចង្កូមសស្អាត ។ បទថា

មហាបុរិសលក្ខណៈ សេចក្ដីថា កាលនឹងពោលដដែល ព្យញ្ជនៈដែលដឹង ហើយមុនដំបូងដោយពាក្យដទៃ ទើបពោលយ៉ាងនោះ ។ ឥឡូវនេះ សេល-ព្រាហ្មណ៍ កាលកាន់យកលក្ខណៈដែលពេញចិត្តរបស់ខ្លួន ក្នុងបណ្ដាលក្ខណៈទាំងនោះ ហើយសរសើរ ទើបពោលពាក្យមានជាដើមថា មានព្រះនេត្រថ្លាផូរផង់ជាដើម ។

ពិតណាស់ ព្រះមានព្រះភាគ ឈ្មោះថា មានព្រះទ័យផូរផង់ ព្រោះទ្រង់បរិបូរណ៍ដោយប្រសាទ ៥ យ៉ាង ឈ្មោះថា មានព្រះភ័ក្ត្រស្រស់បោះ ព្រោះមានព្រះភ័ក្ត្រដូចព្រះចន្ទពេញវង់ ។ ឈ្មោះថា ជាអ្នកស្រស់ល្អ ព្រោះបរិបូរណ៍ដោយទ្រង់ទ្រាយ មិនខ្ពស់ពេក ។ មិនទាបអ្នក មិនស្គម មិនធាត់ ។ ឈ្មោះថា មានព្រះកាយត្រង់ ព្រោះមានអវយវៈត្រង់ដូចព្រហ្ម ។ ឈ្មោះថា ជាអ្នកមានព្រះរស្មី ព្រោះទ្រង់មានភាពរុងរឿង ។ មួយវិញទៀត ព្រះលក្ខណៈយ៉ាងណា ក្នុងទីនេះដែលបានពោលទុកមុនហើយ ព្រះលក្ខណៈយ៉ាងនោះដែលសេលព្រាហ្មណ៍ ពោលសរសើរទុកទៀត ដោយបរិយាយនេះថា ទ្រង់ស្រស់ល្អត្រង់កណ្ដាលពួកសមណៈ ដូច្នេះ ។ ចំណែកបុគ្គលដូច្នេះ រមែងរុងរឿងដោយប្រការដូចពោលមកនេះ ។ សូម្បីក្នុងគាថាក្រោយក៏ន័យនេះ

ដូចគ្នា ។ បទថា **ឧត្តមវណ្ណិនោ** បានដល់ ទ្រង់ដល់ព្រមវណ្ណដ៏ឧត្តម ។

បទថា **រថេសភោ** បានដល់ ទ្រង់ជាសារថីដ៏ប្រសើរ ។ បទថា **ជម្ពុសណ្ឌស្ស** បានដល់ នៃជម្ពូទ្វីប ។ កាលនឹងសរសើរនូវភាពជាឥស្សរៈ ។ ដោយអាការដែលប្រាកដ ទើបពោលហើយ ។

ក៏ស្តេចចក្រពត្តិ ទ្រង់ជាឥស្សរៈនៃទ្វីបទាំងបួន ។ បទថា **ខត្តិយា** គឺ ជាតិជាក្សត្រិយ៍ ។ បទថា **ភោគា** គឺ ជាអ្នកមានភោគៈ ។ បទថា **រាជានោ** បានដល់ ព្រះរាជាអង្គណាមួយទ្រង់គ្រងរាជ្យ ។

បទថា **រាជាភិរាជា** បានដល់ ជាអ្នកដែលព្រះរាជាទាំងឡាយទ្រង់បូជា អធិប្បាយថា ជាព្រះរាជាដ៏ធំក្រៃលែង គឺ ស្តេចចក្រពត្តិ ។ បទថា **មនុជិន្ទោ** គឺ ជាអ្នកធំក្រៃលែងក្នុងពួកមនុស្ស អ្នកមានឥស្សរៈយ៉ាងក្រៃលែង ។

កាលសេលព្រាហ្មណ៍ពោលយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា ព្រះអរហន្តសម្មាសម្ពុទ្ធ រមែងធ្វើព្រះអង្គឲ្យប្រាកដចំពោះអ្នកពោលគុណរបស់ខ្លួន កាលនឹងញុំាងមនោរថរបស់សេលព្រាហ្មណ៍នេះឲ្យពេញ ទើបត្រាស់ពាក្យជាដើមថា តថាគតជារាជា ដូច្នេះ ។ ក្នុងព្រះតម្រាស់នោះ

មានពាក្យអធិប្បាយដូចតទៅនេះ ៖

ម្នាលសេល អ្នកពោលអង្វរនឹងតថាគតថា ព្រះអង្គគួរនឹងជាព្រះរាជា ដូច្នេះ ។ សូមអ្នកមានសេចក្តីខ្វល់ខ្វាយតិចក្នុងសេចក្តីនេះចុះ តថាគតជាព្រះរាជា កាលជាព្រះរាជាហើយ ឧបមាថា ព្រះរាជាដទៃទ្រង់គ្រប់គ្រងរយយោជន៍ខ្លះ ពាន់យោជន៍ខ្លះ ។

សូម្បីស្តេចចក្រពត្តិ ក៏ទ្រង់គ្រប់គ្រងត្រឹមតែផែនដី មានមហាសមុទ្រ ៤ ជាព្រំដែន តែតថាគតមិនមានព្រំដែនកំណត់ឡើយ ។ គឺ តថាគតជាព្រះធម្មរាជា មិនមានព្រះរាជាដទៃក្រៃលែងជាង គ្រប់គ្រងលោកធាតុដែលរកប្រមាណមិនបាន ដោយចំណែកទទឹងតាំងពីភវគ្គព្រហ្មចុះមកដល់អវិចីជាទីបំផុត ។ ក៏សត្វទាំងឡាយផ្សេងៗ សូម្បីមិនមានជើង មានជើង ២ ជាដើម មានប្រមាណត្រឹមណា តថាគតជាអ្នកប្រសើរជាងសត្វទាំងឡាយនោះ ។ មិនមានអ្នកណាៗ មានចំណែកប្រៀបផ្ទឹមដោយសីល ។ល។ ឬដោយវិមុត្តិញ្ញាណទស្សនៈរបស់តថាគត ។ តថាគតនោះឯងជាព្រះធម្មរាជាដ៏កំពូលឆ្នើម ញុំាងធម្មចក្កដែលមានសតិប្បដ្ឋានបួនជាដើម ដ៏កំពូលពិតៗ ។ តថាគតបានអាណាចក្រថា នេះអ្នកចូរលះ នេះអ្នកគប្បីចូលដល់ ឬញុំាង

ធម្មចក្កដោយបរិយត្តិធម៌ជាដើមថា ម្នាលភិក្ខុទាំងឡាយ នេះឯងជា ទុក្ខ-អរិយសច្ចៈ ។ បទថា **ចក្កំ អប្បដិវត្តិយំ** សេចក្តីថា ចក្កដែលសមណៈ ។ល។ ឬនរណាៗ ក្នុងលោកឲ្យប្រព្រឹត្តមិនបាន ។

សេលព្រាហ្មណ៍ ឃើញព្រះមានព្រះភាគ ទ្រង់បើកបង្ហាញព្រះអង្គ ដោយប្រការដូច្នេះ ទើបកើតបីតិសោមនស្ស ដើម្បីនឹងធ្វើឲ្យមុតមាំទៀត ទើបពោល ២ គាថាថា លោកបញ្ជាក់ថា **សម្ពុទ្ធោ បដានាសិ** ដូច្នេះ ជាដើម ។ ក្នុងបទទាំងនោះ ដោយពាក្យថា **កោ នុ សេនាបតិ** (នរណាហ្ន៎ ជាសេនាបតី) សេលព្រាហ្មណ៍ទូលសួរថា កាលបើព្រះអង្គជាព្រះធម្មរាជា ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅហើយ នរណាជាសេនាបតីញុំាងចក្កឲ្យប្រព្រឹត្តទៅតាម ។

ក៏សម័យនោះ ព្រះសារីបុត្រ អង្គុយនៅខាងស្តាំព្រះមានព្រះភាគ ល្អដោយសិរីដូចដុំមាស ។ ព្រះមានព្រះភាគកាលនឹងទ្រង់ចង្អុលព្រះសារី-បុត្រនោះ ទើបត្រាស់គាថាថា **មយា បវត្តិតំ** ជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **អនុជាតោ តថាគតំ** សេចក្តីថា អ្នកកើត ព្រោះតថាគតជាហេតុ បានសេចក្តីថា អ្នកកើតតាម ព្រោះហេតុព្រះតថាគត ។ មយ៉ាងទៀត បុត្រ

៣ ពួក គឺ អនុជាតបុត្រ អវជាតបុត្រ អតិជាតបុត្រ ។ ក្នុងបុត្រទាំងនោះ **អវជាតបុត្រ** ជាអ្នកទ្រុស្តសីល គេមិនឈ្មោះថា ជាបុត្ររបស់ព្រះតថាគត ។ អ្នកដែលក្រៃលែងជាងបិតា ឈ្មោះថា **អតិជាតបុត្រ** ។ បុត្រសូម្បីនោះ របស់ព្រះតថាគតមិនមាន ។ តែព្រះតថាគតមានអនុជាតបុត្រតែពួកមួយ ប៉ុណ្ណោះ ។ កាលទ្រង់ចង្អុលបុត្រនោះ ទើបត្រាស់យ៉ាងនោះ ។

កាលព្យាករណ៍បញ្ហាថា អ្នកណាជាសេនាបតី យ៉ាងនេះហើយ ដែល សេលព្រាហ្មណ៍ពោលថា **សម្ពុទ្ធោ បជានាសិ** ព្រះមានព្រះភាគទ្រង់ប្រាថ្នា នឹងធ្វើព្រាហ្មណ៍នោះឲ្យអស់សង្ស័យ ព្រោះហេតុនោះ ទើបត្រាស់គាថាថា **អភិញ្ញេយ្យំ** ជាដើម ដើម្បីសម្តែងឲ្យព្រាហ្មណ៍ជ្រាបថា តថាគតមិនបាន បេ្តជ្ញាដោយអាការត្រឹមតែទទួលដឹងប៉ុណ្ណោះ ប៉ុន្តែថា តថាគតជាព្រះពុទ្ធ ព្រោះហេតុនេះ ។ ក្នុងគាថានោះ ពាក្យថា **អភិញ្ញេយ្យំ** ជាដើម បានដល់ វិជ្ជា វិមុត្តិ មគ្គសច្ចដែលគួរចម្រើន និងសមុទយសច្ចដែលគួរលះបង់ ។ មយ៉ាងទៀត សូម្បីនិរោធសច្ច និងទុក្ខសច្ច ដែលជាផលនៃសច្ចៈទាំងនោះ រមែងជាការត្រាស់ហើយតែម្យ៉ាង ព្រោះផលសម្រេចដោយការពោលដល់ ហេតុ ។ ពាក្យនេះថា តថាគតបានធ្វើឲ្យជាក់ច្បាស់នូវវត្ថុដែលគប្បីធ្វើឲ្យ

ជាក់ច្បាស់ បានកំណត់ដឹងវត្ថុដែលគប្បីកំណត់ដឹងហើយយ៉ាងនេះ ព្រះ-មានព្រះភាគទ្រង់សង្គ្រោះទុកក្នុងទីនេះឯង ។ កាលទ្រង់សម្តែងសច្ចៈ ៤ ភាវនា ផល និងវិមុត្តិ ទ្រង់ញ៉ាំងពុទ្ធដោយសភាវៈឲ្យសម្រេច ដោយហេតុដ៏សមគួរថា **តថាគតបានដឹងធម៌ដែលគប្បីដឹង ជាព្រះពុទ្ធហើយ** ដូច្នេះ ។ ព្រះមានព្រះភាគ កាលបើកបង្ហាញព្រះអង្គដោយនិប្បរិយាយ យ៉ាងនេះហើយ កាលនឹងញ៉ាំងព្រាហ្មណ៍ឲ្យឈានចុះដ៏ក្រៃលែង ដើម្បីឆ្លងសេចក្តីសង្ស័យក្នុងព្រះអង្គ ទើបត្រាស់ពីរគាថាថា **វិនយស្សុ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **សល្លកត្តោ** បានដល់ អ្នកដកកូនសរ គឺ រាគៈជាដើមបានហើយ ។ បទថា **អនុត្តរោ** សេចក្តីថា រោគខាងក្រៅដែលពេទ្យព្យាបាលឲ្យជាហើយ នៅកម្រើកបានក្នុងអត្តភាពនេះ យ៉ាងណា តែរោគដែលតថាគតព្យាបាលឲ្យជាហើយ មិនមែនដូច្នោះ រមែងមិនកើតឡើងក្នុងភពដទៃទៀត ។ ព្រោះដូច្នោះ តថាគតទើបជាអ្នកមិនមានរោគក្រៃលែងជាង ។ បទថា **ព្រហ្មភូតោ** បានដល់ ជាអ្នកប្រសើរ ។ បទថា **អតិតុលោ** (ប្រៀបផ្ទឹមមិនបាន) គឺ កន្លងការប្រៀបធៀប មានសេចក្តីថា ប្រៀបផ្ទឹមមិនបាន ។

បទថា **មារសេនប្បមទ្ទនោ** សេចក្ដីថា ទ្រង់ញាំញីមារ និងសេនាមារ ដែលមកហើយយ៉ាងនេះថា កាមទាំងឡាយជាសេនាទី ១ របស់អ្នក ។ បទថា **សព្វាមិត្តេ** បានដល់ សត្រូវទាំងពួង ពោលគឺ ខន្ធមារ កិលេសមារ អភិសង្ខារមារ មច្ចុមារ និងទេវបុត្តមារ ។ ពាក្យថា **វសីកត្វា** សេចក្ដីថា ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនហើយ ។ បទថា **អកុតោភយោ** សេចក្ដីថា អ្នកមិនមានភ័យពីទីណាៗ ។

កាលព្រះមានព្រះភាគត្រាស់ដោយប្រការដូច្នេះហើយ សេលព្រាហ្មណ៍កើតសេចក្ដីជ្រះថ្លាក្នុងព្រះមានព្រះភាគភ្លាម ក្នុងវេលានោះ ជាអ្នកប្រាថ្នាចំពោះបព្វជ្ជា ទើបពោលពីរគាថាថា **ឥមំ ភោន្តោ** ដូច្នេះជាដើម ។ ក្នុងគាថានោះ ពាក្យថា **កណ្ហាភិជាតិកោ** បានដល់ អ្នកកើតក្នុងត្រកូលថោកទាប មានចណ្ឌាលជាដើម ។ បន្ទាប់ពីនោះ សូម្បីមាណពទាំងនោះ ក៏ជាអ្នកប្រាថ្នាបព្វជ្ជា ទើបពោលគាថាថា **ឯវញ្ចេ រុច្ចតិ ភោតោ** (អ្នកដ៏ចម្រើនពេញចិត្ត) យ៉ាងនេះជាដើម ។ គ្រានោះឯង សេលព្រាហ្មណ៍មានចិត្តរីករាយត្រេកអរក្នុងមាណពទាំងនោះ និងប្រាប់ឲ្យមាណពទាំងនោះ ទូលសូមបព្វជ្ជា ទើបពោលគាថាថា **ព្រាហ្មណា** ដូច្នេះជាដើម ។

តអំពីនោះ ព្រះមានព្រះភាគ កាលទឹងទ្រង់ញ៉ាំងមាណពទាំងអស់នោះឲ្យបព្វជ្ជា ជាឯហិភិក្ខុបព្វជ្ជា ទើបត្រាស់ព្រះគាថាថា **ស្វាក្ខាតំ** ដូច្នេះជាដើម ព្រោះសេលព្រាហ្មណ៍ ធ្លាប់ជាប្រធាននៃគណៈបុរស ៣០០ ទាំងអស់នោះ រួមគ្នាសាងបរិវេណទឹងអ្នកទាំងនោះ ធ្វើបុណ្យមានទានជាដើមក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមថា **បទុមុត្តរៈ** ក្នុងអតីតជាតិបានសោយទេវសម្បត្តិ និងមនុស្សសម្បត្តិតាមលំដាប់ ដល់កពចុងក្រោយទើបមកកើតជាអាចារ្យរបស់មាណពទាំងនោះទៀត និងកម្មរបស់អ្នកទាំងនោះ ចាស់ក្លាហើយ ដើម្បីអប់រំវិមុត្តិ និងជាឧបនិស្ស័យនៃឯហិភិក្ខុនោះ ។ ក្នុងព្រះគាថានោះ បទថា **សន្ទិដ្ឋិកំ** បានដល់ ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ។ បទថា **អកាលិកំ** សេចក្តីថា បានដល់ ផលដែលទឹងគប្បីសម្រេចនៃផលដែលកើតឡើងក្នុងចន្លោះនៃមគ្គ មិនមែនក្នុងកាលដទៃ ។

បទថា **យត្ថ អមោឃា** សេចក្តីថា កាលមិនប្រមាទនៅក្នុងមគ្គ-ព្រហ្មចរិយណា សិក្សាដោយការបំពេញសិក្ខាបីឲ្យបរិបូណ៌ ការបព្វជ្ជា ក៏មិនទទេឥតប្រយោជន៍ សេចក្តីថា មានផល ដូច្នេះ ។ ព្រះមានព្រះភាគកាលត្រាស់យ៉ាងនេះហើយ ទើបត្រាស់ថា អ្នកទាំងឡាយចូរមកជាភិក្ខុចុះដូច្នេះ ។ ភិក្ខុទាំងអស់នោះ ជាអ្នកប្រដាប់បាត្រ និងចីវរ ហោះមកផ្ទូវ

អាកាស ថ្វាយបង្គំព្រះមានព្រះភាគហើយ ព្រះមានព្រះភាគទ្រង់ណែនាំល្អហើយ ដូចព្រះថេរៈមានវស្សា ១០០ ។

លោកជាពោលថា **អលត្ថ ខោ សេលោ** ដូច្នេះជាដើម សំដៅដល់ភិក្ខុទាំងនោះ គឺ ឯហិភិក្ខុនេះ ដោយប្រការដូច្នេះ ។

**[២៨]** បទថា **ឥមាហិ** បានដល់ ដោយគាថាដែលសមគួរដល់ចិត្តរបស់កេណិយបរិព្វាជកទាំងនេះ ។ លោកពោលពាក្យថា **អគ្គិហុត្តមុខា យញ្ញា** ក្នុងគាថានោះ ព្រោះព្រាហ្មណ៍ទាំងឡាយ មិនមានការបូជាយញ្ញក្រៅពីការបម្រើភ្លើង ។ សេចក្ដីថា មានការបូជាភ្លើងជាវត្ថុដ៏ប្រសើរ មានការបូជាភ្លើងជាប្រធាន ។ លោកពោលថា សាវិត្តិសាស្រ្តជាប្រធានរបស់ឆន្ទសាស្រ្ត ព្រោះកាលស្វាធ្យាយវេទ ក៏ត្រូវរាយបទនេះមុន ។ លោកពោលថា ព្រះរាជាជាប្រធាន ព្រោះជាអ្នកប្រសើរជាងមនុស្សទាំងឡាយ ។ លោកពោលថា ក៏សាគរជាប្រធាន ព្រោះជាទីទ្រទ្រង់ទុកនូវទន្លេទាំងឡាយ និងជាទីពឹងអាស្រ័យនៃសត្វ ។ លោកពោលថា ព្រះចន្ទ ជាប្រធាននៃផ្កាយទាំងឡាយ ព្រោះមានពន្លឺភ្លឺស្វាង និងមានភាពត្រជាក់ ព្រោះឲ្យដឹងបានថា ថ្ងៃនេះជា កត្តិកាឫក្ស (ខែកត្តិក) , ថ្ងៃនេះជា រោហិណីនក្សត្រ (ជាឈ្មោះផ្កាយឫក្សម្យ៉ាង) ព្រោះប្រកបដោយព្រះចន្ទ ។ លោកពោលថា ព្រះអាទិត្យ

មានសភាពក្តៅជាប្រធាន ព្រោះប្រសើរជាងវត្ថុដែលក្តៅទាំងឡាយ ។

ម្យ៉ាងទៀត លោកពោលថា ព្រះសង្ឃ ជាប្រធាននៃអ្នកប្រាថ្នាបុណ្យ កាលបូជាដោយចំពោះយ៉ាងក្រៃលែង សំដៅដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធានក្នុងសម័យនោះ ព្រោះជាអ្នកប្រសើរជាងទក្ខិណេយ្យបុគ្គលទាំងឡាយ ។ ព្រោះហេតុនោះ លោកសម្តែងថា ព្រះសង្ឃជាស្រែបុណ្យ ដូច្នេះ ។

លោកពោលគាថាព្យាករណ៍ដទៃៗ ថា **យន្តំ សរណំ** (ទីពឹងណា) ។ សេចក្តីនៃគាថានោះ មានដូចតទៅនេះ ៖

ព្រះមានព្រះភាគ ទ្រង់មានចក្ខុដោយចក្ខុ ៥ ព្រោះយើងទាំងឡាយបានមកដល់សរណៈនោះៗ ក្នុងថ្ងៃទី ៨ បន្ទាប់ពីថ្ងៃនេះ ដូច្នោះ ទើបទូន្មានខ្លួនហើយ ដោយការទូន្មាន ដែលមិនមានការទូន្មានដទៃក្រៃលែងជាងក្នុងសាសនារបស់ព្រះអង្គ គួរអស្ចារ្យណាស់ អានុភាពនៃសរណៈរបស់ព្រះ-អង្គ ។ តពីនោះ បានសរសើរព្រះមានព្រះភាគ ដោយគាថា ២ គាថាទៀត កាលសំពះលើកទីបី ទើបពោលថា ភិក្ខុ ៣០០ រូបទាំងនោះ ជាដើម ។

“ ចប់អដ្ឋកថា សេលសូត្រទី ២ ”

# អ ដ្ឋ ក ថា

## អស្សលាយនសូត្រទី ៣

[៣០] *អស្សលាយនសូត្រ* មានពាក្យផ្ដើមថា *ឯវម្មេ សុតំ* ខ្ញុំបាន ស្ដាប់មកហើយយ៉ាងនេះ ៖

ក្នុងព្រះសូត្រនោះ ពាក្យថា **នានាវេរជ្ជកានំ** បានដល់ អ្នកដែល មកអំពីដែនផ្សេងៗ មានអង្គៈ និងមគធៈជាដើម ដោយប្រការផ្សេងៗ គ្នា យ៉ាងទៀត សេចក្ដីថា អ្នកកើតហើយចម្រើនហើយក្នុងដែនទាំងនោះ ក៏ មាន ។ បទថា **កេនចិទេវ** គឺ ដោយកិច្ចដែលមិនបានកំណត់ មានការ បូជាយញ្ញជាដើម ។ បទថា **ចាតុវណ្ណិ** គឺ ទូទៅដល់វណ្ណៈ ៤ ។ ក៏យើង ទាំងឡាយពោលថា ព្រាហ្មណ៍ទាំងឡាយ រមែងស្វាធ្យាយមន្តដើម្បីជម្រះ ឲ្យបរិសុទ្ធិខ្លះ ដើម្បីសេចក្ដីបរិសុទ្ធិនៃការនោខ្លះ ទើបសម្គាល់ថា ព្រះសម-ណគោតមធ្វើវត្ថុដែលមិនសមគួរ ទើបគិតគ្នាយ៉ាងនោះ ។ បទថា **វុត្ត-សិរោ** គឺ កោរសក់ ។

[៣១] បទថា **ធម្មវាទី** សេចក្ដីថា និយាយតាមសភាវៈរបស់ខ្លួន ។

បទថា **ទុប្បភិមន្តិយា** សេចក្ដីថា ដែលបុគ្គលពោលមិនមែនជាធម៌ ដូចយើងនឹងគប្បីពិគ្រោះបានដោយលំបាក ។ លោកសម្ដែងថា មិនអាចធ្វើឲ្យបុគ្គលជាធម្មវាទីចាញ់បាន ។

បទថា **បរិព្វាជកំ** បានដល់ វិធីបព្វជ្ជា ។ ព្រាហ្មណ៍ទាំងនោះ សម្គាល់ថា បុគ្គលដែលរៀនវេទបី ហើយបួសក្នុងខាងក្រោយបុគ្គលដទៃទាំងអស់ រមែងបួសដោយមន្តណា ពេលបួសហើយ រមែងរក្សាមន្តពួកណា រមែងប្រព្រឹត្តអាចារៈណា វត្ថុទាំងអស់នោះ ដែលអ្នកដ៏ចម្រើនរៀនហើយ សិក្សាហើយ ព្រោះហេតុនោះឯង អ្នកនឹងមិនចាញ់ អ្នកនឹងមានតែជ័យជំនះតែម្យ៉ាង ដូច្នេះ ទើបពោលយ៉ាងនោះ ។

**[៣៣]** ពាក្យថា **ទិស្សន្តេ ខោ បន** ដូច្នេះជាដើម លោកពោលដើម្បីទម្លាយលទ្ធិរបស់ព្រាហ្មណ៍ទាំងអស់នោះ ។ ក្នុងបទទាំងនោះ បទថា **ព្រាហ្មណិយោ** បានដល់ នរណាៗ ក៏ឃើញនាងព្រាហ្មណីដែលនាំមកពីត្រកូល ដើម្បីឲ្យដល់បុត្ររបស់ព្រាហ្មណ៍ (រៀបការ) ដោយអាវាហៈ និងវិវាហមង្គល ។ សូម្បីនាងនោះ ក្នុងសម័យដទៃមានក៏រដូវ សេចក្ដីថា កើតមានថ្ងៃខែ ។ បទថា **គព្ភិនិយោ** បានដល់ មានគភ៌ ។ បទថា **វិជាយ-**

មានា បានដល់ ប្រសូតកូនប្រុសស្រី ។ បទថា **បាយមានា** គឺ ឲ្យក្មេងបៅដោះ ។ ពាក្យថា **យោនិជាវសមានា** សេចក្តីថា កើតពីយោនីរបស់នាងព្រាហ្មណី ។ ពាក្យថា **ឯវមាហំសុ** ប្រែថា ពោលហើយយ៉ាងនេះ ។ សួរថា ពោលយ៉ាងណា ។ ឆ្លើយថា ពោលថា **ព្រាហ្មណោវ សេដ្ឋោ វណ្ណោ ។បេ។ ព្រហ្មទាយាទា** ដូច្នេះ ។ ចំណែកពាក្យរបស់បុគ្គលទាំងនោះគប្បីជាពាក្យពិត ផ្ទៃនាងព្រាហ្មណីក៏គប្បីជាទ្រូងរបស់មហាព្រហ្ម ។ យោនីរបស់នាងព្រាហ្មណី ក៏គប្បីជាមាត់របស់មហាព្រហ្ម ដោយហេតុត្រឹមប៉ុណ្ណោះអ្នកទាំងឡាយកុំបានពោលថា នៅក្នុងទ្រូងរបស់មហាព្រហ្ម ចេញពីព្រហ្មដូច្នោះ ទើបពោលពាក្យកាត់រឿងជាតិចេញបាន ។

**[៣៤]** ពាក្យថា **អយ្យោ ហុត្វា ទាសោ ហោតិ ទាសោ ហុត្វា អយ្យោ ហោតិ** (ជាម្ចាស់ហើយ ត្រឡប់ជាទាសៈ ជាទាសៈហើយត្រឡប់ជាម្ចាស់) សេចក្តីថា ព្រាហ្មណ៍ និងភរិយា ប្រកបការធ្វើជំនួញទៅកាន់ដែនយោនកៈ ឬដែនកម្ពោជៈ ធ្វើមរណកាល កាលបុត្រចម្រើនវ័យក្នុងផ្ទះគេមិនមាន នាងព្រាហ្មណីក៏សម្រេចសំវាស និងទាសៈ ឬកម្មករ កើតបុត្តម្នាក់ បុរសនោះជាទាសៈ ។ បុត្តដែលកើតរបស់បុរសនោះ ក៏ជាម្ចាស់មតិក

ឈ្មោះថា បរិសុទ្ធិចំណែកខាងមាតា មិនបរិសុទ្ធិចំណែកខាងបិតា ។ បុរស នោះប្រកបការធ្វើជំនួញហើយ ទៅកាន់មជ្ឈិមប្រទេស នាំកូនក្រមុំរបស់ព្រាហ្មណ៍ទៅ បានកូនប្រុសក្នុងផ្ទៃរបស់នាងនោះ ។ សូម្បីកូនប្រុសនោះ ក៏រមែងបរិសុទ្ធិចំណែកខាងមាតាតែម្យ៉ាង មិនបរិសុទ្ធិចំណែកខាងបិតា ដោយអាការយ៉ាងនេះ ការលាយឡំដោយជាតិ រមែងមានក្នុងលទ្ធិរបស់ព្រាហ្មណ៍នោះឯង ដើម្បីសម្តែងសេចក្តីដូចពោលមកនេះ ទើបពោលពាក្យនោះទុក ។ ពាក្យថា *កឹ ពលំ កោ អស្សាសោ* លោកសម្តែងថា ក្នុងទីណាពួកអ្នកជាទាសៈ គ្រប់គ្នាក៏ជាទាសៈ , បើជាម្ចាស់ គ្រប់គ្នាក៏ជាម្ចាស់ ក្នុងទីនេះអ្វីជាកម្លាំង អ្វីជាសេចក្តីត្រេកអររបស់អ្នកទាំងឡាយ ដែលពោលយ៉ាងនេះថា ព្រាហ្មណ៍ប៉ុណ្ណោះ ជាវណ្ណៈប្រសើរ ។

**[៣៥]** ពាក្យថា *ខត្តិយោ នុ ខោ* ជាដើម ជាពាក្យកាត់ចំណែកសោហេយចេញ ។

**[៣៩]** ឥឡូវនេះ កាលនឹងសម្តែងសេចក្តីបរិសុទ្ធិដែលមានវណ្ណៈ ៤ ទើបពោលពាក្យថា *ឥធកាជា* ដូច្នេះជាដើម ។ បទថា *សាបានទោណិយា* បានដល់ ស្នូកទឹកបាយសូម្បីរបស់សុនខ ។

បទថា **អគ្គិករណីយំ** បានដល់ កិច្ចរបស់ភ្លើងជាដើមថា បន្ទោបង់សេចក្ដីត្រជាក់ កម្ចាត់សេចក្ដីងងឹត ដាំបាយទឹក ។ ឈ្មោះថា អ្នកធ្វើកិច្ចដោយភ្លើងក្នុងកិច្ចគ្រប់យ៉ាងនេះ ឈ្មោះថា **អស្សលាយន** ក្នុងបទនេះ ។

**[៤០]** ឥឡូវនេះ ក្នុងសេចក្ដីដែលព្រាហ្មណ៍ពោលថា សេចក្ដីបរិសុទ្ធិជាប់ទាក់ទងនឹងវណ្ណៈ ៤ សេចក្ដីបរិសុទ្ធិជាប់ទាក់ទងនឹងវណ្ណៈ ៤ នេះមិនមានសេចក្ដីជាក់ច្បាស់ថា វណ្ណៈ ៤ ព្រោះនៅមានវណ្ណៈជាគម្រប់ទី ៥ ដូច្នោះ ដើម្បីនឹងសម្ដែងទោសក្នុងពាក្យរបស់ព្រាហ្មណ៍ទាំងនោះដោយសង្ខេប ព្រះមានព្រះភាគទើបត្រាស់ថា **ឥធ ខត្តិយកុមារោ** នេះ ដូច្នេះជាដើម ។

**[៤២]** បណ្ដាពាក្យទាំងនោះ ពាក្យថា **អមុត្រ ច បន សានំ** សេចក្ដីថា ព្រះមានព្រះភាគត្រាស់ថា ក៏តថាគតមិនឃើញការធ្វើអ្វីៗ របស់មាណពទាំងនេះ ក្នុងន័យមុនឯណោះ ។ សូម្បីព្រាហ្មណ៍ទាំងនោះ នៅមានការធ្វើផ្សេងគ្នាពិតមែន ។ ក៏អ្នកដែលកើតអំពីនាងព្រាហ្មណី និងខត្តិយកុមារ ក៏ឈ្មោះថា កូនកើតពីក្សត្រិយ៍ ។ ក្រៅពីនេះឈ្មោះថា កូនកើតពីព្រាហ្មណ៍ ។ ទាំងនេះជាមាណពដែលមានជាតិថោកទាប ។ ព្រះមានព្រះភាគ លុះទ្រង់សម្ដែងទោសក្នុងវាទៈរបស់ព្រាហ្មណ៍ទាំងនេះថា សេចក្ដី

បរិសុទ្ធិជាប់ទាក់ទងនឹងវណ្ណៈ ៤ ព្រោះនៅមានវណ្ណៈទី ៥ យ៉ាងនេះឯង ។

**[៤៣]** ឥឡូវនេះ កាលនឹងឈានចុះក្នុងសេចក្តីបរិសុទ្ធិជាប់ទាក់ទងនឹងវណ្ណៈ ៤ ទៀត ទើបត្រាស់ពាក្យថា **តំ កឹ មញ្ញសិ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **សាទ្ធេ** បានដល់ ភត្តដើម្បីអ្នកស្លាប់ ។ បទថា **ថាលិបាកេ** បានដល់ ភត្តដើម្បីបណ្ណាការ ។ បទថា **យញ្ញេ** បានដល់ ភត្តដើម្បីបូជាយ័ញ្ញ ។ បទថា **បាហុនេ** បានដល់ ភត្តដែលគេធ្វើដើម្បីភ្ញៀវ ។ បទថា **កឹ ហិ គឹ** រមែងសម្តែងថា អ្វីណានឹងមានផលច្រើន ឬនឹងមិនមានផលច្រើន ។

**[៤៥]** បទថា **ភូតបុព្វំ** សេចក្តីថា អស្សលាយនៈក្នុងកាលមុន យើងថោកទាបដោយជាតិ លោកសូម្បីប្រសើរជាង ក៏មិនអាចដោះស្រាយបញ្ហាក្នុងវាទៈប្រារព្ធជាតិ ដែលតថាគតបានសួរហើយ ឥឡូវនេះ អ្នកជាបុគ្គលថោកទាប តថាគតសួរបញ្ហាប្រារព្ធជាតិរបស់ខ្លួននៃព្រះពុទ្ធទាំងឡាយ នឹងដោះស្រាយបានឬ ការគិតក្នុងបញ្ហានោះ ក៏ធ្វើមិនបាន កាលនឹងលើកស្ទួយមាណពនោះ ទើបប្រារព្ធការទេសនានេះ ដោយប្រការដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **អសិតោ** ប្រែថា ខ្មៅ ។ ពាក្យថា **ទេវលោ** ជាឈ្មោះ

របស់តាបសនោះ ។ ដោយសម័យនោះ ក៏គឺ ព្រះមានព្រះភាគនេះឯង ។ បទថា **អគលិយោ** បានដល់ ស្បែកជើងបួនជាន់ ។

បទថា **បត្តិណ្ឌិលេ** បានដល់ បរិវេណបណ្ណសាលា ។ ពាក្យថា **កោ នុ ខោ** បានដល់ ក្នុងទីណាហ្ន៎ ។ ពាក្យថា **គាមណ្ឌរូបោ វិយ** បានដល់ ដូចក្មេងអ្នកស្រុក ។

ពាក្យថា **សោ ខ្វាហំ កោ ហោមិ** សេចក្តីថា ព្រះមានព្រះភាគត្រាស់ថា តថាគតជាអសិតទេវលៈ ។ បានឮថា ក្នុងកាលនោះ ព្រះមហាសត្វជាអ្នកទូន្មានសេះដែលនៅមិនទាន់បានទូន្មាន ត្រាច់ទៅ ។

ពាក្យថា **អភិវាទេតុំ ឧបក្កមឹសុ** គឺ ចូលទៅថ្វាយបង្គំ និងបន្ទាប់ពីនោះ សូម្បីតាបសដ៏មានអាយុ ១០០ ឆ្នាំ ក៏មិនសំពះ ព្រាហ្មណ៍កុមារដែលកើតក្នុងថ្ងៃនោះ ជាអ្នកទូន្មានហើយ ទូន្មានល្អហើយ ។ ពាក្យថា **ជនិមាតា** សេចក្តីថា ស្ត្រីណាឲ្យអ្នកកើតមក ស្ត្រីនោះក៏ជាមាតាបង្កើតរបស់អ្នក ។ បទថា **ជនិមាតុ** គឺ នៃមាតាបង្កើត ។ បទថា **ជនិបិតា** គឺ អ្នកណាជាបិតាបង្កើត ។ បាឋៈថា **យោ ជនិបិតា** ដូច្នេះក៏មាន ។ បទថា **អសិតេន** សេចក្តីថា ឥសីអសិតទេវលៈអ្នកបានអភិញ្ញា ៥ សួរបញ្ហាប្រារព្ធ

គន្ធពួនេះ ហើយដោះស្រាយមិនបាន ។ បទថា **យេសំ** បានដល់ ឥសី ៧ នាក់ពួកណា ។ ពាក្យថា **ន បុណ្ណោ ទព្វិគាហោ** សេចក្តីថា មាណពម្នាក់ឈ្មោះបុណ្ណៈ ចាប់វែកចម្អិនស្លឹកឈើឲ្យឥសីទាំង ៧ នាក់នោះ ។ បុណ្ណៈនោះដឹងសិល្បៈក្នុងការចាប់វែក តែបុណ្ណៈមិនបានជាអាចារ្យរបស់ឥសីទាំងនោះ អ្នកមិនដឹងសូម្បីត្រឹមតែសិល្បៈ គឺ ការចាប់វែក ដែលបុណ្ណៈនោះដឹងហើយ ។ ពាក្យដ៏សេសក្នុងទីទាំងពួងងាយទាំងអស់នោះឯង ។

ក៏អស្សលាយនព្រាហ្មណ៍នេះ ជាអ្នកមានសទ្ធា មានសេចក្តីជ្រះថ្លា បានសាងចេតិយទុកក្នុងនិវេសន៍របស់ខ្លួន ។ អ្នកដែលកើតក្នុងវង្សរបស់អស្សលាយនព្រាហ្មណ៍ សាងនិវេសន៍ហើយ ក៏សាងចេតិយទុកខាងក្នុងនិវេសន៍រហូតដល់សព្វថ្ងៃនេះ ។

“ ចប់អដ្ឋកថា អស្សលាយនសូត្រទី ៣ ”

# អ ដ្ឋ ក ថា

## ឃោដមុខសូត្រទី ៤

[៩៧] *ឃោដមុខសូត្រ* មានពាក្យផ្តើមថា *ឯវមេ្ម សុតំ* ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ៖

ក្នុងព្រះសូត្រនោះ បទថា *ខេមិយម្ពវនេ* បានដល់ សួនស្វាយដែលមានឈ្មោះយ៉ាងនោះ[១] ។ ពាក្យថា ការបួសប្រកបដោយធម៌ បានដល់ការវៀរចាកដែលប្រកបដោយធម៌ ។ បទថា *អទស្សនា* សេចក្តីថា ព្រោះមិនឃើញបណ្ឌិតដូចជាលោក ។ ពាក្យថា *យោ វា បនេត្ថ ធម្មោ* សេចក្តីថា ឬម្យ៉ាងទៀត ធម្មៈ គឺ សភាវៈនោះឯង យ៉ាងណា ក្នុងទីនេះ ព្រោះមិនឃើញសភាវៈនោះ ។

ដោយបទនេះ លោកសម្តែងថា ពាក្យរបស់យើងមិនជាប្រមាណ ធម៌តែម្យ៉ាងជាប្រមាណ ។ តពីនោះ ព្រះថេរៈគិតថា ក្នុងទីនេះគប្បីមានការងារច្រើនដូចក្នុងរោងឧបោសថថ្មី ទើបចៀសចេញពីទីចង្រ្កម ចូលទៅ

---

១-ព្រៃនេះ ព្រះរាជទេវីព្រះនាមថា ខេមិយា ដាំទុក ។

អន្តុយក្នុងបណ្ណសាលា ។ ដើម្បីនឹងសម្តែងរឿងនោះ លោកទើបពោលថា កាលពោលហើយយ៉ាងនេះ ដូច្នេះជាដើម ។

ពាក្យថា **ចត្តារោ មេ ព្រាហ្មណ** សេចក្តីថា បានឮថា ព្រះថេរៈ មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រាហ្មណ៍នេះពោលថា អ្នកចូលដល់បព្វជ្ជា ដែលប្រកបដោយធម៌ជាសមណៈ ឬជាព្រាហ្មណ៍មិនមានទេ ។ ព្រះថេរៈ កាលសម្តែងបុគ្គល ៤ និងបរិស័ទ ២ ដល់ព្រាហ្មណ៍នេះហើយ ទើបផ្តើម ទេសនានេះថា យើងនឹងសួរបុគ្គល ៤ ពួកថា លោកឃើញមានច្រើនក្នុង បរិស័ទណា ព្រាហ្មណ៍កាលដឹងហើយពោលថា ក្នុងបរិស័ទរបស់អ្នកមិនគ្រប់ គ្រងផ្ទះ យើងនឹងឲ្យព្រាហ្មណ៍នោះពោលដោយមាត់របស់ខ្លួនឯងថា ការវៀរ ចាកប្រកបដោយធម៌មានហើយ ដោយប្រការដូច្នេះ ។

**[៥០]** ក្នុងបទទាំងនោះ បទថា **អ្នកត្រេកអរហើយ** គឺ ត្រេកអរ ខ្លាំងហើយ ព្រោះរាគៈដ៏ក្រាស់ ។ បទថា **សានុគ្គហោ វាចា ភាសិតា** (ពោលវាចាដែលគួរជឿ) គឺ ពោលវាចាប្រកបដោយហេតុ ។ សមដូចពាក្យ ដែលខ្ញុំពោលទុក ពាក្យរបស់យើងមិនជាប្រមាណ ធម៌តែម្យ៉ាងជាប្រមាណ ។

**[៦២]** ដោយពាក្យថា **កឹ បន តេ** (ប្រយោជន៍អ្វីដល់អ្នក) លោក

សួរដើម្បីនឹងដោះថា ធម្មតា គ្រហស្ថនិយាយគួរខ្លះ មិនគួរខ្លះ ។ បទថា ឲ្យធ្វើហើយ បានដល់ សាងហើយ ក៏កាលឲ្យសាងហើយ ធ្វើមរណកាល បានទៅកើតក្នុងសួគ៌ បានឮថា សិល្បៈដែលគួរដឹងរបស់គេនោះ សម្លាប់ទាំងមាតាសម្លាប់ទាំងបិតាហើយ ក្នុងបទថា ខ្លួនត្រូវសិល្បៈដែលគួរដឹងសម្លាប់ ។ ដែលឈ្មោះថា បុគ្គលចេះសិល្បៈណាមួយ បង្រៀនអ្នកដទៃឲ្យចេះសិល្បៈនោះហើយ ទៅកើតក្នុងសួគ៌មិនមាន ។ ក៏ទេវបុត្រនេះ អាស្រ័យព្រះថេរៈធ្វើបុណ្យទើបទៅកើតក្នុងសួគ៌នោះ ក៏កាលកើតហើយ ទើបគិតថា យើងមកកើតក្នុងទីនេះដោយកម្មអ្វី លុះដឹងសេចក្តីពិតហើយ កាលព្រះសង្ឃប្រជុំគ្នាជួសជុលរោងឆាន់ដែលចាស់ហើយក្នុងថ្ងៃមួយ ទើបក្លែងភេទជាមនុស្សមកសួរថា លោកម្ចាស់ដ៏ចម្រើន ព្រះសង្ឃប្រជុំគ្នាដើម្បីអ្វី ។

ភិក្ខុ- ដើម្បីជួសជុលរោងឆាន់ ។

ទេវ- អ្នកណាឲ្យសាងសាលានេះទុក ។

ភិក្ខុ- នាយយោធមុខៈ ។

ទេវ- ឥឡូវនេះគេទៅណា ។

ភិក្ខុ- គេស្លាប់ហើយ ។

ទេវ- ក៏ញាតិណាៗ របស់គេមានខ្លះទេ ។

ភិក្ខុ- មានប្អូនស្រីម្នាក់ ។

ទេវ- ចូរឲ្យហៅនាងមក ។

ភិក្ខុទាំងឡាយឲ្យហៅនាងមកហើយ ។ គេក៏ចូលទៅរកស្ត្រីនោះពោលថា យើងជាបងប្រុសរបស់អ្នក ឈ្មោះឃោជមុខៈ ឲ្យសាងសាលានេះទុក ហើយទៅកើតក្នុងសួគ៌ ខ្ញុំកប់ទ្រព្យទុកត្រង់ឯណោះមួយកន្លែង ត្រង់ឯណោះមួយកន្លែង នាងចូរទៅយកទ្រព្យនោះមក ឲ្យសាងរោងឆាន់នេះផង ចិញ្ចឹមរក្សាក្មេងៗ ផង ថ្វាយបង្គំព្រះភិក្ខុសង្ឃហើយ ហោះឡើងកាន់វេហាស៍ ទៅកាន់ទេវលោកនោះឯង ។ ពាក្យដ៏សល់ក្នុងទីទាំងពួង ងាយទាំងអស់នោះឯង ។

“ ចប់អដ្ឋកថា ឃោជមុខសូត្រទី ៤ ”

# អ ដ្ឋ ក ថា

## ចង្កីសូត្រទី ៥

[៦៣] *ចង្កីសូត្រ* មានពាក្យផ្តើមថា *ឯវម្មេ សុតំ* ខ្ញុំបា នស្តាប់មកហើយយ៉ាងនេះ ៖

ក្នុងចង្កីសូត្រនោះ ពាក្យថា ***ទេវវនេ សាលវនេ*** សេចក្តីថា បានឮថា មហាជនធ្វើពលីកម្មដល់ទេវតាក្នុងព្រៃសាលៈនោះ ព្រោះហេតុនោះព្រៃសាលៈនោះទើបហៅថា ទេវវ័នខ្វះ សាលវ័នខ្វះ ។ ពាក្យថា ***ឱបាសានំ អជ្ឈាវសតិ*** (គ្រប់គ្រងស្រុកឈ្មោះថា ឱបាសាទៈ) សេចក្តីថា ចង្កីព្រាហ្មណ៍គ្រប់គ្រងនៅក្នុងស្រុកព្រាហ្មណ៍ មានឈ្មោះថា ឱបាសាទៈ គឺ ជាធំរបស់ស្រុកនោះ គ្រប់គ្រងនៅពួកស្រុកនោះរហូតដល់ដែនកំណត់ ដែលគប្បីទទួលខុសត្រូវ ។ ក៏ក្នុងពាក្យថា ***ឱបាសាទំ អជ្ឈាវសតិ*** នេះ គប្បីជ្រាបថាទុតិយាវិភត្តិចុះក្នុងអត្ថន័យជាសត្តមាវិភត្តិ ជាប់ដោយឧបសគ្គ ។ ក្នុងបទដ៏សេសក្នុងព្រះសូត្រនោះ គួរខ្វល់ខ្វាយរកលក្ខណៈអំពីគម្ពីរសព្ទសាស្ត្រ ព្រោះស័ព្ទនោះជាទុតិយាវិភត្តិ ។ បទថា ***សត្តុស្សទំ*** កុះករដោយមនុស្ស

និងសត្វសេចក្ដីថា កុះករ គឺ កកកុញដោយមនុស្ស និងសត្វទាំងឡាយ អធិប្បាយថា មានមនុស្សច្រើន មានមនុស្សពាសពេញ និងដោយសត្វច្រើនប្រភេទ មានដំរី សេះ សត្វក្ងោក និងម្រឹគ ដែលចិញ្ចឹមទុកជាដើម ។ ក៏ព្រោះហេតុដែលស្រុកនោះ សម្បូរណ៍ដោយស្មៅសម្រាប់ដំរី សេះជាដើមស៊ី និងស្មៅសម្រាប់ប្រក់ផ្ទះ មួយាងទៀត សម្បូរណ៍ដោយឈើឧស និងឈើគ្រឿងផ្ទះ និងព្រោះហេតុដែលខាងក្នុងស្រុកនោះ មានស្រះបោក្ខរណីច្រើន មានទាំងសណ្ឋានមូល និងបួនជ្រុងជាដើម និងខាងក្រៅ (ស្រុក) មានបឹងដ៏ច្រើន វិចិត្រស្រស់ល្អដោយផ្កាឈើដែលកើតក្នុងទឹក មានទឹកពេញជានិច្ច ព្រោះហេតុនោះ ទើបត្រាស់ថា មានស្មៅ ឈើ និងទឹក ។ បទថា **សធញ្ញំ** ព្រោះប្រព្រឹត្តទៅព្រមដោយធញ្ញាហារ ។ អធិប្បាយថា សន្សំធញ្ញាហារទុកជាច្រើន មានប្រភេទអាហារដែលនឹងបរិភោគមុន និងអាហារដែលបរិភោគក្រោយជាដើម ។ ដោយហេតុដូចពោលមកត្រឹមតែប៉ុណ្ណោះ ព្រាហ្មណ៍ទើបឲ្យលើកស្វេតឆត្រដូចជាព្រះរាជាក្នុងស្រុកនោះ និងសម្ដែងសម្បត្តិការព្រមព្រៀងរបស់ព្រាហ្មណ៍នោះ ។ ទ្រព្យដែលបានអំពីព្រះរាជាឈ្មោះថា រាជទ្រព្យ ។ បើនឹងសួរថា អ្នកណាប្រទាន ។ ឆ្លើយថា ព្រះបាទ

សេនទិកោសលប្រទាន ។ បទថា **រាជទាយំ** រង្វាន់របស់ហ្លួង ប្រែថា ជារង្វាន់របស់ព្រះរាជា អធិប្បាយថា ជាទ្រព្យមត៌ក ។ បទថា **ព្រហ្មទេយ្យំ** (ជាអំណោយដ៏ប្រសើរ) គឺ ជាទ្រព្យដែលគប្បីប្រទានឲ្យដ៏ប្រសើរ អធិប្បាយថា ព្រាហ្មណ៍ឲ្យលើកស្វេតច័ត្រឡើង ហើយប្រើប្រាស់ដូចព្រះរាជា ។ មយ៉ាងទៀត បទថា **រាជភោគ្គំ** (រាជទ្រព្យ) សេចក្ដីថា ព្រាហ្មណ៍បង្គាប់ការកាត់ និងការបែងចែកគ្រប់យ៉ាង រក្សាពន្ធត្រង់កំពង់ទឹក និងភ្នំជាដើម ឲ្យលើកស្វេតច័ត្រឡើងជាព្រះរាជាប្រើប្រាស់ ។ ក្នុងពាក្យថា រាជទ្រព្យដែលព្រះបាទបសេនទិកោសលព្រះរាជទានហើយនេះ ក្នុងព្រះសូត្រនោះ ឈ្មោះថា រង្វាន់របស់ហ្លួង ព្រោះព្រះរាជាប្រទាន ។ លោកពោលពាក្យនេះថា ព្រះរាជាបសេនទិកោសលព្រះរាជទានហើយ ដើម្បីសម្ដែងព្រះរាជាដែលជាអ្នកប្រទានរង្វាន់នោះ ។ បទថា **ព្រហ្មទេយ្យំ** ប្រែថា ជាទ្រព្យដែលព្រះរាជទានដ៏ប្រសើរ អធិប្បាយថា ព្រះរាជទានហើយ ដោយប្រការដែលទ្រង់ព្រះរាជទានហើយ មិនត្រូវការយកវិញ ជាការលះបង់ហើយ បរិច្ចាគហើយ ។

**[៦៩]** ឈ្មោះថា **សង្ឃី** (ជាពួក) ព្រោះមនុស្សជាច្រើន មករួម

គ្នា ៗ មិនចំពោះតែទិសណាមួយ ៗ ពួកមានដល់ព្រាហ្មណ៍ទាំងនោះ ព្រោះហេតុនោះ ឈ្មោះថា ជាពួក ៗ ឈ្មោះថា **គណី** (ជាគណៈ) ព្រោះក្នុងកាលមុនមិនជាគណៈ (ពេលនៅ) ក្នុងស្រុក ចេញទៅខាងក្រៅទើបជាគណៈ ៗ ឈ្មោះថា បែរឆ្ពោះមុខទៅផ្លូវទិសឧត្តរ ព្រោះបែរមុខទៅទិសឧត្តរ ៗ ពាក្យថា **ឧត្តំ អាមន្តេសិ** សេចក្តីថា មហាមាត្រអ្នកអាចព្យាករណ៍បញ្ហា ដែលសួរហើយបាន ហៅថា **ឧត្តំ** ៗ

បទថា **អាគមេន្តុ** (ចូររង់ចាំ) សេចក្តីថា ចូរឈប់មួយភ្លែត អធិប្បាយថា ចូររង់ចាំងសិន ៗ

**[៦៦]** ពាក្យថា **នានាវេរជ្ជកានំ** សេចក្តីថា ឈ្មោះថា អ្នកមកពីដែនផ្សេងៗ ព្រោះពួកគេកើត ឬនៅក្នុងប្រទេសផ្សេងៗ គឺ រដ្ឋដទៃ មានដែនកាសី និងកោសលជាដើម ឬមកពីដែនផ្សេងៗ នោះ ៗ បទថា **កេនចិទេវ** (ដោយកិច្ចណាមួយ) សេចក្តីថា ដោយកិច្ចខ្លះ មានការបូជាយញ្ញជាដើម ដែលកំណត់មិនពិតប្រាកដ ៗ ព្រាហ្មណ៍ទាំងនោះបានឮថា ចង្កីព្រាហ្មណ៍នឹងទៅ ទើបនាំគ្នាគិតថា ចង្កីព្រាហ្មណ៍នេះ ជាព្រាហ្មណ៍ជាន់ខ្ពស់ដោយច្រើន ព្រាហ្មណ៍ទាំងឡាយពួកដទៃ ដល់ព្រះសមណគោតមជាទីពឹង

ចង្កីព្រាហ្មណ៍នេះប៉ុណ្ណោះ មិនទាន់បានទៅ បើចង្កីព្រាហ្មណ៍នេះនឹងទៅក្នុងទីនោះ ត្រូវព្រះសមណគោតម បណ្តាលចិត្តដោយកលល្បិចសម្រាប់បណ្តាលចិត្ត ក៏នឹងដល់សរណៈ តពីនោះ ពួកព្រាហ្មណ៍ក៏នឹងមិនប្រជុំគ្នាត្រង់ទ្វារស្រុករបស់ចង្កីព្រាហ្មណ៍នោះ ណ្ហើយចុះ ពួកយើងនឹងធ្វើការរារាំងការទៅរបស់ចង្កីព្រាហ្មណ៍នោះ ។ គ្រាប្រឹក្សាគ្នាហើយ ទើបរង់ចាំនៅក្នុងទីនោះ ។ លោកសំដៅយកអាការនោះ ទើបពោលពាក្យមានជាដើមថា គ្រានោះឯង ព្រាហ្មណ៍ទាំងនោះ ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ឧភតោ** បានដល់ សូម្បីទាំងពីរខាង គឺ ចំណែកខាងមាតា និងខាងបិតា ។ អធិប្បាយថា មាតាជានាងព្រាហ្មណី យាយជាព្រាហ្មណី សូម្បីមាតារបស់យាយក៏ជានាងព្រាហ្មណី បិតាព្រាហ្មណ៍ តាជាព្រាហ្មណ៍ សូម្បីបិតារបស់តាក៏ជាព្រាហ្មណ៍ (ចង្កីព្រាហ្មណ៍) ម្រើនល្អហើយអំពីចំណែកទាំងពីរ គឺ ចំណែកខាងមាតា និងខាងបិតា យ៉ាងនេះ ដោយប្រការដូច្នេះ ។ បទថា **សំសុទ្ធគ្គហណិកោ** (ប្រសូតិចាកគភ៌ដ៏បរិសុទ្ធ) សេចក្តីថា គភ៌ដែលចាប់បដិសន្ធិចំណែកខាងមាតារបស់លោកបរិសុទ្ធិល្អ សូម្បីគភ៌ដែលចាប់បដិសន្ធិចំណែកខាងបិតារបស់លោកក៏បរិសុទ្ធិល្អ ។ ក្នុងពាក្យថា **យាវ សត្តមា បិតាម-**

*ហយុគា* (តាំងអំពីតំណនៃជីដូនជីតាជាគម្រប់ ៧ ) តា ឈ្មោះថា បិតាមហៈ យុគរបស់តា ឈ្មោះថា បិតាមហយុគ ។ ប្រមាណអាយុ ហៅថា យុគ ។ ក៏ពាក្យថា យុគនេះ ត្រឹមតែជាពាក្យនិយាយគ្នាប៉ុណ្ណោះ ។ តែដោយអត្ថ បិតាមហយុគ ក៏គឺ បិតាមហៈនុ៎ះឯង ។ បព្វៈបុរសសូម្បីទាំងអស់ ខ្ពស់ឡើងទៅជាងនោះ ក៏កាន់យកដោយសព្ទថា បិតាមហៈនុ៎ះឯង ។ អ្នកមានគតិដែលបដិសន្ធិបរិសុទ្ធិល្អដល់ ៧ ជួរ យ៉ាងនេះ ។

ម្យ៉ាងទៀត សម្តែងថា មិនត្រូវជំទាស់ តិះដៀលដោយការពោលអាងដល់ជាតិ ។ បទថា **មិនត្រូវហាម** សេចក្តីថា មិនត្រូវជំទាស់ គឺមិនត្រូវតវ៉ាជំទាស់យ៉ាងនេះថា ចូរនាំអ្នកនេះចេញទៅ ប្រយោជន៍អ្វីដល់អ្នកនេះ ។ បទថា **មិនត្រូវតិះដៀល** សេចក្តីថា មិនត្រូវតិះដៀល គឺ មិនធ្លាប់ត្រូវជេរ ឬតិះដៀល ។ សួរថា ដោយហេតុអ្វី ។ ឆ្លើយថា ដោយការពោលអាងដល់ជាតិ ។ អធិប្បាយថា ដោយពាក្យនិយាយបែបនេះថា សូម្បីព្រោះហេតុនេះ អ្នកនេះជាអ្នកមានជាតិកំណើតអាក្រក់ ។ បទថា **ដោយអង្គនេះ** សេចក្តីថា ព្រោះហេតុសូម្បីនេះ ។

បទថា **អឌ្ឍោ** ប្រែថា ជាឥស្សរៈ ។ បទថា **មហទ្ធនោ** (មានទ្រព្យ

ច្រើន) ប្រែថា ប្រកបដោយទ្រព្យច្រើន ។ សម្តែងថា ក៏ក្នុងស្រុករបស់ចង្កីព្រាហ្មណ៍អ្នកដល់ព្រមដោយទ្រព្យ ដូចធូលី និងខ្សាច់នៅលើផែនដី ឯព្រះសមណគោតមមិនមានទ្រព្យ ធ្វើពោះឲ្យពេញដោយការសូម ហើយញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ។ បទថា **មានភោគៈច្រើន** គឺ ជាអ្នកមានគ្រឿងឧបភោគច្រើន ជាប់ដោយកាមគុណ ៥ ។ ពួកព្រាហ្មណ៍ពោលគុណណាៗដោយប្រការយ៉ាងនេះ រមែងពោលមើលងាយថា ពួកយើងនឹងពោលចំពោះទោសរបស់ព្រះមានព្រះភាគ ដោយជាបដិបក្ខចំពោះគុណនោះៗ ។ បទថា **មានរូបល្អ** សេចក្តីថា មានរូបល្អក្រៃលែងជាងមនុស្សដទៃ ។ បទថា **ទស្សនីយោ** សេចក្តីថា គួរដល់ការមើល ព្រោះធ្វើការនឿយណាយដល់អ្នកមើលសូម្បីមួយថ្ងៃ ។ ឈ្មោះថា **គួរជ្រះថ្លា** ព្រោះធ្វើសេចក្តីជ្រះថ្លាឲ្យកើត ដោយការមើលប៉ុណ្ណោះ ។ ការស្អាតល្អ ហៅថា **បោក្ខរតា** ។ភាពស្អាតល្អនៃពណ៌សម្បុរ ឈ្មោះថា **វណ្ណបោក្ខរតា** ។ ដោយការៈស្អាតនៃពណ៌សម្បុរនោះ ។ អធិប្បាយថា ដោយសេចក្តីដល់ព្រមនៃពណ៌សម្បុរ ។ចំណែកបុរាណាចារ្យ ហៅសរីរៈថា **បោក្ខរ** ។ វណ្ណៈ ក៏គឺ ពណ៌សម្បុរនុ៎ះឯង ។ តាមមតិរបស់លោក វណ្ណៈ និងសរីរៈ ឈ្មោះថា វណ្ណៈ និង

សរីរៈ ។ ភាវៈនៃវណ្ណៈ និងសរីរៈ ឈ្មោះថា **វណ្ណពោក្ខរតា** ។ ពាក្យថា **បរមាយ វណ្ណពោក្ខរតាយ** សេចក្ដីថា ដោយវណ្ណៈដ៏បរិសុទ្ធិខ្ពង់ខ្ពស់ និង ដោយការដល់ព្រមដោយសរីរសណ្ឋាន ។ បទថា **ព្រហ្មវណ្ណី** ប្រែថា មាន វណ្ណៈប្រសើរខ្ពង់ខ្ពស់ ។ អធិប្បាយថា ប្រកបដោយវណ្ណៈដូចមាស ដ៏ ប្រសើរបំផុត សូម្បីក្នុងបណ្ដាវណ្ណៈដែលបរិសុទ្ធិទាំងឡាយ ។ ពាក្យថា **មានសរីរៈដូចព្រហ្ម** បានដល់ ប្រកបដោយសរីរៈដូចសរីរៈរបស់មហាព្រហ្ម ។ ពាក្យថា **អខុទ្ទាវកាសោ ទស្សនាយ** សេចក្ដីថា ឱកាសនៃការបានឃើញ សរីរៈរបស់លោកដ៏ចម្រើន មិនតិចតួច គឺ ធំ ។ លោកសម្ដែងថា អវយវៈ តូចធំរបស់លោកទាំងអស់នោះឯង គួរមើលផង ទាំងធំនោះឯងផង ។ ឈ្មោះ ថា **មានសីល** ព្រោះអត្ថថា សីលរបស់ព្រាហ្មណ៍នោះមាន ។ ឈ្មោះថា **មានសីលតាំងមាំ** ព្រោះអត្ថថា សីលរបស់ព្រាហ្មណ៍នោះរីករាយហើយ គឺ ចម្រើនហើយ ។ បទថា **វុឌ្ឍសីលេន** ប្រែថា ដោយសីលដែលរីករាយ ហើយ គឺ ចម្រើនហើយ ។ បទថា **សមន្នាគតោ** ប្រែថា ប្រកបហើយ ។ ពាក្យនេះជាវេវចនៈ របស់បទថា **វុឌ្ឍសីលី** នុ៎ះឯង ។ ពួកព្រាហ្មណ៍ពោល ពាក្យ (ថាសីល) ទាំងអស់នោះ សំដៅយកត្រឹមតែសីល ៥ ប៉ុណ្ណោះ ។

ក្នុងពាក្យថា **មានវាចាល្អជាដើម** ដែលឈ្មោះថា មានវាចាល្អ ព្រោះអត្ថថា វាចារបស់ព្រាហ្មណ៍នោះ ល្អ គឺ ល្អ បានដល់ មានបទ និងព្យញ្ជនៈមូល ក្ខំ ។ ឈ្មោះថា **សំឡេងពីរោះ** ព្រោះអត្ថថា ការនិយាយសំឡេងរបស់ព្រាហ្មណ៍នោះល្អ គឺ ពីរោះ ។ សំឡេងដែលពោលចេញ ឈ្មោះថា **វាក្ករណំ** ។ ឈ្មោះថា **មានវាចាជារបស់អ្នកក្រុង** ព្រោះជាវាចាមានក្នុងក្រុង ដោយវាចាដែលសម្បូរណ៍ដោយគុណ ។ ម្យ៉ាងទៀត ឈ្មោះថា មានវាចាដូចមនុស្សស្រីអ្នកក្រុង ព្រោះអត្ថថា មានវាចាដូចវាចារបស់ស្រ្តីអ្នកក្រុងនោះ ព្រោះស្រ្តីអ្នកក្រុង ឈ្មោះថា អ្នកបុរី ព្រោះមានក្នុងក្រុង ជាអ្នកល្អិតល្អន់ ។ ប្រកបដោយវាចារបស់អ្នកក្រុងនោះ ។ បទថា **វិសដ្ឋាយ** បានដល់ មិនជាប់ គឺ វៀរចាកទោស មានសំឡេងខ្ពស់ និងសំឡេងទាបជាដើម ។ បទថា **អនេលគឡាយ** សេចក្តីថា វៀរចាកទោស ។ អធិប្បាយថា ក៏កាលបុគ្គលខ្លះកំពុងនិយាយ ទោសរមែងហូរចេញ គឺ ទឹកមាត់ហូរ ឬជុំទឹកមាត់សាច វាចារបស់អ្នកនោះឈ្មោះថា ជាវាចាមានទោស ។ ដោយវាចាដែលផ្ទុយនឹងវាចាដែលមានទោសនោះ ។ ពាក្យថា **អត្ថស្ស វិញ្ញាបនិយា** សេចក្តីថា អាចធ្វើខាងដើម កណ្តាល និងខាងចុងឲ្យប្រាកដ ធ្វើ

ឲ្យអ្នកស្តាប់យល់ជាក់ច្បាស់សេចក្តីដែលពោល ។ ពាក្យដ៏សេសក្នុងការពណ៌នាគុណរបស់ព្រាហ្មណ៍ក្នុងទីនេះ ងាយទាំងអស់ ។

**[៦៧]** ពាក្យថា ឯវំ វុត្តេ ប្រែថា កាលព្រាហ្មណ៍ទាំងនោះពោលយ៉ាងនេះ ។ ចង្កីព្រាហ្មណ៍គិតថា ពួកព្រាហ្មណ៍ទាំងនេះ យល់ថា ដែលឈ្មោះថា សត្វកាលពោលគុណរបស់ខ្លួននឹងមិនត្រេកអរមែងមិនមាន ពួកយើងនឹងពោលគុណរបស់ចង្កីព្រាហ្មណ៍នោះ ហាម (មិនឲ្យទៅ) ទើបពោលគុណរបស់យើង ដោយអាងដល់ជាតិជាដើម ការត្រេកអរក្នុងការពណ៌នាគុណរបស់ខ្លួនឯង មិនគួរដល់យើងទេ ណ្ហើយចុះ យើងនឹងទម្លាយវាទៈរបស់ព្រាហ្មណ៍ទាំងនោះ ឲ្យពួកគេដឹងថា ព្រះសមណៈគោតមជាធំ ធ្វើឲ្យពួកគេទៅក្នុងទីនោះ ដូច្នេះហើយ ទើបពោលពាក្យជាដើមថា អ្នកដ៏ចម្រើនទាំងឡាយ បើដូច្នោះ ពួកអ្នកចូរស្តាប់ខ្ញុំសិន ។ ក៏ចង្កីព្រាហ្មណ៍ដឹងគុណទាំងឡាយ ដែលក្រៃលែងជាងគុណរបស់ខ្លួនថា បណ្តាគុណទាំងនោះ គុណសម្បត្តិណាដូចគ្នានឹងគុណរបស់ខ្លួនមានជាដើម ថា កើតល្អហើយតែទាំងពីរចំណែក គុណសម្បត្តិនោះ មានការដល់ព្រមដោយព្រះជាតិជាដើម ក៏សុទ្ធតែជារបស់ព្រះសមណគោតមទាំងអស់ ទើបប្រកាសគុណទាំងឡាយដែល

ខ្ពស់ៗ ឡើងទៅ ដើម្បីសម្ដែងថា ព្រះមានព្រះភាគទ្រង់ជាធំដោយចំណែកតែមួយនោះឯង ។ ពាក្យថា **ពួកយើងប៉ុណ្ណោះរមែងគួរ** សេចក្ដីថា កាលព្រាហ្មណ៍កំណត់យ៉ាងនេះ ទើបសម្ដែងពាក្យនេះទុកក្នុងទីនេះថា ព្រះសមណ-គោតម ឈ្មោះថា ជាបុគ្គលដែលយើងគួរនឹងចូលទៅរក ព្រោះទ្រង់ជាធំដោយព្រះគុណ ។ ដូចគ្រាប់ស្ពៃ ប្រៀបនឹងភ្នំព្រះសុមេរុ ជារបស់តិចតួច , ទឹកក្នុងជានជើងគោ ប្រៀបនឹងទឹកមហាសមុទ្រ ជារបស់តិចតួច , តំណក់ទឹកសន្សើម ប្រៀបនឹងទឹកក្នុងស្រះធំទាំង ៧ ក៏ជារបស់តិចតួច យ៉ាងណា គុណរបស់ពួកយើង កាលបើប្រៀបនឹងព្រះគុណ មានជាតិសម្បត្តិជាដើមរបស់ព្រះសមណគោតម ក៏ជារបស់បន្តិចបន្តួច ដូច្នោះដែរ ព្រោះដូច្នោះពួកយើងប៉ុណ្ណោះ រមែងគួរចូលទៅគាល់ព្រះគោតមដ៏ចម្រើននោះ ។ ក្នុងពាក្យថា **ភូមិគតញ្ចវេហាសដ្ឋញ្ច** នេះ ទ្រព្យដែលនៅក្នុងផែនដី ធ្វើស្រះបោក្ខរណីដែលបូកដោយកំបោរ.សឲ្យពេញដោយរតនៈ ៧ ប្រការ ទាំងក្នុងព្រះរាជវាំង និងក្នុងព្រះរាជឧទ្យាន ឈ្មោះថា ទ្រព្យនៅក្នុងផែនដី ។ ចំណែកទ្រព្យដែលរក្សាទុកពេញប្រាសាទ និងដែលរក្សារួបរួមទុកជាដើម ឈ្មោះថា ទ្រព្យតាំងនៅក្នុងអាកាស ។ ទ្រព្យដែលមានមកតាមវង្សត្រកូល យ៉ាងនេះ

មុន ។

ចំណែកចំពោះក្នុងថ្ងៃដែលព្រះតថាគតប្រសូតិ មានរណ្តៅទ្រព្យផុសឡើង ៤ រណ្តៅ គឺ រណ្តៅទ្រព្យសង្ខៈ ១ , រណ្តៅទ្រព្យឯលៈ ១ , រណ្តៅទ្រព្យឧប្បលៈ ១ , រណ្តៅទ្រព្យបុណ្ឌរិកៈ ។ បណ្តារណ្តៅទ្រព្យទាំងនោះ រណ្តៅទ្រព្យទទឹងមួយគាវុត ឈ្មោះសង្ខៈ ។ រណ្តៅទ្រព្យទទឹងកន្លះយោជន៍ ឈ្មោះឯលៈ ។ រណ្តៅទ្រព្យទទឹង ៣ គាវុត ឈ្មោះឧប្បលៈ ។ កំណាប់ទ្រព្យទទឹង ១ យោជន៍ ឈ្មោះបុណ្ឌរិកៈ ។ ទីដែលចាប់យកទ្រព្យក្នុងរណ្តៅទ្រព្យសូម្បីទាំងនោះ រមែងពេញនៅដូចដើម គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់លះបង់ប្រាក់ និងមាសច្រើនណាស់ចេញបួសដោយប្រការដូច្នេះ ។

ពាក្យថា **កម្ហោះ ដូច្នេះជាដើម** ខ្ញុំឲ្យពិស្តារហើយក្នុងខាងក្រោយនោះឯង ។ ក្នុងពាក្យថា **អនុទ្ទារិកាសោ** នេះ គប្បីជ្រាបថា គ្រាន់តែឃើញព្រះមានព្រះភាគដែលរកប្រមាណមិនបាន ក្នុងសេចក្តីនេះ មានរឿងដូចតទៅនេះ ៖

បានឮមកថា ព្រាហ្មណ៍ម្នាក់ក្នុងក្រុងរាជគ្រិះ ស្តាប់តៗ មកថា អ្នក

ណាៗ មិនអាចវាស់ប្រមាណ (ខ្នាត) របស់ព្រះសមណគោតមបាន ទើប ក្នុងវេលាដែលព្រះមានព្រះភាគស្ដេចចូលទៅបិណ្ឌបាត គេឈរកាន់ឫស្សី ប្រវែង ៦០ ហត្ថ នៅខាងក្រៅទ្វារក្រុង ពេលព្រះមានព្រះភាគស្ដេចទៅ ដល់ ទើបកាន់ឫស្សីឈរនៅជិតៗ ។ ឫស្សីវែងត្រឹមតែព្រះជានុ របស់ ព្រះមានព្រះភាគ ។ ថ្ងៃស្អែក គេយកឈើឫស្សី ២ ដើម ហើយបានឈរ កាន់ឫស្សីនៅក្នុងទីជិតៗ ។ ព្រះមានព្រះភាគត្រាស់ថា ព្រាហ្មណ៍ អ្នកធ្វើ អ្វីប្រាកដត្រឹមតែឫស្សី ២ ដើម (មក.ត) ឬលើសពីឫស្សី ២ ដើម ។

ព្រាហ្មណ៍- ខ្ញុំព្រះអង្គនឹងវាស់ខ្នាតរបស់ព្រះអង្គ ។

ព្រះមានព្រះភាគ- ព្រាហ្មណ៍ សូម្បីអ្នកយកឫស្សីមក.តគ្នារហូត ពេញចក្រវាឡទាំងអស់ ហើយឈរវាស់នៅក្នុងទីជិត អ្នកក៏មិនអាចវាស់ ខ្នាតរបស់តថាគតបាន ព្រោះតថាគតបំពេញបារមីមកអស់ ៤ អសង្ខេយ្យ មួយសែនមហាកប្ប ដោយប្រការដែលអ្នកដទៃនឹងគប្បីវាស់ខ្នាតរបស់តថា-គតនោះរកមិនបាន ព្រះតថាគតនោះថ្លឹងមិនបាន ប្រមាណមិនបាន ដូច្នេះ ហើយត្រាស់ព្រះគាថាក្នុងព្រះធម្មបទ ។ ក្នុងវេលាចប់ព្រះគាថា សត្វប្រាំ-បីម៉ឺនបួនពាន់ផឹកទឹកអម្រឹតហើយ ។ នៅមានរឿងមួយទៀត ។ បានឮថា

រាហូអសុរិន្ទ្រ កម្ពស់ ៤.៨០០ យោជន៍ ។ ប្រវែងដៃ ១.២០០ យោជន៍ ។ បាតដៃបាតជើងទំហំ ៣០០ យោជន៍ ។ ថ្នាំងម្រាមដៃ ៥០ យោជន៍ ។ ចន្លោះចិញ្ចើម ៥០ យោជន៍ ។ ថ្ងាស់ទំហំ ៣០០ យោជន៍ ។ សីសៈ ៩០០ យោជន៍ ។ ស្តេចរាហូនោះមិនមកគាល់ដោយគិតថា យើងខ្ពស់ មិនអាចឱនមើលព្រះសាស្តា ។ ថ្ងៃមួយ បានស្តាប់ការពណ៌នាគុណរបស់ព្រះមានព្រះភាគ ទើបមកគាល់ ដោយគិតថា នឹងមើលតាមតែនឹងអាចមើលបាន ព្រះមានព្រះភាគទ្រង់ជ្រាបអធ្យាស្រ័យរបស់រាហូអសុរិន្ទ្រ ទើបទ្រង់ព្រះតម្រិះថា តថាគតនឹងសម្តែងដោយឥរិយាបថណា ក្នុងបណ្តាឥរិយាបថទាំង ៤ ហើយទ្រង់ត្រិះរិះបន្តទៅថា ធម្មតា អ្នកឈរស្ទូម្បីទាប ក៏ប្រាកដដូចជាខ្ពស់ តថាគតនឹងដេកសម្តែងខ្លួនដល់រាហូអសុរិន្ទ្រចុះ ដូច្នេះហើយ ត្រាស់ថា ម្នាលអានន្ទ អ្នកចូរនាំគ្រែតាំងទុកក្នុងបរិវេណព្រះគន្ធកុដិ ហើយទ្រង់សម្រេចសីហសេយ្យាសនៈលើគ្រែនោះ ។ ស្តេចរាហូនឹងមកដល់ ក៏ងើយ.កសម្លឹងមើលព្រះមានព្រះភាគដែលទ្រង់ផ្ទំ ដូចងើយ.កមើលព្រះចន្ទពេញវង់ នាកណ្តាលនភាកាស ដូច្នោះ ។ ហើយព្រះមានព្រះភាគត្រាស់ថា នេះជាអ្វី រាហូអសុរិន្ទ្រ ក៏ក្រាបទូលថា ខ្ញុំព្រះអង្គមិនមកគាល់ដោយគិតថា ខ្ញុំព្រះអង្គ

មិនអាចឱនមើលព្រះមានព្រះភាគបាន ។ ព្រះសាស្តាត្រាស់ថា ម្នាលរាហុ តថាគតមិនបានបំពេញបារមីដូចឱនមុខ តថាគតឲ្យទានធ្វើឲ្យមានផលប្រសើរខ្ពស់ទាំងអស់ ។ ថ្ងៃនោះ ស្តេចរាហុបានដល់ សរណៈ ។ ព្រះមានព្រះ-ភាគទ្រង់គ្រាន់តែឃើញ តែរកប្រយោជន៍មិនបាន ដោយប្រការយ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់មានសីលដោយចតុប្បារិសុទ្ធិសីល ។ ចំណែកសីលនោះជាអរិយៈ គឺ បរិសុទ្ធិខ្ពង់ខ្ពស់ ។ ព្រោះហេតុនោះ ចង្កីព្រាហ្មណ៍ទើបពោលថា ទ្រង់មានសីលជាអរិយៈ ។ សីលនោះឯង ឈ្មោះថា ជាកុសល ព្រោះអត្ថថា មិនមានទោស ។ ព្រោះហេតុនោះ ចង្កីព្រាហ្មណ៍ទើបពោលថា ទ្រង់មានសីលជាកុសល ។ ពាក្យថា មានសីលជាកុសលនេះ ជាវេវចនៈរបស់ពាក្យថា មានសីលជាកុសលនោះ ។ ពាក្យថា **ពហុន្នំ អាចរិយបាចរិយោ** ទ្រង់ជាអាចារ្យលើអាចារ្យរបស់មនុស្សជាច្រើន សេចក្តីថា សត្វប្រាំបីម៉ឺនបួនពាន់ ទាំងទេវតា និងមនុស្សមិនមានប្រមាណ ផឹកអមតធម៌ គឺ មគ្គផលដោយព្រះធម៌ទេសនាតែម្យ៉ាង របស់ព្រះមានព្រះ-ភាគ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ឈ្មោះថា ជាប្រធានលើអាចារ្យរបស់ពួកជនជាច្រើន គឺ របស់អាចារ្យ និងសាវកវេនេយ្យៈ ។ ក្នុងពាក្យថា

ទ្រង់មានកាមរាគៈអស់ហើយនេះ កិលេសសូម្បីទាំងពួង របស់ព្រះមាន-ព្រះភាគអស់ទៅហើយដោយពិត តែព្រាហ្មណ៍មិនស្គាល់កិលេសទាំងនោះ ពោលគុណក្នុងឋានៈដែលខ្លួនដឹងប៉ុណ្ណោះ ។ បទថា **វិគតាចាបល្លោ** (ប្រាស ចាកសេចក្តីឡេះឡោះ) សេចក្តីថា ទ្រង់ប្រាសចាកសេចក្តីឡេះឡោះ ដែល ពោលទុកយ៉ាងនេះថា ប្រដាប់បាត្រប្រដាប់ចីវរ និងសេនាសនៈ ម្យ៉ាងទៀត ការស្រឡាញ់ ការប្រកាន់កាយដែលស្អុយរលួយនេះ ។ បទថា **អបាបបុរេក្ខារោ** (ទ្រង់មិនប្រាថ្នាសេចក្តីអាក្រក់) គឺ ទ្រង់ប្រាថ្នាលោកុត្តរធម៌ ៩ ដ៏ប្រសើរ ស្តេចត្រាច់ទៅ ។ ពាក្យថា **ជនដែលជាព្រាហ្មណ៍** បានដល់ ពួកព្រាហ្មណ៍តែមួយពួក មានព្រះសារីបុត្រ ព្រះមោគ្គល្លាន និងព្រះមហា កស្សបៈជាដើម ។ ក៏ព្រះមានព្រះភាគនោះ ទ្រង់មិនប្រាថ្នាអាក្រក់ ទ្រង់ ធ្វើពួកជននេះឯងទុកខាងមុខ ។ អធិប្បាយថា ក៏ពួកជននេះធ្វើព្រះសមណ-គោតមទុកខាងមុខ ហើយត្រាច់ទៅ ។

ម្យ៉ាងទៀត មិនប្រព្រឹត្តប្រាថ្នាសេចក្តីអាក្រក់ អធិប្បាយថា មិនប្រាថ្នា សេចក្តីបាប ។ សួរថា ដល់អ្នកណា ។ ឆ្លើយថា ដល់ពួកព្រាហ្មណ៍ ។ មានអធិប្បាយថា ទ្រង់មិនប្រទូស្ត គឺ ទ្រង់បំណងប្រយោជន៍សុខចំពោះ

ព្រាហ្មណ៍តែម្យ៉ាង សូម្បីអ្នកប្រាថ្នាប្រទូស្តចំពោះព្រះអង្គ ។ បទថា **តិរោរដ្ឋា** រដ្ឋផ្សេងៗ គឺ អ្នករដ្ឋដទៃ ។

បទថា **តិរោជនបទា** ជនបទផ្សេង គឺ ជនបទដទៃ ។ ពាក្យថា **សំបុច្ឆិតុំ អាគច្ឆន្តិ** មកដើម្បីទូលសួរបញ្ហា បានដល់ ជនទាំងឡាយមានក្សត្រិយ៍ និងបណ្ឌិតជាដើម ព្រាហ្មណ៍ និងគន្ធព្វ (អ្នកចម្រៀង) ជាដើម តែងបញ្ហាមកដោយប្រាថ្នាថា នឹងទូលសួរបញ្ហា ។ បណ្តាជនទាំងនោះពួកខ្លះកំណត់ឃើញទោសនៃការសួរបញ្ហា និងមិនអាចក្នុងការដោះស្រាយបញ្ហា និងការមិនអាចទទួលបញ្ហា ទើបអង្គុយស្ងៀមមិនសួរ ។ ពួកខ្លះសួរ ។ សម្រាប់ពួកខ្លះ ព្រះមានព្រះភាគទ្រង់ធ្វើសេចក្តីឧស្សាហ៍ក្នុងការសួរបញ្ហាឲ្យកើតឡើង ហើយទ្រង់ដោះស្រាយ ។ បើដូច្នេះ សេចក្តីសង្ស័យរបស់អ្នកទាំងអស់នោះ លុះមកគាល់ព្រះមានព្រះភាគ ក៏អស់ទៅ ដូចរលករបស់មហាសមុទ្រ ពេលមកដល់ច្រាំងក៏រលាយបាត់ទៅ ដូច្នោះ ។ ពាក្យដ៏សេសក្នុងការពណ៌នាគុណរបស់ព្រះតថាគត ក្នុងអធិការនេះ ងាយទាំងអស់ ។ ពាក្យថា **អតិថី នោ តេ ហោន្តិ** (សមណៈ ឬព្រាហ្មណ៍ទាំងនោះជាភ្ញៀវ) សេចក្តីថា សមណៈ ឬព្រាហ្មណ៍ទាំងនោះជាអាគន្តុកៈ គឺ ជាភ្ញៀវរបស់ពួក

យើង ។ បទថា **បរិយាបុណាមិ** (ខ្ញុំជ្រាប) គឺ ខ្ញុំដឹង ។ បទថា **អបមាណវណ្ណា** មានព្រះគុណរកប្រមាណមិនបាន លោកសម្តែងសេចក្តីថា មានព្រះគុណដែលសូម្បីព្រះសព្វញ្ញូដូចៗ គ្នា ក៏ប្រមាណមិនបាន នឹងពោលថ្វីដូចយើង ។ សមពិត ដូចពាក្យដែលលោកពោលទុកថា ៖

សូម្បីព្រះពុទ្ធនឹងគប្បីពោលគុណរបស់ព្រះពុទ្ធ បើពោលគុណនៃគ្នានិងគ្នារហូតដល់អស់ទាំងកប្ប កប្បគប្បីអស់ទៅក្នុងចន្លោះ ជាវេលាយឺតយូរ ការពោលព្រះគុណរបស់ព្រះតថាគត មិនអស់ទេ ដូច្នេះ ។

ព្រាហ្មណ៍ទាំងនោះ បានស្តាប់ពាក្យពណ៌នាគុណនេះហើយ នាំគ្នាគិតថា ចង្កីព្រាហ្មណ៍ពោលគុណណាៗ របស់ព្រះសមណគោតម ព្រះសមណគោតមដ៏ចម្រើនអង្គនោះ ទ្រង់មានព្រះគុណមិនអន់ថយ ដោយប្រការណា ក៏ចង្កីព្រាហ្មណ៍នេះ ដឹងព្រះគុណទាំងឡាយរបស់សមណគោតមព្រះអង្គនោះ ទើបនៅយូរដោយប្រការនោះ ណ្ហើយចុះ ពួកយើងនឹងប្រព្រឹត្តតាមចង្កីព្រាហ្មណ៍នោះ ដូច្នេះ កាលពួកព្រាហ្មណ៍នឹងប្រព្រឹត្តតាម ទើបពោលពាក្យជាដើមថា លោកដ៏ចម្រើន បើដូច្នេះ ។

[៦៨] បទថា **ឧបាគេតិ** ប្រែថា ចូលទៅ ។

[៦៩] បទថា **សំបុរក្ខរោន្តិ** រមែងប្រាថ្នាល្អ គឺ រមែងប្រព្រឹត្តទៅស្មើ សូម្បីកូន និងចៅ ។ បទថា **មន្តបទំ** បទមន្ត សេចក្តីថា បទមន្ត ក៏គឺមន្តនុ៎ះឯង អធិប្បាយថា វេទ ។ ដោយបទថា **ឥតិហិតិហបរម្បរាយ** ដោយតៗ គ្នាមកដូច្នេះៗ នេះ សម្តែងថា បទមន្តមកដោយការៈតៗ គ្នាថា គេបានឮមកថាយ៉ាងនេះ ។ បទថា **បិដកសម្បទាយ** ដោយសម្បត្តិ គឺ តម្រាក្បួនច្បាប់ បានដល់ ដោយសម្បត្តិ គឺ ពាក្យនិយាយ ។ លោកសម្តែងថា តែងមកដោយការប្រព័ន្ធជាធនុៈ មានសាវិត្តសាស្ត្រជាដើម និងដោយការជាពួក ។ បទថា **តត្ថ ច** (នោះដោយ) ប្រែថា ក្នុងបទមន្តនោះ ។

[៧០] បទថា **បវត្តារោ** (អ្នកពោល) ប្រែថា ជាអ្នកប្រាប់មន្ត ។ បទថា **យេសំ** ប្រែថា ដែលជារបស់មានហើយរបស់ព្រាហ្មណ៍ពួកណា ។ បទថា **មន្តបទំ** បានដល់ មន្ត គឺ វេទនុ៎ះឯង ។ បទថា **គីតំ** សេចក្តីថា ដែលព្រាហ្មណ៍ចាស់ពីមុន ១០ នាក់ មានអដ្ឋកព្រាហ្មណ៍ជាដើម សូត្រហើយដល់ព្រមដោយការជាប់នៃសំឡេង ។ បទថា **បវុត្តំ** បានដល់ ប្រាប់ហើយ អធិប្បាយថា ពោលហើយដល់អ្នកដទៃ ។ បទថា **សមិហិតំ** សេចក្តីថា

រួមទុក គឺ ធ្វើឲ្យជាពួកៗ អធិប្បាយថា ចាត់ចែងទុកជាពួក ។ បទថា **តទនុគាយន្តិ** សូត្រតាមមន្តនោះ សេចក្តីថា ព្រាហ្មណ៍ទាំងឡាយក្នុងកាលឥឡូវនេះ សូត្រតាម គឺ សូត្រតាមបទមន្តនោះ ដែលលោកទាំងនោះសូត្រហើយក្នុងកាលមុន ។ បទថា **តទនុភាសតិ** ប្រែថា ពោលតាមបទមន្តនោះ ។ ពាក្យនេះជាវេវចនៈរបស់ពាក្យមុនន៉ុះឯង ។ បទថា **ភាសិតមនុភាសន្តិ** ប្រែថា ពោលតាមលោកទាំងនោះពោលហើយ ស្វាធ្យាយហើយ ។ បទថា **វាចិតមនុវាចេន្តិ** ប្រែថា បង្រៀនតាមដែលលោកទាំងនោះបង្រៀនដល់អ្នកដទៃ ។ ពាក្យថា **សេយ្យថីទំ** មានសេចក្តីថា លោកទាំងនោះ គឺ លោកពួកណា ។ ពាក្យថា **អដ្ឋក** ជាដើម ជាឈ្មោះរបស់លោកទាំងនោះ ។ បានស្តាប់មកថា លោកទាំងនោះពិចារណាមើលដោយទិព្វចក្ខុ មិនធ្វើការបៀតបៀនអ្នកដទៃ ប្រៀបធៀបនឹងព្រះតម្រាស់របស់ព្រះមានព្រះភាគកស្សប-សម្មាសម្ពុទ្ធ ព្រមទាំងចងក្រងមន្តទាំងឡាយទុក ។ ចំណែកព្រាហ្មណ៍ពួកដទៃ ថែមការសម្លាប់សត្វជាដើមចូលទៅ ទម្លាយវេទទាំងបី ធ្វើឲ្យខុសនឹងព្រះតម្រាស់របស់ព្រះពុទ្ធ ។

**[៧១]** បទថា **អន្ធវេណិ** ប្រែថា ជួរអ្នកខ្វាក់ភ្នែក ។ គឺ បុគ្គលអ្នក

ក្អែកខ្វាក់ម្នាក់ ចាប់ចុងឈើច្រត់ដែលបុគ្គលក្អែកល្អម្នាក់ ។ បុគ្គលខ្វាក់ក្អែក ៥០-៦០ នាក់ តគ្នាតាមលំដាប់យ៉ាងនេះ គឺ បុគ្គលខ្វាក់ក្អែកដទៃតោងបុគ្គលខ្វាក់ក្អែកនោះ បុគ្គលដទៃតោងបុគ្គលនោះ តៗ ទៅ ហៅថា ជួរបុគ្គលខ្វាក់ក្អែក ។ បទថា **បរម្បរាសំសត្តា** តោងគ្នាតៗ ទៅ សេចក្តីថា តោងគ្នានិងគ្នា អធិប្បាយថា វៀរបុគ្គលក្អែកល្អអ្នកកាន់ឈើច្រត់ ។ បានឮថា អ្នកលេងម្នាក់ឃើញពួកមនុស្សខ្វាក់ក្អែក ក៏និយាយលួងលោមថា ក្នុងស្រុកឈ្មោះឯណោះ របស់ទំពារ របស់បរិភោគរកបានងាយ ពួកអ្នកខ្វាក់ក្អែកទាំងនោះនិយាយថា លោកជួយនាំពួកខ្ញុំទៅឯស្រុកនោះចុះ ពួកខ្ញុំនឹងឲ្យវត្ថុនេះដល់លោក គេទទួលយកតម្លៃឈ្នួល (នាំទៅដល់កណ្តាលផ្លូវ) ក៏ចៀងចុះផ្លូវម្ខាង នាំដើរតាមជុំវិញដង្គត់ឈើធំៗ ហើយឲ្យយកដៃរបស់មនុស្សខ្វាក់ក្អែកដំបូង ចាប់ក្លៀករបស់មនុស្សខ្វាក់ក្អែកខាងក្រោយ ហើយនិយាយថា ខ្ញុំមានការងារបន្តិច ពួកលោកចូរដើរទៅមុន ដូច្នេះ ហើយក៏គេចចេញទៅ ។ មនុស្សខ្វាក់ក្អែកទាំងនោះ នាំគ្នាដើរពេញមួយថ្ងៃ មិនជួបផ្លូវទៅ នាំគ្នាទួញយំថា លោកដ៏ចម្រើន ! ណាអ្នកក្អែកល្អ ឯណាផ្លូវ កាលមិនជួបផ្លូវ ក៏នាំគ្នាស្លាប់នៅក្នុងទីនោះឯង ។ ពាក្យថា **បរម្បរាសត្តា**

គោងគ្នាតៗ ទៅ ទ្រង់ត្រាស់សំដៅដល់មនុស្សខ្វាក់ភ្នែកទាំងនោះ ។ បទថា **បុរិមោបិ** សូម្បីមនុស្សជាន់ដើម សេចក្តីថា បណ្តាព្រាហ្មណ៍ ១០ នាក់ ជំនាន់ដើម សូម្បីព្រាហ្មណ៍ម្នាក់ ។ បទថា **មជ្ឈិមោបិ** សូម្បីមនុស្សជំនាន់កណ្តាល សេចក្តីថា បណ្តាអាចារ្យ និងបាចារ្យក្នុងជំនាន់កណ្តាល សូម្បីអាចារ្យម្នាក់ ។ បទថា **បច្ឆិមោបិ** សូម្បីមនុស្សជំនាន់ក្រោយ សេចក្តីថា បណ្តាព្រាហ្មណ៍ទាំងឡាយក្នុងកាលឥឡូវនេះ សូម្បីព្រាហ្មណ៍ម្នាក់ ។

**[៧២]** បទថា **បញ្ច ខោ** សេចក្តីថា ត្រាស់បន្ថែមធម៌ដទៃ ដែលស្រដៀងគ្នា ៣ ប្រការទៀត ចូលទៅក្នុងធម៌ ២ ប្រការ ដែលមានមកក្នុងព្រះបាលី ។ ពាក្យថា **ទ្វិធា វិបាកា** គឺ មានវិបាកពិត និងមិនមានវិបាក ។

ពាក្យថា **នាលមេត្ថ** (ក្នុងសេចក្តីនេះមិនគួរ) សេចក្តីថា ព្រះមាន-ព្រះភាគទ្រង់តាំងមគ្គ ពាក្យសួរទុកយ៉ាងខ្ពស់ថា ម្នាលភារទ្វាជៈ វិញ្ញូជនកាលបដិបត្តិដោយប្រាថ្នាថា នឹងតាមរក្សាសច្ចៈមិនគួរ គឺ មិនសមគួរដល់ការចូលចិត្តដោយចំណែកតែម្យ៉ាង យ៉ាងនេះថា វត្ថុដែលយើងប្រកាន់ប៉ុណ្ណោះពិត វត្ថុដទៃទទេ ។

**[៧៤]** ពាក្យថា **ឥធ ភារទ្វាជ ភិក្ខុ** (ម្នាលភារទ្វាជៈ ភិក្ខុក្នុងសាសនានេះ) សេចក្ដីថា ត្រាស់សំដៅដល់ព្រះអង្គឯង ដូចក្នុងជីវកសូត្រនិងមហាវច្ឆសូត្រ ។ ពាក្យថា **លោភនីយេសុ ធម្មេសុ** សេចក្ដីក្នុងធម្មៈ គឺ សេចក្ដីលោភ ។ សូម្បីក្នុងពីរបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ ពាក្យថា **សទ្ធំ និវេសេតិ** សេចក្ដីថា ដោយសទ្ធា រមែងជ្រះថ្លាដោយសទ្ធាដែលតាំងទុក ។ បទថា **ឧបសង្កមិតិ** ប្រែថា ចូលទៅរក ។ បទថា **បយិរុបាសតិ** ប្រែថា អង្គុយក្នុងទីជិត ។ បទថា **សោតំ** បានដល់ ផ្ទៀងសោតបសាទ ។

បទថា **ធម្មំ** គឺ ស្ដាប់ធម្មទេសនា ។ បទថា **ធារេតិ** សេចក្ដីថា ធ្វើឲ្យស្ទាត់ជំនាញដោយការទ្រទ្រង់ទុក ។ បទថា **ឧបបរិក្ខតិ** សេចក្ដីថា ពិចារណាដោយអត្ថៈ និងហេតុ ។

ពាក្យថា **និជ្ឈានំ ខមន្តិ** សេចក្ដីថា រមែងគួរពិចារណាមើល ។ អធិប្បាយថា រមែងប្រាកដបានយ៉ាងនេះថា សីល ត្រាស់ទុកក្នុងទីនេះ សមាធិ ត្រាស់ទុកក្នុងទីនេះ ។ សេចក្ដីពេញចិត្ត គឺ សេចក្ដីត្រូវការដែលនឹងធ្វើ ឈ្មោះថា ឆន្ទៈ ។ បទថា **ឧស្សាហតិ** គឺ រមែងព្យាយាម ។

ពាក្យថា **តុលេតិ** សេចក្ដីថា រមែងពិចារណាដោយអំណាចអនិច្ច-

លក្ខណៈជាដើម ។

បទថា **បទហតិ** គឺ រមែងតាំងសេចក្តីព្យាយាមក្នុងមគ្គ ។ ពាក្យថា **កាយេន ចេវ បរមត្ថសច្ចំ** (ធ្វើឲ្យច្បាស់បរមត្ថសច្ចៈដោយកាយ) សេចក្តីថា ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានដោយនាមកាយដែលជាសហជាត និងជម្រះកិលេសដោយបញ្ញា រមែងឃើញច្បាស់នូវព្រះនិព្វាននោះឯង ប្រាកដជាក់ច្បាស់ ។ បទថា **សច្ចានុពោធោ** គឺ ការត្រាស់ដឹងមគ្គ ។ បទថា **សច្ចានុបត្តិ** គឺ ធ្វើឲ្យជាក់ច្បាស់នបូវផល ។

**[៧៥]** បទថា **តេសំ យេវ** គឺ ធម៌ ១២ ប្រការ ដែលពោលទុកហើយក្នុងខាងក្រោយ ។ លោករមែងអនុលោមការពោលដល់មគ្គ យ៉ាងវែងយ៉ាងនេះ ព្រោះដូច្នោះ ទើបមិនមានអធិប្បាយដូច្នេះ ។ បទថា **ចំណែកការអធិប្បាយថា ទាំងនោះឯង** បានដល់ ធម៌ដែលសម្បយុត្តដោយមគ្គទាំងនោះ ។

**[៧៦]** បទថា **បធានំ** គឺ សេចក្តីព្យាយាមក្នុងមគ្គ ។ ក៏សេចក្តីព្យាយាមក្នុងមគ្គនោះ មានឧបការៈច្រើនដល់ការចាក់ធ្លុះសច្ចៈ ពោលគឺការធ្វើឲ្យជាក់ច្បាស់នូវផល ព្រោះកាលមគ្គមិនមាន ផលក៏មិនមាន ហេតុ

*នោះ គប្បីជ្រាបសេចក្តីក្នុងបទទាំងពួងដោយន័យនេះ ។ ពាក្យដ៏សេសក្នុងបទទាំងពួង ក៏ងាយទាំងអស់នោះឯង ។*

" ចប់អដ្ឋកថា ចង្កីសូត្រទី ៥ "

# អ ដ្ឋ ក ថា

## ឯសុការីសូត្រទី ៦

**[៧៨]** *ឯសុការីសូត្រ មានពាក្យផ្ដើមថា* **ឯវម្មេ សុតំ** *ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ៖*

**[៨៣]** *បណ្ដាបទទាំងនោះ ពាក្យថា* **វិសំ ឱលគេយ្យុំ** *គឺ គប្បីប្រគល់ចំណែកឲ្យ ។ ទ្រង់សម្ដែងឈ្មោះថា* **សត្ថធម្ម** *គឺ ធម៌របស់ឈ្មួញរទេះ ដោយពាក្យនេះ ។ បានឮថា ឈ្មួញរទេះធ្វើដំណើរតាមផ្លូវកន្ដារ ។ កាលគោស្លាប់ក្នុងរវាងផ្លូវ ក៏កាន់យកសាច់វាមកហើយ ប្រគល់ឲ្យសម្រាប់អ្នកត្រូវការសាច់ទាំងពួងថា នរណាៗ ទំពារស៊ីសាច់នេះ ចូរឲ្យតម្លៃប៉ុណ្ណេះ ។ ធម្មតាថា សាច់គោ អ្នកស៊ីបានក៏មាន ស៊ីមិនបានក៏មាន អ្នកអាចឲ្យដើមក៏មាន អ្នកមិនអាចក៏មាន ។ ឈ្មួញរទេះទិញគោមកដោយតម្លៃណា ដើម្បីឲ្យតម្លៃនោះ ទើបឲ្យចំណែកដល់មនុស្សទាំងពួងដោយការធ្វើស្រេចហើយយកតែដើម ។ នេះជាធម៌របស់ឈ្មួញរទេះ ។ ដើម្បីសម្ដែងថា សូម្បីពួកព្រាហ្មណ៍ទាំងឡាយ ក៏យ៉ាងនោះដូចគ្នា កាន់យកបដិញ្ញានៃលោកហើយ*

បញ្ញត្តិការបម្រើ ៤ ប្រការ ដោយធម្មតារបស់ខ្លួនឯង ដូច្នេះ ទើបត្រាស់ថា យ៉ាងនោះដូចគ្នា ដូច្នេះជាដើម ។ ពាក្យថា **បាបិយោ អស្ស** គឺ មានសេចក្តីអាក្រក់យ៉ាងក្រៃលែង ។

ពាក្យថា **សេយ្យោ អស្ស** គប្បីមានតែសេចក្តីល្អ គឺ គប្បីមានតែប្រយោជន៍ជួយសង្គ្រោះ ។ ម្យ៉ាងទៀត បទថា **បាបិយោ** អាក្រក់ គឺ មានអត្តភាពអាក្រក់ គឺ មានអត្តភាពដ៏លាមក ។

បទថា **សេយ្យោ** គឺ ប្រសើរ បានដល់ ខ្ពង់ខ្ពស់ ។ បទថា **សេយ្យោ** គឺ ប្រសើរ ព្រោះភាពជាអ្នកកើតក្នុងត្រកូលខ្ពង់ខ្ពស់ គឺ ប្រសើរ ព្រោះជាអ្នកកើតក្នុងត្រកូលស្តុកស្តម ។ បទថា **ឋោកទាប** គឺ អាក្រក់ ។ ភាពជាអ្នកកើតក្នុងត្រកូលខ្ពស់ខ្ពស់ រមែងគួរក្នុងត្រកូលទាំងពីរ គឺ ត្រកូលក្សត្រិយ៍ និងត្រកូលព្រាហ្មណ៍ ។ ភាពជាអ្នកមានវណ្ណៈដ៏ក្រៃលែង រមែងគួរដល់ត្រកូលទាំងបី ព្រោះសូម្បីវេស្សៈ ក៏មានវណ្ណៈក្រៃលែងបាន ។ ភាពជាអ្នកមានភោគៈច្រើន រមែងគួរសូម្បីក្នុងត្រកូលទាំង ៤ ។ ព្រោះសូម្បីសូទ្រៈ ដរាបដល់ទីបំផុតសូម្បីមនុស្សចណ្ឌាល ក៏រមែងជាអ្នកមានភោគៈច្រើនបានដូចគ្នា ។ បទថា **ត្រាច់ទៅដើម្បីភិក្ខា** សេចក្តីថា ព្រាហ្មណ៍

សូម្បីមានទ្រព្យជាកោដិ ក៏ត្រូវត្រាច់សូមភិក្ខា ។ ព្រាហ្មណ៍ក្នុងកាលមុន សូម្បីមានទ្រព្យ ៨០ កោដិ ក៏រមែងត្រាច់រកភិក្ខាម្ដងដែរ ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ការរិះគន់ថា ឥឡូវនេះផ្ដើមត្រាច់សូមភិក្ខា ដូច្នេះ នឹងមិនមានដល់បុរាណព្រាហ្មណ៍ទាំងឡាយ ក្នុងវេលាក្រខ្សត់ ។ បទថា **មើលងាយ** សេចក្ដីថា ព្រាហ្មណ៍លះវង្ស ត្រាច់ភិក្ខាហើយចិញ្ចឹមជីវិតដោយសត្ថាជីវិត (អាជីវៈលក់សស្ត្រា) កសិកម្ម និងពាណិជកម្មជាដើម នេះឈ្មោះថា មើលងាយ ។ បទថា **ដូចអ្នកចិញ្ចឹមគោ** សេចក្ដីថា ដូចជាអ្នកចិញ្ចឹមគោ លួចរបស់ដែលខ្លួនត្រូវរក្សា ជាអ្នកធ្វើក្នុងវត្ថុដែលមិនមែននាទី ដូច្នោះ ។ គប្បីជ្រាបសេចក្ដីក្នុងវារៈទាំងពួងដោយន័យនេះ ។ បទថា **កាំបិត និងអម្រែក** គឺ កណ្ដៀវសម្រាប់ច្រូតស្មៅ និងអម្រែក ។ បទថា **រលឹកដល់** សេចក្ដីថា រលឹកដល់វង្សត្រកូលចាស់ ដែលជារបស់មាតាបិតាដែលខ្លួនកើតមក ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយទាំងអស់នោះឯង ។

" ចប់អដ្ឋកថា ឋសុការីសូត្រទី ៦ "

# អ ដ្ឋ ក ថា

## ធនញ្ជានិសូត្រទី ៧

[៨៩] ធនញ្ជានិសូត្រ មានពាក្យផ្តើមថា ឯវម្មេ សុតំ ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ៖

បណ្តាបទទាំងនោះ បទថា ក្នុងទក្ខិណាគិរីជនបទ សេចក្តីថា ភ្នំឈ្មោះ គិរី ។ ពាក្យនេះ ជាឈ្មោះរបស់ជនបទក្នុងផ្នែកខាងទិសទក្សិណនៃភ្នំដែលឈោមព័ទ្ធក្រុងរាជគ្រឹះ ។

[៩០] បទថា ទ្វារតណ្ឌុលបាល សេចក្តីថា ក្រុងរាជគ្រឹះមានទ្វារធំ ៣២ ទ្វារតូច ៦៤ ។ បណ្តាទ្វារទាំងនោះ ទ្វារមួយកន្លែងឈ្មោះថា ទ្វារតណ្ឌុបាលៈ ។ ព្រះធម្មសង្គាហកាចារ្យ ពោលសំដៅយកទ្វារតណ្ឌុបាលៈនោះ ។ ពាក្យថា អាស្រ័យព្រះរាជា សេចក្តីថា ធនញ្ជានិព្រាហ្មណ៍ ដែលព្រះរាជាទ្រង់បញ្ជូនទៅថា ចូរទៅយកចំណែកស្រូវដំណើប ដោយមិនបៀតបៀនមហាជន តែគេទៅយកស្រូវដំណើបទាំងអស់ ។ ធញ្ជានិព្រាហ្មណ៍ ត្រូវមហាជននិយាយថា លោកដ៏ចម្រើន កុំធ្វើពួកខ្ញុំឲ្យវិនាស ត្រឡប់ពោលថា

ស្រូវដំណើបដែលសាបព្រោះទុកក្នុងរាជត្រកូលមានតិច ព្រះរាជាទ្រង់បង្គាប់យើងយ៉ាងនេះ ក្នុងវេលាដែលមក ពួកលោកកុំបានទួញយំឡើយ ។ ធនញ្ជានិព្រាហ្មណ៍អាស្រ័យព្រះរាជាយ៉ាងនេះ ឈ្មោះថា រមែងប្លន់ព្រាហ្មណ៍និងអ្នកគហបតីទាំងឡាយ ។ នាំស្រូវចូលស្រុករបស់ខ្លួនដោយចំណែកច្រើន នាំចូលរាជត្រកូល មានប្រមាណតិច ។ គេត្រូវព្រះរាជាសួរថា អ្នកមិនបានធ្វើការបង្ខិតបង្ខំព្រាហ្មណ៍ និងគហបតីទេឬ ក៏ក្រាបទូលថា បពិត្រមហារាជ ក្នុងរដូវនេះ ស្រូវដំណើបមានតិច ព្រោះដូច្នោះ កាលខ្ញុំព្រះអង្គមិនរឹបជាន់យក ទើបមិនបានច្រើន ។ ធនញ្ជានិព្រាហ្មណ៍អាស្រ័យព្រាហ្មណ៍និងគហបតីទាំងឡាយយ៉ាងនេះ ឈ្មោះថា ប្លន់ព្រះរាជា ។ ពាក្យថា **ចូរផឹកទឹកដោះស្រស់** សេចក្តីថា ចូរផឹកទឹកដោះស្រស់តិចៗ ។ ពាក្យថា **នៃកត្តាហារមុន** សេចក្តីថា វេលាកត្តាហារ មានដរាបស្មើនឹងពេលដែលលោកអង្គុយផឹកទឹកដោះស្រស់ ។ ធនញ្ជានិព្រាហ្មណ៍សម្តែងថា ជនទាំងឡាយនឹងនាំអាហារព្រឹកមក ដើម្បីយើងទាំងឡាយក្នុងទីនេះឯង ។

**[៩២]** ក្នុងពាក្យថា **មាតា និងបិតាដូច្នេះជាដើម** គប្បីជ្រាបសេចក្តីដោយន័យនេះថា បិតាមាតាចាស់ជរា ដែលបុត្រគប្បីស្វែងរកកម្រាល និង

គ្រឿងស្លៀកដណ្តប់ទន់ៗ សំពត់សាច់ល្អិត គោជនដែលមានរសឆ្ងាញ់ និង របស់ក្រអូប និងកម្រងផ្កាឈើដែលក្រអូបល្អជាដើម មកចិញ្ចឹម ។ បិតា ធ្វើកិច្ចគ្រប់យ៉ាង មានការងារមង្គល ក្នុងការតាំងឈ្មោះបុត្រ និងជីតា គប្បីចិញ្ចឹមរក្សាបុត្រ និងភរិយា ។ ក៏កាលមិនធ្វើយ៉ាងនេះ ការតិះដៀល រមែងកើតឡើង ។

**[៩៣]** បទថា ***ជាអ្នកមិនប្រព្រឹត្តធម៌*** អធិប្បាយថា កម្ម គឺ ភាព ជាអ្នកមិនមានសីល ៥ ឬមិនមាន សីល ១០ ឈ្មោះថា ***អធម៌*** ក្នុងទីនេះ ។ បទថា ***គប្បីអូសទាញ*** គឺ គប្បីទង់ទាញបុគ្គលនោះទៅទម្លាក់ក្នុងនរក គឺ ទាញចូលទៅកាន់រណ្តៅនរកនោះ ។ ដើម្បីធ្វើទារុណកម្ម មានការឃុំឃាំង ៥ យ៉ាងជាដើម ។ បទថា ***អ្នកប្រព្រឹត្តធម៌*** គឺ អ្នកមានប្រក្រតីធ្វើការងារ មានការភ្ជួររាស់ស្រែ និងការធ្វើជំនួញជាដើម ដែលប្រកបដោយធម៌ ។

**[១១៥]** បទថា ***ស្រាកស្រាន្ត*** គឺ ថយចុះ បានដល់ ធូរស្បើយ ។

បទថា ***ខ្លាំងក្លាឡើង*** គឺ កម្រើកឡើង បានដល់ ចម្រើនឡើង ។

**[១១៧]** បទថា ***ប្រសើរ*** ប្រែថា ប្រសើរជាង ។

**[១១៩]** បទថា ***ថោកទាប*** គឺ អាក្រក់លាមក ។

**[១២០]** *ពាក្យថា ហៃ! សារីបុត្រ ធនញ្ជានិព្រាហ្មណ៍ស្លាប់ហើយ ដូច្នេះ ព្រះមានព្រះភាគ ត្រាស់ចំពោះព្រះថេរៈដោយព្រះបំណងថា អ្នកចូរទៅក្នុងទីនោះ ហើយសម្តែងធម៌ដល់ព្រាហ្មណ៍នោះ ។ សូម្បីព្រះថេរៈក៏ទៅក្នុងខណៈនោះភ្លាម ហើយសម្តែងធម៌ដល់មហាព្រហ្មណ៍ ។ ចាប់ផ្តើមតាំងពីនោះទៅ កាលព្រះថេរៈសូម្បីពោលគាថា ៤ បាទ ក៏មិនពោលដល់សេចក្តីវេចផុតដោយសច្ចៈ ៤ ដូច្នេះ ។*

“ ចប់អដ្ឋកថា ធនញ្ជានិសូត្រទី ៧ ”

# អ ដ្ឋ ក ថា

## វាសេដ្ឋសូត្រទី ៨

**[១២១]** *វាសេដ្ឋសូត្រ មានពាក្យផ្ដើមថា ឯវមេ្វ សុតំ ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ៖*

*បណ្ដាបទទាំងនោះ បទថា ក្នុងជងព្រៃឈ្មោះឥច្ឆានង្គល គឺ ក្នុងជងព្រៃដែលមិនឆ្ងាយពីឥច្ឆានង្គលគ្រាម ។ ជនសម្បូរទាំង ៥ នាក់ មានចង្កីព្រាហ្មណ៍ជាដើម ក៏ជាបុរោហិតរបស់ព្រះបាទបសេនទិកោសល ។ ពាក្យថា ព្រាហ្មណ៍មហាសាលពួកដទៃ ដែលមានឈ្មោះល្បីល្បាញ បានដល់ព្រាហ្មណ៍ពួកដទៃជាច្រើន មានឈ្មោះពោះសំឡេង បានឮថា ព្រាហ្មណ៍ទាំងនោះប្រជុំគ្នាក្នុងកន្លែង ២ រាល់ៗ ៦ ខែ ។ ក្នុងកាលណាត្រូវការនឹងជម្រះជាតិឲ្យបរិសុទ្ធិ ក្នុងកាលនោះ ក៏ប្រជុំគ្នាក្នុងឧក្កដ្ឋគ្រាម ដើម្បីជម្រះជាតិឲ្យបរិសុទ្ធិ ក្នុងសម្នាក់របស់បោក្ខរសាតិ ។ ក្នុងកាលណាត្រូវការនឹងជម្រះមន្តឲ្យបរិសុទ្ធិ ក្នុងកាលនោះ ក៏ប្រជុំគ្នាត្រង់ឥច្ឆានង្គលគ្រាម ។ ក្នុងកាលនេះ ប្រជុំគ្នាត្រង់ឥច្ឆានង្គលគ្រាមនោះ ដើម្បីជម្រះមន្តឲ្យបរិសុទ្ធិ ។*

បទថា **អន្តរាកថា** (ពាក្យដែលនិយាយគ្នាក្នុងចន្លោះ) សេចក្តីថា មានពាក្យយ៉ាងដទៃកើតឡើងក្នុងចន្លោះពាក្យដែលសមគួរ ចំពោះសេចក្តីជាសម្លាញ់នឹងគ្នា អ្នកទាំងពីរ ដើរចង្រ្កម ពោលនៅកថា ។ បទថា **មានសីល** គឺមានគុណ ។ បទថា **សម្បូរណ៍ដោយវត្ត** គឺ ដល់ព្រមដោយការប្រព្រឹត្ត ។

**[១២៣]** ពាក្យថា **បានទទួលអនុញ្ញាតិអំពីអាចារ្យ ទាំងបានបេ្តជ្ញាខ្លួនឯង** សេចក្តីថា ដែលអាចារ្យអនុញ្ញាតយ៉ាងនេះថា អ្នកទាំងឡាយសិក្សាចប់ហើយ ។ បទថា **ពួកយើងជាអ្នកដែលអាចារ្យឲ្យសិក្សាហើយ** សេចក្តីថា ខ្លួនឯងបេ្តជ្ញាហើយយ៉ាងនេះ ។ បទថា **អស្មា** ប្រែថា រមែងជា ។

ដោយពាក្យថា **ខ្ញុំព្រះអង្គជាសិស្សរបស់បោក្ខរសាតិព្រាហ្មណ៍** មាណពនេះ ជាសិស្សរបស់តារុក្ខព្រាហ្មណ៍ វាសេដ្ឋមាណពសម្តែងថា ខ្ញុំព្រះអង្គជាសិស្សអ្នកច្បង គឺ ជាសិស្សកំពូលលើសរបស់បោក្ខរសាតិព្រាហ្មណ៍ មាណពនេះជាសិស្សអ្នកច្បង គឺ ជាសិស្សកំពូលលើសរបស់តារុក្ខព្រាហ្មណ៍ ។ បទថា **អ្នកទ្រទ្រង់វិជ្ជា ៣** បានដល់ ព្រាហ្មណ៍អ្នកទ្រទ្រង់ត្រៃវេទ ។ ពាក្យថា **បទណាដែលព្រាហ្មណ៍ទាំងឡាយប្រាប់ហើយ** សេចក្តីថា បទណា សូម្បីតែមួយបទដែលព្រាហ្មណ៍ទាំងឡាយបង្រៀនហើយ ទាំងដោយ

អត្ថ និងព្យញ្ជនៈ ។ ពាក្យថា **ជាអ្នកមានសេចក្តីស្ទាត់ជំនាញក្នុងមន្តនោះ** សេចក្តីថា ខ្ញុំព្រះអង្គទាំងពីរ ជាអ្នកដល់សេចក្តីសម្រេចក្នុងបទនោះ ព្រោះដឹងបទនោះទាំងអស់ ។

ឥឡូវនេះ វាសេដ្ឋមាណពនោះ កាលនឹងធ្វើឲ្យច្បាស់ដល់ភាពជាអ្នកស្ទាត់ជំនាញ ទើបពោលថា **បទកស្មា** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ ពីរបទថា **ក៏ប្រាកដស្មើនឹងអាចារ្យត្រង់កន្លែងជាទីពោលមន្ត** សេចក្តីថា ខ្ញុំព្រះអង្គទាំងពីរ ដូចគ្នានឹងអាចារ្យក្នុងទីដែលពោលមន្ត ។ បទថា **ព្រោះកម្ម** បានដល់ កម្ម គឺ កុសលកម្មបថ ១០ ក៏វាសេដ្ឋមាណពនេះ សំដៅយកកាយកម្ម និងវចីកម្ម ៧ ប្រការខាងដើម ទើបពោលថា កាលណាលោកដ៏ចម្រើនមានសីល ដូច្នេះ ។ សំដៅយកមនោកម្ម ៣ ទើបពោលថា អ្នកដល់ព្រមដោយវត្ត ។ ក៏បុគ្គលដែលប្រកបដោយមនោកម្ម ៣ នោះ រមែងជាអ្នកសម្បូរណ៍ដោយអាចារៈ ។ វាសេដ្ឋមាណព ហៅព្រះមានព្រះ-ភាគថា អ្នកមានព្រះចក្ខុ ព្រោះជាអ្នកមានចក្ខុ ដោយចក្ខុ ៥ ។ បទថា **ពេញវង់** បានដល់ កន្លងហួសនូវភាពខ្វះ អធិប្បាយថា បរិបូណ៌ ។ បទថា **ចំពោះទៅរក** បានដល់ ចូលទៅជិត ។

បទថា **ថ្វាយបង្គំ** គឺ ធ្វើការនមស្ការ ។ ពាក្យថា **ដែលមានដួងចក្ខុកើតឡើងបរិសុទ្ធិក្នុងលោក** សេចក្ដីថា ជាដួងចក្ខុដែលសម្ដែងប្រយោជន៍បច្ចុប្បន្នជាដើមដល់សត្វលោក ដែលកើតឡើង កម្ចាត់ភាពងងឹតនោះ ដែលងងឹតព្រោះអវិជ្ជា ។

**[១២៨]** ព្រះមានព្រះភាគ ដែលវាសេដ្ឋមាណពសរសើរហើយ ទូលអារាធនាយ៉ាងនេះ កាលនឹងទ្រង់សង្គ្រោះជនសូម្បីទាំងពីរ ទើបត្រាស់ព្រះវចនៈមានជាដើមថា តថាគតនឹងប្រាប់ពាក្យយ៉ាងជាក់ច្បាស់ដល់អ្នកទាំងពីរនោះ ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **នឹងប្រាប់យ៉ាងជាក់ច្បាស់** បានដល់ នឹងព្យាករណ៍ ។ បទថា **តាមលំដាប់** សេចក្ដីថា ការគិតរបស់ព្រាហ្មណ៍ចូរលើកទុកចុះ តថាគតនឹងប្រាប់តាមលំដាប់ គឺ ដោយលំដាប់តាំងពីស្មៅ ដើមឈើ មេអំបៅ និងកណ្ដូបជាដើម ។ បទថា **ការបែកជាតិ** គឺ សេចក្ដីពិស្ដាររបស់ជាតិកំណើត ។ ពាក្យថា **ព្រោះជាតិរបស់វាដទៃពីគ្នា** សេចក្ដីថា ព្រោះជាតិកំណើតរបស់សត្វទាំងឡាយនោះៗ ដទៃពីគ្នា គឺ មានប្រការផ្សេងៗ គ្នា ។ បទថា **ស្មៅ និងដើមឈើ** ដូច្នេះ ព្រះមាន-ព្រះភាគ ទ្រង់ផ្ដើមព្រះទេសនានេះថា តថាគតនឹងពោលជាតិកំណើតដែល

មិនមានវិញ្ញាណគ្រប់គ្រង ហើយនឹងពោលដល់ជាតិកំណើតដែលមានវិញ្ញាណគ្រប់គ្រងជាខាងក្រោយ សេចក្តីផ្សេងគ្នានៃជាតិកំណើតនោះ នឹងប្រាកដយ៉ាងនេះ ។

ក៏ព្រះមហាសិវត្ថេរសួរថា លោកដ៏ចម្រើន ការពោលយ៉ាងនេះថា វត្ថុដែលមិនមានវិញ្ញាណគ្រប់គ្រង ឈ្មោះថា ជារបស់ផ្សេងគ្នា ព្រោះមានពូជផ្សេងគ្នា វត្ថុដែលមានវិញ្ញាណគ្រប់គ្រង ក៏ឈ្មោះថា ជារបស់ផ្សេងគ្នា ព្រោះកម្មផ្សេងគ្នា ដូច្នេះ មិនគួរឬ ទើបឆ្លើយថា អើមិនគួរ ។ ព្រោះកម្មតែងញ៉ាំងកំណើតសត្វទាំងនេះឲ្យមានពណ៌ផ្សេងៗ គ្នា ព្រោះការបដិសន្ធិក្នុងកំណើតផ្សេងៗ គ្នា ។ ក្នុងបទថា **ស្មៅ និងដើមឈើ** នេះ មានស្រាយនៅខាងក្នុង ខ្លឹមនៅខាងក្រៅ ដោយហោចទៅសូម្បីត្នោត និងដូងជាដើម ឈ្មោះថា ស្មៅនោះឯង ។ ចំណែកឈើដែលមានខ្លឹមនៅខាងក្នុង ស្រាយនៅខាងក្រៅ ឈ្មោះថា ដើមឈើទាំងអស់ ។ ពាក្យថា **មិនស្គាល់ខ្លួនឯង** សេចក្តីថា រមែងមិនដឹងយ៉ាងនេះថា ពួកយើងជាស្មៅ ពួកយើងជាដើមឈើ ឬថា យើងជាស្មៅ យើងជាដើមឈើ ។ ពាក្យថា **យើងជាតិណជាតិរុក្ខជាតិ** បានដល់ ស្មៅ និងដើមឈើទាំងនោះ សូម្បីមិនដឹងសណ្ឋាន វាក៏

សម្រេចមកពីជាតិទាំងនោះ គឺ ដូចជាស្មៅជាដើម ដែលមានពូជពីដើមរបស់ខ្លួនទុំឯង ។ ព្រោះហេតុអ្វី ។ ព្រោះជាតិរបស់វាផ្សេងៗ គ្នា ។ ព្រោះតិណជាតិផ្សេង រុក្ខជាតិផ្សេង សូម្បីបណ្តាតិណជាតិទាំងឡាយ ជាតិត្នោតផ្សេង ជាតិដូងផ្សេង ។ គប្បីពង្រីកសេចក្តីឲ្យពិស្តារទៅដោយប្រការយ៉ាងនេះ ។ ពាក្យថា ជាតិផ្សេងគ្នានេះ ទ្រង់សម្តែងអត្ថន័យនេះថា វត្ថុណាផ្សេងគ្នាដោយជាតិ វត្ថុនោះសូម្បីវៀរការដឹងខ្លួន ឬការប្រាប់ណែនាំរបស់អ្នកដទៃ ក៏រមែងកាន់យកបានដោយពិសេសថា (វាមាន) ជាតិផ្សេងៗ គ្នា ។ ប្រសិនបើ អ្នកគប្បីជាព្រាហ្មណ៍ពិតៗ ដោយជាតិកំណើត សូម្បីគេវៀរការដឹង ឬការប្រាប់របស់អ្នកដទៃ គប្បីកាន់យកដោយពិសេសពីក្សត្រិយ៍ វេស្ស: ឬសូទ្រ: តែនឹងកាន់យកមិនបានទេ ។ ព្រោះដូច្នោះ បុគ្គលឈ្មោះថា ជាព្រាហ្មណ៍ព្រោះជាតិកំណើតក៏មិនមែន ។ ក៏ព្រះមានព្រះភាគទ្រង់នឹងធ្វើឲ្យជាក់ច្បាស់នូវសេចក្តីនេះ នៃព្រះគាថាថា ក្នុងជាតិកំណើតទាំងនេះ យ៉ាងណា ដូច្នេះ ដោយទ្រង់ថ្លែងព្រះវាចាទុកប៉ុណ្ណោះមួយចំណែក ។ ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងជាតិកំណើតក្នុងវត្ថុដែលមិនមានវិញ្ញាណគ្រប់គ្រងយ៉ាងនេះហើយ កាលទ្រង់នឹងសម្តែងជាតិកំណើតក្នុងវត្ថុដែលមាន

វិញ្ញាណគ្រប់គ្រង អំពីនោះ ទើបត្រាស់ពាក្យមានជាដើមថា កណ្ហូប ដូច្នេះ ។ ពាក្យថា **រហូតដល់ស្រមោចខ្មៅស្រមោចក្រហម** សេចក្តីថា ទ្រង់ធ្វើស្រមោចខ្មៅស្រមោចក្រហមឲ្យជាជាតិចុងបង្អស់ ។ ក៏ក្នុងបណ្តាសត្វទាំងនេះ សត្វដែលលោតទៅ ឈ្មោះថា កណ្ហូប ។ ពាក្យថា **ព្រោះជាតិរបស់វាផ្សេងពីគ្នា** មានសេចក្តីថា ជាតិកំណើតជាប់ដោយវត្ថុដែលមានពណ៌ខៀវ ពណ៌ក្រហមជាដើម របស់សត្វទាំងនោះ ក៏មានប្រការផ្សេងៗ គ្នា ។ បទថា **ខុទ្ទតូច** បានដល់ កំប្រុកជាដើម ។ បទថា **ធំ** បានដល់ ពស់ និងឆ្មាជាដើម ។ បទថា **ពួកសត្វដែលមានពោះជាជើង** សេចក្តីថា មានពោះជាជើង ។ អធិប្បាយថា ពោះនោះឯង ជាជើងរបស់សត្វពួកណា ។ បទថា **មានខ្នងវែង** សេចក្តីថា ពស់ទាំងឡាយមានខ្នងតាំងពីក្បាលរហូតដល់ទីងកន្ទុយ ព្រោះដូច្នោះ ពស់ទាំងនោះ ទើបត្រាស់ហៅថា មានខ្នងវែង ។ បទថា **ក្នុងទឹក** គឺ កើតក្នុងទឹក ។ បទថា **បក្ខី** បានដល់ ពួកសត្វ ។ សត្វទាំងឡាយឈ្មោះថា ទៅដោយស្លាប ព្រោះហើរទៅដោយស្លាបទាំងនោះ ។ ឈ្មោះថា ទៅផ្លូវអាកាស ព្រោះទៅផ្លូវអាកាសកណ្តាលវេហាស៍ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងជាតិតែមួយប្រភេទៗ របស់សត្វ

ដែលទៅផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាសយ៉ាងនេះហើយ ឥឡូវនេះកាល នឹងទ្រង់ប្រាប្តាសម្តែងដល់រឿងជាតិនោះឲ្យជាក់ច្បាស់ ទើបត្រាស់ព្រះគាថា ថា ក្នុងជាតិកំណើតទាំងនេះយ៉ាងណា ដូច្នេះជាដើម ។ សេចក្តីនៃគាថា នោះ ទ្រង់ត្រាស់ទុកដោយសង្ខេបតែម្យ៉ាង ។ តែពាក្យណាដែលនឹងគប្បី ត្រាស់ក្នុងទីនេះដោយពិស្តារ កាលទ្រង់សម្តែងពាក្យនោះដោយព្រះអង្គឯង ទើបត្រាស់ពាក្យថា **មិនមែនដោយសក់** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ មានការប្រកបសេចក្តីដូចតទៅនេះ ៖

ពាក្យណាដែលពោលថា ក្នុងពួកមនុស្ស មិនមានភេទដែលសម្រេច ដោយជាតិកំណើតច្រើន ដូច្នេះ ពាក្យនោះគប្បីជ្រាបថា មិនមានយ៉ាងនេះ ។ គឺ យ៉ាងណា ។ គឺ មិនមែនដោយសក់ទាំងឡាយ ។ ព្រោះមិនមានការ កំណត់ទុកថា ពួកព្រាហ្មណ៍មានសក់ដូច្នេះ ពួកក្សត្រិយ៍ដូច្នេះ ដូចរោមរបស់ ដំរី សេះ និងម្រឹះជាដើម ។ ក៏ព្រះតម្រាស់ថា **ភេទដែលសម្រេចដោយជាតិ** (ក្នុងមនុស្សទាំងឡាយ) មិនដូចក្នុងជាតិកំណើតពួកដទៃ ដូច្នេះ គប្បីជ្រាប ថា ជាពាក្យពោលសរុបសេចក្តីដែលត្រាស់ទុកហើយប៉ុណ្ណោះ បទនោះប្រកប សេចក្តីថា ព្រោះភេទក្នុងមនុស្សទាំងឡាយដែលសម្រេចដោយជាតិជាច្រើន

រមែងមិនមានដោយសក់ជាដើមទាំងនេះ ដោយប្រការយ៉ាងនេះ ព្រោះដូច្នោះ គប្បីជ្រាបភេទនោះថា ក្នុងមនុស្សទាំងឡាយដែលផ្សេងគ្នាដោយជាតិព្រាហ្មណ៍ជាដើម ភេទដែលសម្រេចដោយជាតិ មិនដូចក្នុងជាតិកំណើតពួកដទៃទេ ។

ឥឡូវនេះ ក្នុងកាលសេចក្តីផ្សេងគ្នានៃជាតិ សូម្បីនឹងមិនមានយ៉ាងនេះ ដើម្បីនឹងសម្តែងប្រការដែលកើតសេចក្តីផ្សេងគ្នានេះថា ព្រាហ្មណ៍ក្សត្រិយ៍នោះ ទើបត្រាស់គាថាថា **ជារបស់ចំពោះខ្លួន** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **វោការំ** បានដល់ សេចក្តីផ្សេងគ្នា ។ ក៏ក្នុងពាក្យនេះមានសេចក្តីសង្ខេបដូចតទៅនេះ ៖

ដូចជាសត្វតិរច្ឆានទាំងឡាយ សេចក្តីផ្សេងគ្នាដោយសណ្ឋាន មានរោមជាដើម សម្រេចមកពីកំណើតតែម្តង យ៉ាងណា ចំពោះពួកព្រាហ្មណ៍ជាដើម សេចក្តីផ្សេងគ្នានោះ ក្នុងសរីរៈរបស់ខ្លួន រមែងមិនមាន ដូច្នោះ ។ សូម្បីយ៉ាងនេះ សេចក្តីផ្សេងគ្នាដែលថា ព្រាហ្មណ៍ ក្សត្រិយ៍ ដូច្នេះនោះ ក្នុងពួកមនុស្ស គេហៅគ្នាតាមឈ្មោះ គឺ គេហៅដោយត្រឹមតែថា ផ្សេងគ្នាប៉ុណ្ណោះ ។ ព្រះមានព្រះភាគ ទ្រង់គ្របសង្កត់វាទៈរបស់ការទ្វាជមាណពដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណោះ ឥឡូវនេះ ប្រសិនបើថា អ្នកនឹងជា

ព្រាហ្មណ៍បាន ព្រោះជាតិសោត សូម្បីអ្នកដែលមានអាជីវៈ សីល និងការប្រព្រឹត្តវិនាសអស់ ក៏នឹងជាព្រាហ្មណ៍បាន តែព្រោះហេតុដែលព្រាហ្មណ៍ពីបុរាណ មិនប្រាថ្នាសេចក្តីដែលអ្នកវិនាសអស់នោះ មកជាព្រាហ្មណ៍ និងអ្នកដែលជាបណ្ឌិតសូម្បីដទៃៗ រមែងមាននៅក្នុងលោក ព្រោះដូច្នោះ កាលនឹងទ្រង់លើកតម្កើងវាទៈរបស់វាសេដ្ឋមាណព ទើបត្រាស់គាថា ៨ គាថាថា ព្រោះថា បណ្តាមនុស្សទាំងឡាយ មនុស្សណាមួយ ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ការរក្សាគោ** គឺ ការរក្សាស្រែ ។ អធិប្បាយថា កសិកម្ម ។

ក៏ពាក្យថា **គោ** ជាឈ្មោះរបស់ផែនដី ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនោះ ។ បទថា **ដោយសិល្បៈផ្សេងៗ** បានដល់ សិល្បៈច្រើនយ៉ាងមានការត្បាញជាដើម ។ បទថា **ជំនួញ** បានដល់ ការធ្វើជំនួញ ។ បទថា **ដោយការបម្រើអ្នកដទៃ** គឺ ដោយកម្ម គឺ ការខ្វល់ខ្វាយជួយអ្នកដទៃ ។ បទថា ដោយការកាន់សស្ត្រាវុធ គឺ ការរស់នៅដោយអាវុធ អធិប្បាយថា (អាស្រ័យ) កូនសរ និងសស្ត្រា ។ បទថា ដោយនាទីជាបុរោហិត គឺ ដោយការងាររបស់បុរោហិត ។

ព្រះមានព្រះភាគ កាលទ្រង់ប្រកាសសេចក្ដីដែលអ្នកវិនាសខាងអាជីវៈ សីល និងការប្រព្រឹត្ត ថា មិនមែនព្រាហ្មណ៍ ដោយលទ្ធិរបស់ព្រាហ្មណ៍ និងដោយវោហារនៃលោកយ៉ាងនេះហើយ ទ្រង់ឲ្យព្រមទទួលសេចក្ដីត្រឹមត្រូវនេះ ដោយសេចក្ដីយ៉ាងនេះថា បើដូច្នេះ អ្នករមែងមិនមែនជាព្រាហ្មណ៍ ព្រោះជាតិ តែជាព្រាហ្មណ៍ ព្រោះជាអ្នកចម្រើនដោយគុណ ព្រោះដូច្នោះ បុគ្គលណា កើតក្នុងត្រកូលណាមួយ ជាអ្នកទ្រទ្រង់នូវគុណ បុគ្គលនោះជាព្រាហ្មណ៍ នេះជាសេចក្ដីត្រឹមត្រូវក្នុងអធិការដែលពោលអំពីរឿងព្រាហ្មណ៍នេះ ដូច្នេះ ឥឡូវនេះ កាលនឹងទ្រង់ប្រកាសសេចក្ដីត្រឹមត្រូវនោះ ដោយការថ្លែងពាក្យនិយាយចេញមក ទើបត្រាស់ថា តថាគតក៏មិនហៅថាជាព្រាហ្មណ៍ ដូច្នេះជាដើម ។ សេចក្ដីនៃព្រះតម្រាស់នោះថា ព្រោះតថាគតមិនហៅអ្នកដែលកើតក្នុងកំណើតណាមួយ ក្នុងបណ្ដាកំណើត ៤ ឬអ្នកដែលកើតក្នុងមាតា ដែលព្រាហ្មណ៍លើកតម្កើងសរសើរដោយពិសេសក្នុងកំណើត ៤ សូម្បីនោះ អ្នកកើតពីកំណើត មានមាតាជាដែនកើតនោះ ថាជាព្រាហ្មណ៍ គឺ តថាគតមិនហៅបុគ្គលដែលគេពោលថា កើតពីកំណើត មានមាតាជាដែនកើត ព្រោះជាអ្នកកើតពីកំណើត ដោយមាតាសម្បត្តិក៏ដោយ ដោយ

ជាតិសម្បត្តិក៏ដោយ ដោយពាក្យដែលពោលមកនេះថា កំណើត ពោលគឺ ត្រឹមតែការកើតឡើង ដែលបរិសុទ្ធិរបស់ព្រាហ្មណ៍ ដែលពួកព្រាហ្មណ៍ពោលទុក ដោយន័យមានជាដើមថា អ្នកកើតល្អហើយដោយចំណែកទាំងពីរខាង មានគភ៌ដែលកាន់បដិសន្ធិបរិសុទ្ធិនោះ អ្នកកើតពីកំណើត មានមាតាជាដែនកើតនោះ ថាជាព្រាហ្មណ៍ដោយហេតុត្រឹមតែថា កើតពីកំណើតមានមាតាជាដែនកើតនេះ ។ ព្រោះហេតុអ្វី ។ ព្រោះបុគ្គលនោះ ជាអ្នកឈ្មោះថា **ភោវាទី** មានវាទៈថា អ្នកចម្រើន ព្រោះជាអ្នកវិសេសជាងពួកអ្នកដទៃ អ្នកមានសេចក្តីកង្វល់ ដោយត្រឹមតែពោលថា អ្នកដ៏ចម្រើន អ្នកដ៏ចម្រើន បុគ្គលនោះឯង ជាអ្នកមានសេចក្តីកង្វល់ មានសេចក្តីហួងហែង ។ ចំណែកបុគ្គលណា សូម្បីនឹងកើតក្នុងត្រកូលណាមួយ ឈ្មោះថា អ្នកមិនមានសេចក្តីកង្វល់ ព្រោះមិនមានកិលេសជាគ្រឿងកង្វល់ មានរាគៈជាដើម ឈ្មោះថា អ្នកមិនប្រកាន់មាំ ព្រោះលះបង់សេចក្តីប្រកាន់ទាំងពួង តថាគតហៅបុគ្គលដែលមិនមានសេចក្តីកង្វល់ អ្នកមិនប្រកាន់នោះ ថាជាព្រាហ្មណ៍ ។ ព្រោះហេតុអ្វី ។ ព្រោះជាអ្នកបន្សាត់បាបហើយ ។ ក្រៃលែងជាងបន្តិច គាថា ២៧ ជាដើមថា កាត់សញ្ញោជនៈទាំងពួង ដូច្នេះ ។ បណ្តាបទទាំង

នោះ បទថា **សញ្ញោជនៈទាំងពួង** បានដល់ សញ្ញោជនៈទាំងអស់ គឺ សូម្បី ទាំង ១០ ។ បទថា **រមែងមិនតក់ស្លុត** គឺ រមែងមិនតក់ស្លុតដោយសេចក្តី តក់ស្លុត គឺ តណ្ហា ។ បទថា **កន្ទងបង់នូវគ្រឿងជាប់ជំពាក់** គឺ ឈាន កន្ទងកិលេសគ្រឿងជាប់ជំពាក់ មានរាគៈជាដើម ។ បទថា **អ្នកប្រាសចាក កិលេស** គឺ អ្នកមិនប្រកបដោយកំណើត ៤ ឬដោយកិលេសទាំងពួង ។ បទថា **ខ្សែរឹត** បានដល់ ឧបនាហៈ និងសេចក្តីក្រោធ ។ បទថា **ព្រ័ត្រ** បានដល់ តណ្ហា ។ បទថា **ទី.ត** បានដល់ អន្ទាក់ ។ ពាក្យថា អន្ទាក់នេះ ជាឈ្មោះរបស់កិលេសជាគ្រឿងរួបរឹត គឺ ទិដ្ឋិ ។ ចំណងដែលស៊កចូល ក្នុងអន្ទាក់ ហៅថា ខ្សែចំណង ក្នុងពាក្យថា **សហានុក្កមំ** នេះ ។ ពាក្យនេះ ជាឈ្មោះរបស់ទិដ្ឋានុស័យ ។ ក្នុងពាក្យថា **មានបង្គោល** ដែលដកចេញ ហើយ អវិជ្ជា ឈ្មោះថា បង្គោល ។ បទថា **អ្នកត្រាស់ដឹង** បានដល់ ត្រាស់ដឹងសច្ចៈទាំង ៤ ។ បទថា **អត់ទ្រាំ** គឺ រមែងអត់ធន់ ។ បទថា **អ្នកមានខន្តិជាកម្លាំង** គឺ មានអធិវាសនខន្តិជាកម្លាំង ។ ក៏ខន្តិនោះ កើត ឡើងតែមួយដង មិនឈ្មោះថា ជាកម្លាំង ដូចពួកពល តែកើតរឿយៗ ទើបជាកម្លាំង ។ ឈ្មោះថា មានកម្លាំងដូចពួកពល ព្រោះមានអធិវាសន-

ខន្តិនោះ ។ បទថា **អ្នកមានធម៌ជាគ្រឿងកម្ចាត់បង់** គឺ មានធុតង្គវត្ត ។ បទថា **មានសីល** គឺ មានគុណ ។ បទថា **អ្នកមិនមានកិលេសជាគ្រឿងប៉ោងឡើង** គឺ ប្រាសចាកកិលេសជាគ្រឿងប៉ោងឡើង មានរាគៈជាដើម ។ បាលីថា **អនុស្សុតំ** ដូច្នេះក៏មាន ។ អត្ថន័យថា អ្នកមិនត្រូវកិលេសរួបរឹត ។ បទថា **អ្នកទូន្មានហើយ** គឺ មិនមានពុតត្បុត ។ បទថា **មិនបូកលាប** គឺ រមែងមិនជាប់ ។ បទថា **ក្នុងកាមទាំងឡាយ** បានដល់ ក្នុងកិលេសកាម និងវត្ថុកាម ។ **ព្រះអរហត្ត** លោកប្រាថ្នាយកថា ធម៌ជាទីអស់ទុក្ខ ក្នុងព្រះបាលីនោះថា រមែងដឹងច្បាស់នូវធម៌ជាទីអស់ទុក្ខក្នុងភពនេះឯង ដូច្នេះ ។ បទថា **រមែងដឹងច្បាស់** មានសេចក្តីថា ដឹងដោយអំណាចការសម្រេច ។ បទថា មានភារៈដាក់ចុះហើយ គឺ អ្នកមានភារៈដែលដាក់ចុះហើយ បានដល់ ធ្វើភារៈ គឺ ខន្ធ កិលេស អភិសង្ខារ និងកាមគុណ ចុងផុតហើយតាំងនៅ ។ បទដែលមិនប្រកប មានសេចក្តីពោលទុកហើយនោះឯង ។

បទថា **មានបញ្ញាជ្រាលជ្រៅ** គឺ មានបញ្ញាដែលទៅហើយក្នុងអារម្មណ៍ដ៏ជ្រាលជ្រៅ ។ បទថា **អ្នកមានប្រាជ្ញា** បានដល់ អ្នកមានបញ្ញាដោយបញ្ញាតាមប្រក្រតី ។ ពាក្យថា **គ្រហស្ថ និងបព្វជិតទាំងពីរពួក** សេចក្តី

ថា អ្នកមិនច្រឡូកច្របល់ដោយគ្រហស្ថ និងបព្វជិត អធិប្បាយថា អ្នកមិនច្រឡូកច្របល់ដាច់ខាតក្នុងជនទាំងពីរពួក គឺ គ្រហស្ថ និងបព្វជិត សូម្បីទាំងពីរពួកទាំងនោះ ។ ក្នុងបទថា **អ្នកមិនអាល័យ** សេចក្តីថា សេចក្តីអាល័យក្នុងកាមគុណ ៥ ហៅថា **ឱកៈ** អ្នកមិនអាល័យ គឺ កាមគុណ ៥ នោះ ។

បទថា **អ្នកមានសេចក្តីប្រាថ្នាតិច** គឺ អ្នកមិនមានសេចក្តីប្រាថ្នា ។ បទថា **អ្នកមានសេចក្តីតក់ស្លុត** គឺ អ្នកមានតណ្ហា ។ បទថា **អ្នកមានសេចក្តីខ្ជាប់ខ្ជួន** គឺ អ្នកមិនមានតណ្ហា ។ បទថា **អ្នកមានអាជ្ញាក្នុងខ្លួន** គឺ អ្នកកាន់អាជ្ញា ។ បទថា **អ្នករលត់ហើយ** គឺ រលត់ហើយ ដោយការរលត់កិលេស ។ បទថា **អ្នកមានសេចក្តីប្រកាន់** គឺ អ្នកមានសេចក្តីប្រកាន់មាំ ។ បទថា **ដាក់ចុះហើយ** ប្រែថា ឲ្យធ្លាក់ទៅ ។ បទថា **មិនរឹងរូស** គឺ មិនមានទោស ។ ព្រោះសូម្បីដើមឈើដែលមានទោស ក៏ហៅថា មានសេចក្តីរឹងប៉ឹង ។ បទថា **ជាវាចាញ៉ាំងអ្នកដទៃឲ្យស្គាល់** គឺ ញ៉ាំងអ្នកដទៃឲ្យដឹងប្រយោជន៍ បានដល់ មិនស៊ីកសៀត ។ បទថា **ជាវាចពិត** គឺ មិនឃ្លៀងឃ្លាត ។ បទថា **ថ្លែង** គឺ ពោល ។ ពាក្យថា **មិនបានធ្វើអ្នកដទៃណាមួយ**

ឲ្យជំពាក់ដោយវាចាណា សេចក្ដីថា រមែងពោលវាចាមិនគ្រោតគ្រាត មិនជាហេតុធ្វើឲ្យអ្នកដទៃជាប់ចិត្ត ឬជំពាក់ចិត្ត ដូច្នោះ ។ ទ្រង់សំដែងវត្ថុដូចក្រងអំបោះទុក ដោយពាក្យថា វែង ។ ទ្រង់សំដែងវត្ថុដែលខ្វាត់ខ្វាយទៅដោយពាក្យថា ខ្លី ។ បទថា **តូច** គឺ ល្អិត ។ បទថា **ថូលៈ** ប្រែថា ធំ ។ បទថា **ល្អ ឬអាក្រក់** គឺ ស្អាត ឬមិនស្អាត ។ ព្រោះវត្ថុ (ដែលក្រងជាកម្រង) វែង មានតម្លៃតិចខ្លះ ច្រើនខ្លះ ។

សូម្បីក្នុងវត្ថុខ្លីនោះ ក៏មានន័យនេះដូចគ្នា ។ ដូច្នោះ ដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណេះ ទ្រង់មិនបានកំណត់កាន់យកវត្ថុទាំងអស់ទេ តែទ្រង់កំណត់កាន់យកដោយវត្ថុនេះដែលថា ល្អ ឬអាក្រក់ ។ បទថា **មិនមានសេចក្ដីប្រាថ្នា** គឺ មិនមានចំណង់ ។ បទថា **សេចក្ដីអាល័យ** បានដល់សេចក្ដីអាល័យ គឺ តណ្ហា ។

បទថា **ជាអ្នកដឹងច្បាស់** គឺ ជាអ្នកជាក់ច្បាស់ ។ បទថា **បានសម្រេចព្រះនិព្វាន** គឺ ខាងក្នុងអមតធម៌ ។ បទថា **ដល់ហើយដោយលំដាប់** បានដល់ ចូលទៅហើយដោយលំដាប់ ។ បទថា **ធម៌ជាគ្រឿងជំពាក់ទាំងពីរ** គឺ ធម៌ជាគ្រឿងជំពាក់សូម្បីទាំងពីរនោះ ។ ព្រោះថា បុណ្យ រមែងធ្វើឲ្យ

សត្វជាប់ជំពាក់ក្នុងសួគ៌ បាប រមែងញុំាងសត្វឲ្យជំពាក់នៅក្នុងអបាយ ។ ព្រោះដូច្នោះ ទើបត្រាស់ថា ធម៌ជាគ្រឿងជាប់ជំពាក់សូម្បីទាំងពីរនោះ ។ បទថា **កន្ទ្រង់បង់** គឺ ឈានកន្លងទៅហើយ ។ បទថា **មិនកករល្អក់** គឺ វៀរចាកកិលេសដែលធ្វើឲ្យកករល្អក់ ។ បទថា **អ្នកមានតម្រេកក្នុងភពអស់ហើយ** បានដល់ មានសេចក្តីត្រេកអរទៅប្រាស់ហើយ មានភពទៅប្រាស់ហើយ ។ ដោយគាថាថា **យោ ឥមំ** សេចក្តីថា អវិជ្ជានុ៎ះឯង លោកពោលថា ឈ្មោះថា **ដូចផ្លូវរអិល** ព្រោះអត្ថថា ធ្វើឲ្យឃ្លៀងឃ្លាត ឈ្មោះថា **ដូចល្បាប់កក់** ព្រោះជារបស់ដែលដកឡើងបានដោយលំបាក ឈ្មោះថា **សង្សារ** ព្រោះអត្ថថា អន្ទោលទៅ (និង) ឈ្មោះថា **មោហៈ** ព្រោះអត្ថថា ល្ងង់ខ្លៅ ។ បទថា **ឆ្លងហើយ** គឺ ឆ្លងឱឃៈទាំង ៤ ។ ពាក្យថា **ដល់ត្រើយ** គឺ ដល់ព្រះនិព្វាន ។ បទថា **មានប្រក្រតីសម្លឹង** គឺ មានប្រក្រតីសម្លឹង ដោយអំណាចសម្លឹងអារម្មណ៍ និងលក្ខណៈ ។ បទថា **អ្នកមិនញាប់ញ័រ** គឺ មិនមានតណ្ហា ។ ពាក្យថា **រលត់ហើយ ព្រោះមិនប្រកាន់មាំ** បានដល់ រលត់ហើយ ដោយការរលត់កិលេសទាំងពួង ព្រោះមិនប្រកាន់អ្វីតិចតួច ។ បទថា **កាមទាំងឡាយ** បានដល់ កាមសូម្បីទាំងពីរ ។

បទថា **មិនមានផ្ទះ** ប្រែថា ជាអ្នកមិនមានផ្ទះ ។ បទថា **វៀរ** ប្រែថា វៀរគ្រប់ផ្នែក ។ បទថា **មានកាម និងភពអស់ហើយ** គឺ អស់កាម អស់ភព ។ ពាក្យថា **ធម៌ជាគ្រឿងប្រកបរបស់មនុស្ស** បានដល់ កិលេសជាគ្រឿងប្រកប គឺ កាមគុណ ៥ ដែលជារបស់មនុស្ស ។ បទថា **ធម៌ជាគ្រឿងប្រកបដែលជាទិព្វ** គឺ កិលេសជាគ្រឿងប្រកប គឺ កាមគុណ ៥ ដែលជាទិព្វ ។ បទថា **ដែលប្រាសចាកធម៌ជាគ្រឿងប្រកបទាំងអស់** សេចក្តីថា ប្រាសចាកកិលេសជាគ្រឿងប្រកបទាំងពួង ។

បទថា **តម្រេក** គឺ ការត្រេកអរក្នុងកាមគុណ ៥ ។ បទថា **សេចក្តីអផ្សុក** បានដល់ មិនពេញចិត្តក្នុងកុសលភាវនា ។ បទថា **អ្នកក្លៀវក្លា** គឺ មានសេចក្តីព្យាយាម ។ បទថា **មានដំណើរល្អ** គឺ ទៅកាន់ស្ថានទីល្អ ឬដំណើរទៅដោយវត្តបដិបត្តិដែលល្អ ។ បទថា **គតិ** គឺ សេចក្តីសម្រេច ។ បទថា **បុរេ** បានដល់ ក្នុងអតីត ។ បទថា **បច្ឆា** គឺ ក្នុងអនាគត ។ បទថា **មជ្ឈេ** គឺ ក្នុងបច្ចុប្បន្ន ។ បទថា **កង្វល់** គឺ កិលេសជាគ្រឿងធ្វើឲ្យកង្វល់ ។ បទថា **អ្នកស្វែងរកគុណដ៏ធំ** គឺ ឈ្មោះថា អ្នកស្វែងរកគុណដ៏ក្រៃលែង ព្រោះស្វែងរកគុណដ៏ធំ ។ បទថា **អ្នកមានជ័យជំនះ** គឺ អ្នកមានការឈ្នះ

ហើយ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងចំពោះព្រះវិណាស្រេព ប៉ុណ្ណោះថា ជាព្រាហ្មណ៍ដោយគុណយ៉ាងនេះហើយ កាលនឹងទ្រង់សម្ដែងថា បុគ្គលណាធ្វើការប្រកាន់ថា ជាព្រាហ្មណ៍ព្រោះជាតិ ដូច្នេះ បុគ្គលនោះ មិនដឹងការប្រកាន់នេះថា ជាទិដ្ឋិយ៉ាងនោះ របស់បុគ្គលទាំងនោះ ជាទិដ្ឋិអាក្រក់ ទើបត្រាស់ពីរគាថា ថា ដែលឈ្មោះថា ដូច្នេះ ។ សេចក្ដីរបស់ពីរគាថានោះថា នាម និងគោត្រ ដែលគេកំណត់តាំងទុក តាក់តែងទុកថា ព្រាហ្មណ៍ ក្សត្រិយ៍ ការទ្វាជៈ វាសេដ្ឋៈនោះ យ៉ាងនោះ ជាឈ្មោះ (ហៅគ្នា) ក្នុងលោក អធិប្បាយថា ត្រឹមតែជាវោហារ ។ ព្រោះហេតុអ្វី ។ ព្រោះសន្មតិហៅគ្នា គឺ មកដោយកំណត់ ព្រោះនាម និងគោត្រនោះ ញាតិសាលោហិតកំណត់ តាំងទុក ក្នុងវេលាដែលគេកើតក្នុងទីនោះៗ ។ បើមិនកំណត់នាម និងគោត្រនោះទុកយ៉ាងនោះ អ្នកណាៗ ឃើញអ្នកណាៗ ក៏នឹងមិនដឹងថា អ្នកនេះជាព្រាហ្មណ៍ ឬថា ជាការទ្វាជៈ ។ ក៏នាម និងគោត្រនោះដែលគេកំណត់ទុកយ៉ាងនោះ កំណត់ទុកដើម្បីដឹងថា ទិដ្ឋិដែលដេកជាប់នៅអស់កាលយូរនោះ ទិដ្ឋិដែលដេកជាប់នៅអស់កាលយូរក្នុងសន្ដានរបស់

សត្វទាំងឡាយដែលមិនដឹងថា នោះត្រឹមតែជានាម និងគោត្រ ដែលគេកំណត់ទុកដើម្បីហៅគ្នា អធិប្បាយថា ព្រោះទិដ្ឋិនោះដេកជាប់នៅ អ្នកមិនដឹងនាម និងគោត្រនោះ គឺ មិនដឹងថា ជាព្រាហ្មណ៍ ក៏និយាយយ៉ាងនេះថា អ្នកនេះជាព្រាហ្មណ៍ព្រោះជាតិ ដូច្នេះ ។

ព្រះមានព្រះភាគទ្រង់សម្តែងថា បុគ្គលដែលប្រកាន់មាំថា ជាព្រាហ្មណ៍ដោយជាតិនោះ មិនដឹងថា ការហៅគ្នានេះ ទិដ្ឋិនោះ របស់អ្នកទាំងនោះជាទិដ្ឋិអាក្រក់ ដូច្នេះ ឥឡូវនេះ កាលនឹងទ្រង់បដិសេធវាទៈ ពោលអំពីជាតិយ៉ាងដាច់ខាត និងទ្រង់តាំងវាទៈពោលអំពីកម្ម ទើបត្រាស់ពាក្យជាដើមថា មិនមែនព្រោះជាតិ ដូច្នេះ ។ ដើម្បីពង្រីកសេចក្តីនៃកន្លះគាថា ដែលថា ព្រោះកម្មដូច្នេះ ក្នុងព្រះតម្រាស់នោះ ទើបត្រាស់ពាក្យថា ជាអ្នកស្រែព្រោះការងារ ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **ព្រោះការងារ** បានដល់ ព្រោះកម្ម គឺ ចេតនា ដែលញុំាងការងារ មានកសិកម្មជាដើមជាបច្ចុប្បន្ន ។ បទថា **បដិច្ចសមុប្បាទ** បានដល់ មានប្រក្រតីឃើញបដិច្ច-សមុប្បាទយ៉ាងនេះថា មានយ៉ាងនេះ ព្រោះបច្ច័យនេះ ។ បទថា **អ្នកដឹងក្នុងកម្ម និងផលរបស់កម្ម** សេចក្តីថា អ្នកឆ្លាតក្នុងកម្ម និងផលរបស់កម្ម

យ៉ាងនេះថា រមែងមានការឧប្បត្តិក្នុងត្រកូលដែលគួរដល់ការរាប់អាន និង មិនគួររាប់អាន ព្រោះអំណាចកម្ម សេចក្តីអាក្រក់ និងសេចក្តីល្អសូម្បីដទៃៗ រមែងមានក្នុងកាលកម្មអាក្រក់ និងកម្មល្អឲ្យផល ។ ក៏ព្រះគាថាថា រមែង ប្រព្រឹត្តទៅព្រោះកម្ម ដូច្នេះ មានអត្ថន័យតែមួយប៉ុណ្ណោះថា មនុស្ស ឬ ពួកសត្វ ឬថា សត្វ ។ ផ្សេង គ្នាត្រឹមតែពាក្យ ។ ក៏ក្នុងព្រះគាថានេះ ដោយ បទដំបូង គប្បីជ្រាបការបដិសេធទិដ្ឋិថា មានព្រហ្ម មហាព្រហ្មដ៏ប្រសើរ ជាអ្នកបង្កើត ។ សត្វរមែងប្រព្រឹត្តទៅក្នុងគតិនោះៗ ព្រោះកម្ម អ្នកណា នឹងជាអ្នកបង្កើតលោកនោះ ។ ដោយបទទីពីរ ទ្រង់សម្តែងថា សូម្បីកើត ព្រោះកម្មយ៉ាងនេះ ក៏ប្រព្រឹត្តទៅ និងរមែងប្រព្រឹត្តទៅព្រោះកម្ម ដែលផ្សេង ដោយកម្មក្នុងបច្ចុប្បន្ន និងកម្មដែលជាអតីត ។ សោយសុខទុក្ខ និងដល់ ប្រភេទថោកទាប និងប្រណីតជាដើម ប្រព្រឹត្តទៅ ។ ដោយបទទីបី ទ្រង់ សរុបសេចក្តីនោះឯងថា សត្វទាំងឡាយត្រូវចងទុកព្រោះកម្ម ឬជាអ្នកដែល កម្មចងទុក ប្រព្រឹត្តទៅហើយ សូម្បីដោយប្រការទាំងពួងយ៉ាងនេះ ។ មិន មែនដោយប្រការដទៃ ។ ដោយបទទី ៤ ទ្រង់ធ្វើសេចក្តីនោះឲ្យជាក់ច្បាស់ ដោយការប្រៀបធៀប ។ ដូចជារថដែលកំពុងគ្រាច់ទៅ ព្រោះនៅមានស្នៀត

វេចកាលស្មៀតនោះមិនមាន រមែងត្រាច់ទៅមិនបាន យ៉ាងណា សត្វដែល កើតហើយ និងប្រព្រឹត្តទៅ មានកម្មជាគ្រឿងចង បើកម្មនោះមិនចងទុក រមែងប្រព្រឹត្តទៅមិនបាន ដូច្នោះ ។ ឥឡូវនេះ ព្រោះហេតុដែលសត្វត្រូវ ចងទុកព្រោះកម្ម ព្រោះហេតុនោះ កាលនឹងទ្រង់សម្តែងនូវសភាពជាអ្នក ប្រសើរ ព្រោះកម្មដ៏ប្រសើរ ទើបត្រាស់ ២ គាថា ថា គឺ ព្រោះតបៈ ដូច្នេះ ជាដើម ។ បណ្តាបទទាំងនោះ បទថា **ព្រោះតបៈ** បានដល់ ព្រោះតបៈ គឺ ធុតង្គវត្ត ។ បទថា **ព្រោះព្រហ្មចរិយៈ** គឺ ព្រោះមេថុនវិរតិ ។ បទថា **ព្រោះសេចក្តីសង្រួម** គឺ ព្រោះសីល ។ បទថា **ព្រោះការទូន្មាន** គឺ ព្រោះ ការទូន្មានឥន្ទ្រិយ ។ បទថា **នេះសេចក្តីថា ជាព្រាហ្មណ៍ព្រោះកម្មដ៏ប្រសើរ** គឺ បរិសុទ្ធិដូចជាព្រហ្មនេះ ។ ព្រោះហេតុអ្វី ។ ព្រោះភាពជាព្រាហ្មណ៍នេះ ជាអ្នកប្រសើរបំផុត អធិប្បាយថា ព្រោះកម្មនេះ ជាគុណរបស់ព្រាហ្មណ៍ យ៉ាងខ្ពស់បំផុត ។ ក៏ក្នុងពាក្យថា ព្រាហ្មណ៍នេះ មានអត្ថន័យរបស់ពាក្យ ដូចតទៅនេះ ៖

ឈ្មោះថា **ព្រាហ្មណ៍** ព្រោះអត្ថថា នាំមកនូវព្រហ្ម អធិប្បាយថា នាំមកនូវភាពជាព្រាហ្មណ៍ ។

បទថា **អ្នកស្ងប់** ដូច្នេះ ក្នុងគាថា ទី ២ មានសេចក្តីថា ជាអ្នកមានកិលេសដែលស្ងប់ហើយ ។ ពាក្យថា **ជាព្រហ្ម ជាសក្កៈ** គឺ ជាព្រះព្រហ្មជាសក្កៈ អធិប្បាយថា បុគ្គលបែបនេះ មិនមែនជាព្រហ្មតែម្យ៉ាង ដោយពិត បុគ្គលនោះជាព្រហ្ម និងជាសក្កៈរបស់បណ្ឌិត ជាអ្នកដឹងច្បាស់ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះ ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង ងាយទាំងអស់នោះឯង ។

" ចប់អដ្ឋកថា វាសេដ្ឋសូត្រទី ៨ "

# អ ដ្ឋ ក ថា

# សុភសូត្រទី ៩

**[១២៦]** *សុភសូត្រ* មានពាក្យផ្តើមថា *ឯវម្មេ សុតំ* ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ៖

ក្នុងសុភសូត្រនោះ បុត្ររបស់តោទេយ្យព្រាហ្មណ៍អ្នកនៅក្នុង តុទិ-គ្រាម ឈ្មោះថា តោទេយ្យបុត្រ ។

**[១២៧]** ពាក្យថា **ជាអ្នកបំពេញ** គឺ ជាអ្នកដល់ព្រម ជាអ្នកបរិបូណ៌ ។ ពាក្យថា **ញាយធម៌** គឺ ធម៌ដែលជាហេតុ ។ បទថា **ជាកុសល** គឺ មិនមានទោស ។ បទថា **ប្រតិបត្តិខុស** គឺ វត្តបដិបត្តិដែលមិនមែនជាកុសល មិនមែនជាគ្រឿងនាំចេញចាកទុក្ខ ។ បទថា **ការបដិបត្តិត្រូវ** បានដល់ ការបដិបត្តិដែលជាកុសល ដែលជាគ្រឿងនាំចេញចាកទុក្ខ ។

**[១២៨]** ក្នុងបទថា **មានសេចក្តីត្រូវការច្រើន** ដូច្នេះជាដើម មានវិគ្រោះដូចតទៅនេះ ឈ្មោះថា មានសេចក្តីត្រូវការច្រើន ព្រោះក្នុងឋានៈនេះ មានសេចក្តីត្រូវការដោយការធ្វើសេចក្តីខ្វល់ខ្វាយ ឬដោយការជួយ នៅសល់

ច្រើន គឺ ច្រើនណាស់ ។ ឈ្មោះថា មានកិច្ចច្រើន ព្រោះឋានៈនេះ មានកិច្ចច្រើនដូចជាការងារមង្គល ក្នុងការតាំងឈ្មោះជាដើមច្រើន ។ ឈ្មោះថា មានអធិករណ៍ច្រើន ដែលនឹងត្រូវចាត់ការច្រើន ព្រោះក្នុងឋានៈនេះ មានរឿងរ៉ាវ គឺ មុខនាទីការងារច្រើនយ៉ាងនេះ គឺ ថ្ងៃនេះត្រូវធ្វើវត្ថុនេះ ស្អែកនេះត្រូវ ធ្វើវត្ថុនេះ ។ ឈ្មោះថា មានសេចក្តីប្រុងប្រៀបច្រើនច្រើន ព្រោះក្នុងឋានៈនេះ មានការចុះដៃធ្វើច្រើន គឺ ការខ្វល់ខ្វាយ ដោយអំណាចការជួយក្នុងការងាររបស់មនុស្សជាច្រើន ។ ការងាររបស់ខ្លួនជាយរាវាស ឈ្មោះថា ឋានៈការងាររបស់យរាវាស ។ គប្បីជ្រាបសេចក្តីក្នុងវារៈទាំងពួងដោយប្រការយ៉ាងនេះ ។ ក៏ក្នុងបណ្តាការធ្វើស្រែ និងការធ្វើជំនួញនេះ ក្នុងការធ្វើស្រែ គប្បីជ្រាបសេចក្តីត្រូវការច្រើន ដោយការស្វែងរកគ្រឿងឧបករណ៍ មាននង្គ័លជាដើម , ក្នុងការធ្វើជំនួញ គប្បីជ្រាបសេចក្តីត្រូវការតិច ដោយការកាន់យកទំនិញតាមសភាពដើម ហើយមកចំណាយ ។ បទថា **វិបត្តិ** សេចក្តីថា កសិកម្មរមែងមានផលតិចខ្លះ ដល់ការខាតដើមខ្លះ ព្រោះភ្លៀងមិនធ្លាក់ និងធ្លាក់ច្រើនពេកជាដើម , និងពាណិជ្ជកម្ម មានផលតិចខ្លះ ដល់ការខាតដើមខ្លះ ព្រោះការមិនឆ្លាតជាដើម ក្នុងការមើលកែវ-

មណី និងមាសជាដើម ។ ដោយផ្ទុយគ្នា ដែលសម្បូរណ៍ រមែងមានផល ច្រើន ដូចអន្តេវាសិករបស់ចូឡកៈ ។ ពាក្យថា ដូច្នោះនោះឯង សេចក្តីថា ឋានៈ គឺ កសិកម្ម កាលវិបត្តិ រមែងមានផលតិចយ៉ាងណា សម្បូឋានៈ គឺ ការងាររបស់យកវាសក៏ដូច្នោះ ។ ព្រោះបុគ្គលដែលមិនធ្វើកម្មល្អទុក ស្លាប់ ហើយ រមែងកើតក្នុងនរក ។ បានឮថា មនុស្សដែលព្រាហ្មណ៍ចិញ្ចឹមទុក ម្នាក់ ឈ្មោះមហាទត្តសេនាបតី ។ ក្នុងសម័យដែលគេជិតស្លាប់ នរកក៏ ប្រាកដឡើង ។

ពួកព្រាហ្មណ៍សួរថា លោកឃើញអ្វី គេពោលថា ឃើញផ្ទះពណ៌ ក្រហម ។

ព្រាហ្មណ៍ពោលថា អ្នកដ៏ចម្រើន នុ៎ះឯងព្រហ្មលោក ។ គេសួរថា លោកដ៏ចម្រើន ព្រហ្មលោកនៅទីណា ។ នៅខាងលើ ។ គេនិយាយថា ប្រាកដដល់ខ្ញុំ គឺ ខាងក្រោម ។ សេចក្តីពិត ផ្ទះពណ៌ក្រហម ប្រាកដនៅ ខាងក្រោម មិនបានប្រាកដនៅខាងលើ ។ គេស្លាប់ហើយទៅកើតក្នុងនរក ។ ពួកព្រាហ្មណ៍គិតថា នាយម្នាក់នេះ ឃើញទោសក្នុងយញ្ញរបស់យើង ដូច្នេះ ទើបបានយកទ្រព្យមួយពាន់មកឲ្យ ដើម្បីនឹងបាននាំជាប់ខ្លួនទៅ ។ ចំណែក

ឋានៈ គឺ កសិកម្មដែលសម្បូរណ៍ រមែងមានផលច្រើន ។ ព្រោះបុគ្គលដែលធ្វើកម្មល្អទុក ស្លាប់ហើយ រមែងទៅកើតក្នុងសួគ៌ ។ គប្បីសម្តែងគុត្តិលវិមានកថាទាំងអស់ ។ ដូចជា ឋានៈ គឺ ពាណិជ្ជកម្ម កាលវិបត្តិរមែងមានផលតិចយ៉ាងណា សុម្បីឋានៈ គឺ បព្វជ្ជាកម្មរបស់ភិក្ខុ ដែលមិនធ្វើឲ្យបរិបូណ៌ក្នុងសីល ប្រកបការស្វែងរកដែលមិនគួរ ក៏ដូច្នោះ ។ ព្រោះភិក្ខុទាំងឡាយបែបនោះ រមែងមិនបានសុខក្នុងឈានជាដើម រមែងមិនបានសុខក្នុងសួគ៌ និងនិព្វាន ។ ចំណែកបព្វជ្ជាកម្មដែលដល់ព្រម រមែងមានផលច្រើន ។ ព្រោះអ្នកធ្វើសីលឲ្យបរិបូណ៌ ចម្រើនវិបស្សនា រមែងសម្រេចព្រះអរហត្ត ។

**[១២៨]** ពាក្យថា បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ទាំងឡាយសេចក្តីថា មាណពរមែងទូលសួរថា ខ្ញុំព្រះអង្គសូមសួរអ្វីក្នុងទីនេះ គឺ រមែងសួរថា ព្រាហ្មណ៍ទាំងឡាយរមែងពោលថា បព្វជិតឈ្មោះថា អាចបំពេញធម៌ ៥ ប្រការទាំងនេះ រមែងមិនមាន គ្រហស្ថប៉ុណ្ណោះបំពេញបាន ចំណែកព្រះសមណគោតម រមែងត្រាស់រឿយៗ ថា ម្នាលមាណព ចំពោះគ្រហស្ថឬបព្វជិត ដូច្នេះ រមែងមិនថ្លែងវាចាដល់បព្វជិតប៉ុណ្ណោះ ទ្រង់មិនកំណត់

ការសួររបស់ខ្ញុំព្រះអង្គ ព្រោះហេតុនោះ ខ្ញុំព្រះអង្គសូមសួរធម៌ ៥ ប្រការ មានចាគៈជាបំផុត ។ ពាក្យថា **ប្រសិនបើអ្នកមិនទើសទាល់ទេ** សេចក្ដីថា បើអ្នកមិនទើសទាល់ទេដើម្បីពោលក្នុងទីនេះ ដោយប្រការដែលពួកព្រាហ្មណ៍បញ្ញត្តិទុកនោះ ។ អធិប្បាយថា បើមិនទើសទាល់ចិត្ត អ្នកក៏ចូរពោល ។ មាណពពោលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គមិនទើសទាល់ចិត្តឡើយ ដូច្នេះ សំដៅយកអ្វី ។ ក៏ការពោលក្នុងសំណាក់របស់បុគ្គលដែលមិនមែនជាបណ្ឌិត រមែងជាទុក្ខ ។ បុគ្គលដែលមិនមែនជាបណ្ឌិតទាំងនោះ រមែងឲ្យទោសប៉ុណ្ណោះ គ្រប់ៗ បទ គ្រប់ៗ អក្សរ ។ ចំណែកបុគ្គលជាបណ្ឌិត ស្ដាប់ពាក្យហើយ រមែងសរសើរពាក្យដែលពោលត្រូវ ។ កាលពោលខុស ក្នុងបណ្ដាបាលី បទ អត្ថ និងព្យញ្ជនៈ ពាក្យណាៗ ខុស រមែងប្រាប់ពាក្យនោះៗ ឲ្យត្រូវ ។ ក៏ឈ្មោះថា បណ្ឌិត ដូចនឹងព្រះមានព្រះភាគរមែងមិនមាន ។ ព្រោះហេតុនោះ មាណពទើបពោលថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គគ្គី អ្នកប្រាជ្ញប្រហែលនឹងព្រះអង្គគ្គី ប្រថាប់គង់ក្នុងទីណា ទីនោះ ខ្ញុំព្រះអង្គមិនមានទើសទាល់ចិត្តឡើយ ដូច្នេះ ។

**[១៣២]** បទថា **សច្ចៈ** គឺ និយាយពិត ។ បទថា **តបៈ** បានដល់

ការប្រព្រឹត្តិតបៈ ។ បទថា **ព្រហ្មចរិយ** បានដល់ ការវៀរចាកមេថុន ។ បទថា **ការស្វាធ្យាយ** បានដល់ ការរៀនមន្ត ។ បទថា **ចាគៈ** គឺ ការបរិច្ចាគអាមិស ។

**[១៣៩]** ពាក្យថា **នឹងជាអ្នកឲ្យដល់** សេចក្តីអាក្រក់ គឺ នឹងជាអ្នកឲ្យដល់សេចក្តីមិនដឹង ។ ពាក្យថា **បានពោលពាក្យនេះ** សេចក្តីថា មាណពត្រូវព្រះមានព្រះភាគទ្រង់គ្របសង្កត់ ប្រៀបដូចមនុស្សក្អែកខ្វាក់ កាលមិនអាចដើម្បីតបតពាក្យនោះបាន កាលនឹងអាងដល់អាចារ្យ ប្រៀបផ្ទឹមបែបសុនខខ្សោយកម្លាំង ពាំសាច់មកដាក់ត្រង់មុខម្ចាស់របស់ហើយ ខ្លួនឯងក៏ឱនចុះទៅ ដូច្នោះ ទើបបានពោលពាក្យនោះ មានជាដើមថា ព្រាហ្មណ៍ដូច្នេះ ។ ពាក្យថា **បោក្ខរសាតិ** នេះ ក្នុងពាក្យថា ព្រាហ្មណ៍ជាដើមនោះ ជាឈ្មោះរបស់ព្រាហ្មណ៍នោះ ។ ហៅថា បោក្ខរសាតិខ្លះ ក៏មាន ។ បានឮថា រាងកាយរបស់ព្រាហ្មណ៍នោះ ដូចឈូកស ស្រស់ល្អដូចសសរខឿនប្រាក់ដែលលើកឡើងក្នុងទេវនគរ ចំណែកសីសៈរបស់ព្រាហ្មណ៍នោះ ដូចធ្វើដោយកែវឥន្ទនិលពណ៌ខ្មៅ ។ សូម្បីពុកមាត់ ក៏ប្រាកដដូចជួរពពកខ្មៅក្នុងព្រះចន្ទ នេត្រាទាំងពីរខាង ដូចផ្កាឧប្បលខៀវ ។ ច្រមុះតាំងនៅល្អ

បរិសុទ្ធិផូរផង់ដូចប្រាក់ ។ បាតដៃបាតជើង និងមាត់ ល្អដូចជ្រលក់ដោយទឹកល័ក្ខ ។ អត្តភាពរបស់ព្រាហ្មណ៍ដល់កាលល្អប្រសើរយ៉ាងក្រៃលែង សមគួរតាំងឲ្យជាភពជាក្នុងឋានៈដែលមិនបានជាភពជា ព្រោះហេតុនោះ ជនទាំងឡាយទើបស្គាល់ព្រាហ្មណ៍នោះថា បោក្ខរសាតិ ដោយប្រការដូច្នេះ ព្រោះព្រាហ្មណ៍នេះ ជាអ្នកមានសភាពស្រស់ស្អាតយ៉ាងនេះនុ៎ះឯង ម្យ៉ាងទៀតព្រាហ្មណ៍នោះ កើតក្នុងផ្កាឈូក មិនបានកើតក្នុងផ្ទៃមាតា ព្រោះហេតុនោះជនទាំងឡាយទើបស្គាល់ព្រាហ្មណ៍នោះថា បោក្ខរសាតិ ព្រោះដេកនៅក្នុងផ្កាឈូក ដោយប្រការដូច្នេះ ។ បទថា **ឱបមញ្ញ** ប្រែថា អ្នកជាឱបមញ្ញ-គោត្រ ។ បទថា **ជាអ្នកជំក្នុងសុភគវនជនបទ** គឺ ជាជំក្នុងសុភគវនជនបទក្នុងស្រុកឧកដ្ឋា ។ បទថា **នាំឲ្យគេសើចលេង** គឺ គួរឲ្យគេសើចតែម្យ៉ាង ។

បទថា **នាំឲ្យតែអាក្រក់ឈ្មោះ** បានដល់ អាក្រក់តែម្ដង ។ ភាសិតនោះៗ ឈ្មោះថា សោះសូន្យ ព្រោះមិនមានប្រយោជន៍ ឈ្មោះថា ទទេព្រោះជាភាសិតសោះសូន្យ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងគ្របសង្កត់សុភមាណពនោះព្រមទាំងអាចារ្យ ទើបត្រាស់ពាក្យថា ម្នាលមាណព ចុះ... ឬទេ ដូច្នេះ

ជាដើម ។

**[១៣៧]** បណ្ដាពាក្យទាំងនោះ ពាក្យថា **តើវាចាដូចម្ដេច របស់ព្រាហ្មណ៍មហាសាលទាំងនោះ ដែលជាវាចាប្រសើរជាងគេ** ដូច្នេះ សេចក្ដីថា វាចាពួកណារបស់សមណព្រាហ្មណ៍ទាំងនោះ ប្រសើរជាង អធិប្បាយថា ជាវាចាគួរសរសើរ ល្អជាង ។ បទថា **សំមុច្ចា** ប្រែថា តាមសម្មតិ គឺជាលោកវោហារ ។ បទថា **វាចាដែលត្រិះរិះហើយពោល** គឺ បានកំណត់ហើយ បានថ្លឹងថ្លែងហើយ ។ បទថា **ពិចារណាហើយ** បានដល់ ដឹងហើយ ។ បទថា **ប្រកបដោយប្រយោជន៍** គឺ អាស្រ័យហេតុ ។

**[១៣៨]** បទថា **ឯវំ សន្តេ** កាលវាចាដែលបុគ្គលមិនលះវោហាររបស់លោក ពិចារណាហើយ ដឹងហើយ ពោលធ្វើហេតុឲ្យជាទីអាស្រ័យជាវាចាប្រសើរ ។

**[១៣៩]** បទថា **អាវុតោ** ព័ន្ធព័ទ្ធ គឺ រារាំង ។ បទថា **និវុតោ** រារាំង គឺ ឃាំងទុក ។ បទថា **ឱផុតោ** រួបរឹតហើយ គឺ ចងទុកហើយ ។ បទថា **បរិយោនទ្ធោ** បិទបាំង គឺ គ្របទុក ។

**[១៤០]** បទទាំងឡាយមានជាដើមថា **គធិតោ** ជំពាក់ចិត្ត ដូច្នេះ

មានសេចក្ដីពោលទុកហើយនោះឯង ។

[១៤១] ពាក្យថា **បពិត្រព្រះគោតមដ៏ចម្រើន បើហេតុនោះមាន** សេចក្ដីថា បើហេតុនោះមាន ។ បទថា **ស្វាស្ស** ... សេចក្ដីថា ព្រោះមិនមានផ្សែង និងកម្ទេចផេះជាដើម ភ្លើងនោះ គប្បីមានអណ្ដាត មានពណ៌ និងមានពន្លឺ ។ ពាក្យថា **តថូបមហំ មាណវ** មាណព តថាគតពោលនូវបីតិៈ ថាមានឧបមេយ្យដូច្នោះដែរ សេចក្ដីថា តថាគតប្រៀបបីតិដែលអាស្រ័យកាមគុណនោះ ។ អធិប្បាយថា ប្រៀបដូចភ្លើងដែលអាស្រ័យស្មៅ និងឧសជាគ្រឿងឆេះសន្ធោសន្ធៅ រមែងជាភ្លើងដែលមានទោស ព្រោះមានផ្សែង កម្ទេចផេះ និងរងើក យ៉ាងណា បីតិដែលអាស្រ័យកាមគុណ ៥ កើតឡើង រមែងមានទោស ព្រោះមានជាតិ ជរា ព្យាធិ មរណៈ និងសោកៈជាដើមយ៉ាងនោះ ។ អធិប្បាយថា ភ្លើងឈ្មោះថា ជារបស់បរិសុទ្ធិ ព្រោះមិនមានផ្សែងជាដើម ដែលប្រាសចាកគ្រឿងឆេះ គឺ ស្មៅ និងឧសយ៉ាងណា **បីតិដែលប្រកបដោយលោកុត្តរ និងឈានទាំងពីរ ឈ្មោះថាបរិសុទ្ធិ ព្រោះមិនមានជាតិជាដើម** ដូច្នោះ ។

[១៤២] ឥឡូវនេះ ធម៌ ៥ ប្រការ ដែលព្រាហ្មណ៍ទាំងឡាយបញ្ញត្តិ

ដោយចាគៈដែលជាប្រធានសូម្បីនោះ ព្រោះហេតុដែលមិនតាំងនៅត្រឹមតែ ៥ ប្រការប៉ុណ្ណោះ ជាធម៌មិនញាប់ញ័រតាំងនៅ ក៏មិនមែន គឺ រមែងមិនដល់ព្រមនឹងការអនុគ្រោះ ព្រោះហេតុនោះដើម្បីនឹងសម្ដែងទោសនោះ ទើបត្រាស់ពាក្យថា ម្នាលមាណព ធម៌ទាំងនោះយ៉ាងណា ដូច្នេះជាដើម ។

**[១៨៣]** បណ្ដាបទទាំងនោះ បទថា (ឲ្យទាន) **គ្រាន់តែជារបស់សង្គ្រោះ** គឺ មានសេចក្ដីអនុគ្រោះជាសការៈ ។

**[១៨៤]** ពាក្យថា **អ្នកពិចារណានូវធម៌ទាំង ៥ ប្រការនោះ តើមានច្រើនក្នុងបរិស័ទណា** ព្រោះហេតុដែលព្រះមានព្រះភាគត្រាស់ថា បព្វជិតនេះឈ្មោះថា អ្នកអាចដើម្បីបំពេញធម៌ ៥ ប្រការនេះ ឲ្យបរិបូណ៌ រមែងមិនមាន គ្រហស្ថទើបបំពេញឲ្យបរិបូណ៌បាន ព្រោះហេតុនោះ បព្វជិតប៉ុណ្ណោះបំពេញធម៌ ៥ ប្រការនេះ ឲ្យបរិបូណ៌មិនបាន គ្រហស្ថឈ្មោះថាអាចដើម្បីបំពេញឲ្យបរិបូណ៌បាន រមែងមិនមាន ទើបត្រាស់សួរមាណពឲ្យពោលតាមសេចក្ដីនោះឯង ។ ក្នុងពាក្យថា **នឹងនិយាយពាក្យពិត ទៀងទាត់រឿយៗ មិនបាន** ដូច្នេះជាដើម គប្បីឃើញអត្ថន័យយ៉ាងនេះថា គ្រហស្ថកាលហេតុដទៃមិនមាន ក៏ធ្វើសូម្បីមុសាវាទ ជារបស់អ្នកបញ្ឆោតបន្ទំ ។

ពួកបព្វជិត សូម្បីកាលនឹងត្រូវកាត់សីសៈដោយដាវ ក៏មិនពោលត្រឡប់ពាក្យ ។

ម្យ៉ាងទៀត គ្រហស្ថមិនអាចរក្សាសិក្ខាបទសូម្បីត្រឹមតែបីខែ ។ បព្វ-ជិតជាអ្នកមានតបៈ មានសីល មានតបៈជាទីអាស្រ័យ រហូតអស់កាលជានិច្ចបាន ។ គ្រហស្ថ រមែងមិនអាចធ្វើឧបោសថកម្មត្រឹមតែ ៨ ថ្ងៃក្នុងមួយខែ បព្វជិតទាំងឡាយជាអ្នក ប្រព្រឹត្តព្រហ្មចរិយៈរហូតអស់ជីវិត ។ គ្រហស្ថសរសេរសូម្បីត្រឹមតែរតនសូត្រ និងមង្គលសូត្រ ទុកក្នុងក្រាំងហើយក៏ជាក់ទុក ។ បព្វជិតទាំងឡាយទន្ទេញជានិច្ច ។ គ្រហស្ថមិនអាចឲ្យសូម្បីស្លាកភត្ត (ឲ្យស្មើទៅ) មិនឲ្យដាច់ ។ បព្វជិតទាំងឡាយ កាលរបស់ដទៃមិនមាន ក៏ឲ្យដុំបាយដល់ពួកក្អែក និងសុនខជាដើម រមែងដាក់ក្នុងបាត្រសូម្បីរបស់ភិក្ខុកម្មោះអ្នកទទួលបាត្រនុ៎ះឯង ។

**[១៤៥]** ពាក្យថា **តថាគតពោលធម៌ទាំង ៥ ប្រការថា ជាបរិក្ខាររបស់ចិត្ត** សេចក្តីថា យើងពោលធម៌ ៥ ប្រការទាំងនោះថា ជាបរិវាររបស់មេត្តាចិត្ត ។

**[១៤៦]** បទថា **ជាតវឌ្ឍោ** កើតហើយ ចម្រើនហើយ ប្រែថា ទាំង

កើតហើយ និងចម្រើនហើយ ។

ក៏បុគ្គលណាកើតក្នុងទីនោះ តែម្យ៉ាងប៉ុណ្ណោះ (តែ) ចម្រើនក្នុងស្រុកដទៃ ផ្លូវក្នុងស្រុកជុំវិញ រមែងមិនប្រាកដទូទៅដល់បុគ្គលនោះ ព្រោះដូច្នោះ ទើបត្រាស់ថា ទាំងកើតទាំងចម្រើនហើយ ដូច្នេះ ។

ក៏បុគ្គលណាសូម្បីកើតហើយ ចម្រើនធំឡើងហើយ តែចេញទៅអស់វេលាយូរ ផ្លូវក៏រមែងមិនប្រាកដច្បាស់ដោយទូទៅដល់បុគ្គលនោះ ព្រោះហេតុនោះ ទើបត្រាស់ថា **តាវទេវ អបសក្កំ** (អ្នកចេញទៅក្នុងខណៈនោះ) ។ អធិប្បាយថា ចេញទៅក្នុងខណៈនោះភ្លាម ។ បទថា **យឺតយូរ** សេចក្តីថា បង្អែបង្អង់ដោយសេចក្តីសង្ស័យថា ផ្លូវនេះឬៗ ផ្លូវនេះ ។ បទថា **អ៊ឹមអៀន** សេចក្តីថា សរីរៈរបស់អ្នកណាៗ ដែលត្រូវមនុស្សដទៃចោទសួរដល់បញ្ហាទាំងពាន់ ដែលមានអត្ថដ៏ជ្រាលជ្រៅ រមែងដល់ភាវៈយឺតយូរ យ៉ាងណាការដល់ភាវៈយឺតយូរដូច្នោះ រមែងមិនមានឡើយ ។

ព្រះមានព្រះភាគទ្រង់សម្តែងភាវៈដែលព្រះសព្វញ្ញុតញ្ញាណ ដែលអ្វីៗ មិនខ្ទាំងខ្ទប់បាន ដោយបទថា **វិត្ថាយិតត្តំ** នេះ ។ ក៏ការខ្ទាំងខ្ទប់គប្បី

គប្បីមានដល់បុរសនោះ ដោយអំណាចមារធ្វើឲ្យត្រឡប់ចិត្តជាដើម ព្រោះហេតុនោះ បុរសនោះ គប្បីយឺតយូរ ឬគប្បីអ៊ឹមអៀន ។ តែព្រះសព្វញ្ញុតញ្ញាណមិនមានអ្វីរាំងបាន លោកសម្តែងថា អ្នកណាៗ មិនអាចធ្វើអន្តរាយដល់ព្រះសព្វញ្ញុតញ្ញាណនោះ ។

[១៤៦] បទថា **មានកម្លាំង** ក្នុងពាក្យនេះថា ម្នាលមាណព បុរសមានកម្លាំងផ្លុំស័ង្ខ ដូច្នេះ សេចក្តីថា សម្បូរណ៍ដោយកម្លាំង ។ បទថា **សង្ខធមោ** ប្រែថា អ្នកផ្លុំស័ង្ខ ។ បទថា **អប្បកសិរេន** បានដល់ ដោយមិនលំបាក គឺ បានដោយងាយ ។

ក៏បុរសផ្លុំស័ង្ខជាអ្នកមានកម្លាំងខ្សោយ សូម្បីផ្លុំស័ង្ខ ក៏មិនអាចនឹងឲ្យសំឡេងពួខ្ទាំងទៅកាន់ទិសទាំង ៤ បាន សំឡេងស័ង្ខរបស់គេ មិនផ្សាយទៅដោយប្រការទាំងពួង ។ ចំណែករបស់អ្នកមានកម្លាំង រមែងផ្សាយទៅ ។ ព្រោះហេតុនោះ ទើបត្រាស់ថា អ្នកមានកម្លាំង ។ កាលពោលថា **ដោយមេត្តា** ដូច្នេះ ក្នុងពាក្យថា ដោយមេត្តាដែលជាចេតោវិមុត្តិនេះ រមែងគួរទាំងឧបចារៈ ទាំងអប្បនា ។ តែពោលថា **ចេតោវិមុត្តិយា** រមែងគួរចំពោះអប្បនាប៉ុណ្ណោះ ។ ពាក្យថា **យំ បមាណកតំ កម្មំ** កម្មដែល

ធ្វើទុក ប្រមាណប៉ុនណា សេចក្តីថា ឈ្មោះថា កម្មដែលធ្វើ ប្រមាណបាន ហៅថា កាមាវចរៈ ។ ឈ្មោះថា កម្មដែលធ្វើ ប្រមាណមិនបាន ហៅថា រូបាវចរៈ ។ ក្នុងកម្មដែលជាកាមាវចរៈ និងអរូបាវចរៈសូម្បីទាំងនោះ កម្ម គឺ ព្រហ្មវិហារប៉ុណ្ណោះ ទ្រង់បំណងយកក្នុងទីនេះ ។ ក៏ព្រហ្មវិហារកម្ម នោះ ហៅថា រកប្រមាណមិនបាន ព្រោះធ្វើឲ្យចម្រើនទៅ ដោយការផ្សាយ ទៅប្រមាណមិនបានទៅកាន់ទិសដែលចំពោះ និងមិនចំពោះ ។ ពាក្យថា **កម្មនោះ** នឹងមិនឈប់នៅក្នុងទីនោះ មិនឋិតនៅក្នុងទីនោះ សេចក្តីថា កាមាវចរកម្មនោះ រមែងមិនជាប់ គឺ មិនតាំងនៅក្នុងរូបាវចរកម្មនោះ ។ លោក អធិប្បាយទុកយ៉ាងណា ។ លោកអធិប្បាយទុកថា កាមាវចរកម្មនោះ រមែង មិនជាប់ ឬតាំងនៅក្នុងចន្លោះនៃរូបាវចរកម្មនោះ ឬផ្សាយទៅកាន់រូបាវចរកម្ម និងអរូបាវចរកម្មហើយ គ្របសង្កត់កាន់យកឱកាសសម្រាប់ខ្លួនតាំង នៅ ។ ដោយពិត រូបាវចរកម្មប៉ុណ្ណោះ ផ្សាយទៅកាន់កាមាវចរកម្ម ដូច ទឹកច្រើនជន់ជោរលិចទឹកតិច គ្របសង្កត់ កាន់យកឱកាសសម្រាប់ខ្លួនហើយ ស្ថិតនៅ ។ រូបាវចរកម្ម ហាមវិបាករបស់កាមាវចរកម្មនោះ ហើយចូល ដល់ការៈជាសម្ពាញ់នៃព្រហ្មដោយខ្លួនឯង ។ ពាក្យដ៏សេសក្នុងទីទាំងពួង

*ងាយទាំងអស់នោះឯង ។*

“ ចប់អដ្ឋកថា សុភសូត្រ ទី ៩ ”

# អ ដ្ឋ ក ថា

## សគារវសូត្រទី ១០

**[១៥១]** *សគារវសូត្រ មានពាក្យផ្ដើមថា ឯវម្មេ សុតំ ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ៖*

*បណ្ដាបទទាំងនោះ បទថា* **ក្នុងស្រុកឈ្មោះបច្ចលកប្បៈ** *គឺ ក្នុងស្រុកដែលមានឈ្មោះយ៉ាងនោះ ។ បទថា* **ជ្រះថ្លាក្រៃលែង** *បានដល់ជ្រះថ្លាដោយសេចក្ដីជ្រះថ្លាដែលមិនញាប់ញ័រ ។ បានឮថា នាងព្រាហ្មណីនោះជាអរិយសាវិកាសោតាបន្ន ជាកិរិយារបស់ព្រាហ្មណ៍ការទ្វាជគោត្រ ។ កាលពីមុន ព្រាហ្មណ៍នោះ អញ្ជើញព្រាហ្មណ៍ទាំងឡាយមក ហើយធ្វើសក្ការៈដល់ព្រាហ្មណ៍ទាំងនោះជានិច្ច ។ ពេលធ្វើ យកនាងព្រាហ្មណីនេះមកកាន់ផ្ទះហើយ មិនអាចធ្វើចិត្តឲ្យក្រោធចំពោះនាងព្រាហ្មណីរូបល្អ មានត្រកូលធំ មិនអាចធ្វើសក្ការៈដល់ព្រាហ្មណ៍ទាំងឡាយ ។ គ្រានោះព្រាហ្មណ៍ទាំងឡាយ បានស្ដីបន្ទោសដាក់ព្រាហ្មណ៍នោះក្នុងទីដែលឃើញគ្រប់កន្លែងថា ឥឡូវនេះ លោកមិនកាន់លទ្ធិព្រាហ្មណ៍ ទើបមិនធ្វើសក្ការៈសូម្បីត្រឹម*

តែម្យ៉ាងដល់ពួកព្រាហ្មណ៍ ។ ព្រាហ្មណ៍នោះ ត្រឡប់មកផ្ទះ ប្រាប់សេចក្តីនោះដល់ព្រាហ្មណី ហើយពោលថា បើនាងនឹងអាចរក្សាមុខខ្ញុំ ក្នុងថ្ងៃមួយខ្ញុំក៏នឹងឲ្យកិក្ខាដល់ព្រាហ្មណ៍ទាំងឡាយក្នុងថ្ងៃមួយ ។ នាងព្រាហ្មណីពោលថា លោកចូរឲ្យទេយ្យធម៌របស់លោកក្នុងទីដែលពេញចិត្តចុះ ខ្ញុំនិងមានប្រយោជន៍អ្វីរឿងនេះ ។ ព្រាហ្មណ៍នោះ បានអញ្ជើញព្រាហ្មណ៍ទាំងឡាយហើយឲ្យជាំបាយបាយាសមានទឹកតិច អញ្ជើញឲ្យឡើងផ្ទះ តុបតែងអាសនៈហើយអញ្ជើញឲ្យព្រាហ្មណ៍ទាំងឡាយអង្គុយ ។ នាងព្រាហ្មណីស្លៀកដណ្តប់សំពត់សាដកផ្ទាំងធំ កាន់វែកអន្លាស ជំពប់ (ជាន់) ត្រង់ជាយសំពត់មិនបានធ្វើសេចក្តីសម្គាល់ថា យើងកំពុងអង្គាសពួកព្រាហ្មណ៍ រលឹកដល់ព្រះសាស្តាប៉ុណ្ណោះ ក៏ឧទានឡើងដោយអំណាចទម្លាប់ ។ ព្រាហ្មណ៍ទាំងឡាយស្តាប់ឧទានហើយ ក្រោធថា សម្លាញ់របស់ព្រះសមណគោតមនេះជាអ្នកកាន់ពីរចំណែក ពួកយើងនឹងមិនទទួលទេយ្យធម៌របស់គេ ដូច្នេះ ទើបលះបង់ភោជនទាំងឡាយហើយចេញទៅ ។ ព្រាហ្មណ៍ពោលថា យើងបាននិយាយនឹងនាងទុកតាំងពីដំបូងមិនមែនឬថា ថ្ងៃនេះសូមឲ្យនាងរក្សាមុខខ្ញុំត្រឹមតែមួយថ្ងៃ នាងធ្វើទឹកដោះស្រស់ និងអង្ករជាដើម មានប្រមាណ

ប៉ុណ្ណោះ ឲ្យវិនាសហើយ (គេ) លុះក្នុងអំណាចនៃសេចក្ដីក្រោធយ៉ាងខ្លាំង ពោលថា ក៏ស្រីថោកទាបនេះ ពោលសរសើរសមណគោតមនោះ មិនជ្រើសរើសកន្លែងយ៉ាងនេះ ស្រីថោកទាប ឥឡូវនេះយើងនឹងលើកវាទៈ ចំពោះសាស្ដានោះរបស់នាង ។ ពេលនោះ នាងព្រាហ្មណីទើបពោលនឹងព្រាហ្មណ៍នោះថា ទៅចុះព្រាហ្មណ៍ ទៅចុះព្រាហ្មណ៍ លោកសូម្បីទៅហើយនឹងដឹង ដូច្នេះ ហើយទើបពោលថា បពិត្រព្រាហ្មណ៍ ខ្ញុំមិនធ្លាប់ឃើញបុគ្គលដែលនឹងលើកវាទៈ ។ល។ ក្នុងលោកព្រមទាំងទេវតា ដូច្នេះជាដើម ។

ព្រាហ្មណ៍នោះចូលទៅគាល់ព្រះសាស្ដាហើយ ទូលសួរបញ្ហាថា

សម្លាប់អ្វីហ្ន៎ ទើបនឹងនៅជាសុខ , សម្លាប់អ្វីហ្ន៎ ទើបនឹង

មិនសោកសៅ , ព្រះគោតម លោកពេញចិត្តការសម្លាប់

ធម៌អ្វីដែលជាធម៌ឯក ។

ព្រះសាស្ដាត្រាស់តបបញ្ហាថា សម្លាប់សេចក្ដីក្រោធ

ហើយ នៅជាសុខ សម្លាប់សេចក្ដីក្រោធហើយ រមែងមិន

សោកសៅ នែ៎! ព្រាហ្មណ៍ ព្រះអរិយៈទាំងឡាយ រមែង

សរសើរការសម្លាប់សេចក្ដីក្រោធ ដែលមានឫសជាពិស

មានចុងដ៏ផ្អែម ព្រោះសម្លាប់សេចក្ដីក្រោធបានហើយ រមែង
មិនសោកសៅ ។

ព្រាហ្មណ៍នោះបួសហើយ សម្រេចព្រះអរហត្ត ។ ប្អូនប្រុសរបស់ព្រាហ្មណ៍ទុះឯង ឈ្មោះអក្កោសកភារទ្វាជៈ បានស្ដាប់ដំណឹងថា បងប្រុសរបស់យើងបួសហើយ ទើបចូលទៅគាល់ព្រះមានព្រះភាគ ទ្រង់ណែនាំទើបបួស ហើយសម្រេចព្រះអរហត្ត ។ ប្អូនប្រុសរបស់ព្រាហ្មណ៍នោះម្នាក់ទៀត ឈ្មោះសុន្ទរិកភារទ្វាជៈ ។ សូម្បីព្រាហ្មណ៍នោះ ក៏ចូលទៅគាល់ព្រះមានព្រះភាគទូលសួរបញ្ហា បានស្ដាប់នូវវិសជ្ជនាហើយ បានបួស ក៏សម្រេចព្រះអរហត្ត ។ ប្អូនប្រុសរបស់ព្រាហ្មណ៍នោះ ឈ្មោះបិង្គលភារ-ទ្វាជៈ ។ គេសួរបញ្ហា ក្នុងវេលាចប់ការព្យាករណ៍បញ្ហា ក៏បួស ហើយសម្រេចព្រះអរហត្ត ។

**[១៥២]** ពាក្យថា **មាណពឈ្មោះសគារវៈ** មានសេចក្ដីថា មាណពនេះ ជាប្អូនពៅនៃព្រាហ្មណ៍ទាំងនោះ គេអង្គុយក្នុងរោងកត្តមួយកន្លែង មួយអន្ទើដោយពួកព្រាហ្មណ៍ក្នុងថ្ងៃនោះ ។ បទថា **អវកូតា ច** សេចក្ដីថា ជាអ្នកមិនចម្រើន គឺ ជាអ្នកមិនមានមង្គលឡើយ ។ បទថា **សេចក្ដីវិនាស**

គឺ ជាអ្នកដល់ សេចក្ដីសាបសូន្យប៉ុណ្ណោះ ។

បទថា **មាន** គឺ ក្នុងកាលមានហើយ ។ បទថា **សីល និងបញ្ញា** សេចក្ដីថា លោកមិនដឹងសីល និងបញ្ញា ។

[១៥៣] បទថា **អ្នកដល់នូវទីបំផុត** គឺ ព្រះនិព្វាន ជាគុណជាតិដ៏ក្រៃលែង ព្រោះបញ្ញាក្នុងបច្ចុប្បន្ន សេចក្ដីថា ព្រាហ្មណ៍ទាំងឡាយពោលថា យើងទាំងឡាយជាអ្នកដល់ហើយនូវទីបំផុត សម្រេចព្រះនិព្វានដែលជាគុណជាតដ៏ក្រៃលែងនៃធម៌ទាំងពួង ពោលគឺ ដោយអំណាចនៃបារមីជាហេតុឲ្យដឹងក្រៃលែងក្នុងអត្តភាពនេះនុ៎ះឯង ដូច្នេះ ឈ្មោះថា តែងដឹងច្បាស់នូវធម៌ជាខាងដើមនៃព្រហ្មចរិយៈ ។ បទថា **អាទិព្រហ្មចរិយ** មានអធិប្បាយថា តែងដឹងច្បាស់យ៉ាងនេះថា ជាខាងដើម គឺ ជាឧបការៈ ជាគុណជាតធ្វើឲ្យកើតព្រហ្មចរិយៈ ។ បទថា **អ្នកត្រិះរិះ** គឺ ជាអ្នកមានប្រក្រតីកាន់យកនូវសេចក្ដីត្រិះរិះ ។

[១៥៤] បទថា **ពិចារណា** សេចក្ដីថា ជាអ្នកពិចារណា គឺ ជាអ្នកមានប្រក្រតីប្រើបញ្ញាពិចារណា ហើយពោលយ៉ាងនេះ ។ បទថា **បណ្ដាព្រាហ្មណ៍ទាំងនោះ តថាគតជាជាសមណមួយដែរ** សេចក្ដីថា យើងជាព្រះ

សម្មាសម្ពុទ្ធមួយអង្គដែរ ក្នុងបណ្ដាព្រះសម្មាសម្ពុទ្ធទាំងនោះ ។

**[១៧៥]** ក្នុងបទថា **អដ្ឋិត** ក្នុងបទសន្ធិថា **អដ្ឋិតវតា** ចូលនឹងបទ **បធាន** ក្នុងបទសប្បុរិសៈចូលនឹងបទ បធានៈ ក៏ដូចគ្នា ។ មានពាក្យអធិប្បាយនេះថា សេចក្ដីព្យាយាមដែលមិនឈប់ សេចក្ដីព្យាយាមរបស់សប្បុរស បានមានហើយដល់ព្រះគោតមដ៏ចម្រើន ។

ពាក្យថា **ជាអ្នកត្រូវទូលសួរថា ទេវតាមានមែនឬ** សេចក្ដីថា មាណពពោលពាក្យនេះ ដោយសម្គាល់ថា ព្រះសម្មាសម្ពុទ្ធទ្រង់មិនជ្រាប ទើបប្រកាស ។ ពាក្យថា **បើមានហេតុដូច្នោះ** សេចក្ដីថា កាលសេចក្ដីដែលព្រះអង្គទ្រង់មិនជ្រាបមាន ។ ពាក្យថា **ជាពាក្យទទេ ជាពាក្យកុហក** សេចក្ដីថា ពាក្យរបស់ព្រះអង្គ ជាពាក្យមិនមានផល គឺ ប្រាសចាកផល ។ មាណពឈ្មោះថា រមែងសង្កត់សង្កិនព្រះមានព្រះភាគ ដោយវាទៈថា និយាយកុហក ដោយប្រការយ៉ាងនេះ ។ បទថា **ដែលវិញ្ញូបុរស** បានដល់ ជនជាបណ្ឌិត ។ ទ្រង់សម្ដែងថា អ្នករមែងមិនដឹងពាក្យសូម្បីតថាគតព្យាករណ៍ព្រោះភាពជាអ្នកមិនដឹង ។ ពាក្យថា **ពាក្យនោះគេសន្មតិគ្នាដោយស័ព្ទដ៏ខ្ពស់** គឺ គេសម្មតិ បានដល់ ប្រាកដក្នុងលោកដោយស័ព្ទដ៏ខ្ពស់ ។ ពាក្យថា

*ទេវតាមាន អធិប្បាយថា សូម្បីក្មេងកម្លោះក្រមុំទាំងឡាយ ឈ្មោះថា ទេវៈ ក៏មាន ឈ្មោះថា ទេវីក៏មាន ។ ចំណែកទេវៈទាំងឡាយ ឈ្មោះថា* ***អតិទេវ*** *គឺ ជាអ្នកក្រៃលែងជាងមនុស្សទាំងឡាយ ដែលបានឈ្មោះថា ទេវៈ ទេវី ក្នុងលោក ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង ងាយទាំងអស់នោះឯង ។*

“ ចប់អដ្ឋកថា សគារវសូត្រទី ១០ ”

ចប់ ព្រាហ្មណវគ្គ ទី ៥

## រួម

## ក្នុងវគ្គនេះ មាន ១០ សូត្រ គឺ ៖

១-ព្រហ្មាយុសូត្រ
២-សេលសូត្រ
៣-អស្សលាយនសូត្រ
៤-ឃោដមុខសូត្រ
៥-ចង្កីសូត្រ
៦-ឯសុការីសូត្រ
៧-ធនញ្ជានិសូត្រ
៨-វាសេដ្ឋសូត្រ
៩-សុភសូត្រ
១០-សគារវសូត្រ

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 US |

តាមរយៈភិក្ខុធម្មបញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ
នៅរដ្ឋមាសាជូសេត សហរដ្ឋអាមេរិក

| | |
|---|---|
| -សមាគមពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ | $ 300 US |
| -ភិក្ខុវិជ្ជាសម្បន្នោ ឈួម សំបូរ និងឧបសិកាគង់ គី | $ 200 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 105 US |
| -ឧបាសិកា ជីវ យួម និងស្វាមី ព្រមទាំងបុត្ត | $ 101 US |
| -ឧបាសក សោម រតនៈ និងភរិយា " ខេត្តព្រៃវែង " | $ 100 US |
| -សីលវត្តី នួន សូនី និងបុត្ត នាងវ៉ង់ | $ 100 US |
| -លោក គ្រី សុភី និងភរិយា ផៃ សុណាំង ព្រមទាំងបុត្ត | $ 100 US |
| -លោក តឹក គ្រី និងភរិយា ព្រមទាំងបុត្ត | $ 100 US |
| -ឧបាសក កែម សាគុណ ឧបាសិកា ជា សុភាព | $ 100 US |
| -ឧបាសក លន ចំរើន ឧបាសិកា ម៉ុក ថានិ | $ 100 US |
| -ឧបាសក ម៉ៅ ប៊ួយ ឧបាសិកា ម៉ៅ លន់<br>-ម៉ៅ ម៉ារ៉ា និងស្មៀង ថៃបញ្ញារិទ្ធ ព្រមទាំងបុត្ត<br>-ម៉ៅ ម៉ារ៉ង ម៉ៅ គឹមអាន ម៉ៅ គឹមស្មៀង<br>-ម៉ៅ ប៊ុនសន្ថា ក្ហួយស្រី ធន់ សន្ថានី | $ 700 US |
| -ឧបាសិកា ពិន សាមឿន និងបុត្ត | $ 50 US |
| -ឧបាសិកា ពិន សាម៉ុន និងបុត្ត | $ 50 US |
| -ឧបាសិកា ប៊ុន សារ៉ុម និងបុត្ត | $ 50 US |
| -ឧបាសិកា គង់ ជី និងបុត្ត | $ 50 US |

| | |
|---|---|
| -ឧបាសិកា ឡាច ម៉ាឡៃ និងបុត្ត | $ 50 US |
| -ឧបាសិកា ទូត ច័ន្ទវណ្ណី និងបុត្ត | $ 50 US |
| -ឧបាសិកា ម៉ែន សារ៉ាត | $ 50 US |
| -ឧបាសិកា ពិន សាត | $ 50 US |
| -ឧបាសិកា អ៊ុំ សាត | $ 50 US |
| -លោក ណៃ សារិន និងឧបាសិកា ជា សូភី | $ 50 US |
| -លោក កែវ ណាត និងឧបាសិកា សឹម កឿន | $ 50 US |
| -ឧបាសក កុក ឆាយ និងកូនប្រុស ឧបាសក តាំង សុផល និងភរិយា ព្រមទាំងបុត្ត នៅខេត្តបាត់ដំបង | $ 50 US |
| -ឧបាសិកា សៀន សេង និងបុត្ត | $ 20 US |
| -ឧបាសក ឡាង ឆរី និងភរិយា ព្រមទាំងបុត្ត | $ 20 US |
| -ឧបាសក ម៉ឺន ប៊ុនហេង និងឧបាសិកា កូវ៉ាញ | $ 20 US |
| -ឧបាសក ប៉ោ ហេង និងឧបាសិកា លន់ ឈុនលី | $ 20 US |
| -ឧបាសិកា ពិន សាម៉ុន | $ 20 US |
| -ឧបាសក កែវ សារិន ឧបាសិកា សំឯម | $ 15 US |
| -ឧបាសិកា ប៊ុន សារុំ | $ 10 US |
| -ឧបាសិកា ហាក់ សៃហេង | $ 10 US |
| -ឧបាសិកា ទេព សុផល | $ 10 US |
| -ឧបាសិកា ទេព ណាម | $ 10 US |
| -ឧបាសក គឹម កក់ និងភរិយា ពិសី | $ 10 US |
| -ឧបាសិកា ទឹម សារី និងបុត្ត | $ 10 US |
| -អ្នកស្រី បុប្ផអ៊ីវ និងស្វាមី ព្រមទាំងបុត្ត | $ 10 US |
| -ឧបាសក យិន ឈូ និងភរិយា ព្រមទាំងបុត្ត | $ 6 US |
| -ឧបាសក តាំង សុខឡាយ ឧបាសិកា សន ស៊ីណែត និងបុត្ត នៅខេត្តបាត់ដំបង | $ 5 US |

## នាមរាយនាមភិក្ខុចិត្តរក្សិតោ សំ សម្បត្តិ ប្រទេសអូស្ត្រាលី

| | |
|---|---|
| -ពុទ្ធបរិស័ទច្រើននាក់ " ម៉ែលបិន " | 955 AUS |
| -បុណ្យនៅផ្ទះឧបាសិកា លឹម ស៊ូឆេង | 627 AUS |
| -បុណ្យនៅផ្ទះឧបាសិកា ស៊ុយ មន្ថា ព្រមទាំងកូនចៅ | 450 AUS |
| -បុណ្យនៅផ្ទះឧបាសិកា អ៊ូច សុផល្លី ព្រមទាំងបុត្ត | 400 AUS |
| -ឧបាសក ឡៅ គីមងួន ឧបាសិកា ដួង លី | 200 AUS |
| -បុណ្យនៅផ្ទះឧបាសិកា តែ យក់ហ៊ុន | 200 AUS |
| -លោកជំទាវ " ឯកអគ្គរដ្ឋទូតអាឡឺម៉ង់ " | 100 US |
| -សូ បូរី | 100 AUS |
| -លោក ឥន ចាវ៉ាន់ ឧបាសិកា យ៉ុម យ៉ា | 100 AUS |
| -ឧបាសក ឱ មុយ ឧបាសិកា តែ ចាន់ណាវ៉ា | 100 AUS |
| -ឧបាសិកា ឯម ផាយ៉,ឆេង លន់,ម៉ា ឈូអៀ,អាប៊ួយ | 70 AUS |
| -ឧបាសក ឈិត ទ្រី ឧបាសិកា បាន់ ណៃហ៊ាង | 50 AUS |
| -ឧបាសិកា សុឃឿន ប៊ូ | 50 AUS |
| -ឧបាសក ឡុង ហ៊ន ឧបាសិកា លិម យូអេង និងបុត្ត | 50 AUS |
| -ឧបាសិកា ហេង ប៉េគី ព្រមទាំងកូនចៅ | 50 AUS |
| -ឧបាសិកា ស៊ុម គិមហេង | 50 AUS |
| -ឧបាសិកា ឃឹម វីឡាត់ | 50 AUS |
| -ឧបាសក តូ សវឿន ឧបាសិកា មាន សុវត្ថិ និងបុត្ត | 50 AUS |
| -ឧបាសក មង្គល ផន ឧបាសិកា គឹម លាភ ( មាណ) | 50 AUS |
| -ឧបាសិកា ហេង ងួនអ៊ីម | 50 AUS |
| -ឧបាសិកា ផ្លោក វណ្ណា | 40 AUS |
| -ឧបាសិកា សំ សុមុន្ថា ស្វាមី និងបុត្ត | 30 AUS |
| -ឧបាសិកា រ័ត្ន គីមសាន | 30 AUS |
| -ឧបាសិកា ខូវ ម៉េងលួង ព្រមទាំងស្វាមី និងបុត្ត | 30 AUS |
| -ឧបាសក ហៀក ប៉េងហួរ ឧបាសិកា ផ្លោក ម៉ុង | 30 AUS |
| -ឧបាសិកា ទូច សីណា និងស្វាមី | 20 AUS |
| -ឧបាសក ស៊ូ ឃីម ឧបាសិកា ស៊ូ សៀងតិច | 20 AUS |
| -ឧបាសក ប៉េង គ្រីគួ ឧបាសិកា គឹម សៀងគួ | 20 AUS |
| -ឧបាសិកា គង់ សម្បត្តិ | 20 AUS |

| | |
|---|---|
| -ឧបាសិកា ចំរើន រ៉ាក់ជិត | 20 AUS |
| -ឧបាសិកា តែ យក់ហ៊ុន | 20 AUS |
| -ឧបាសិកា យ៉ា យ៉ុម | 20 AUS |
| -ឧបាសិកា លឹម ស៊ូឆេង | 20 AUS |
| -ឧបាសក សន់ ប៊ុនភារ៍ ឧបាសិកា កាំង គឹមហាន | 20 AUS |
| -ឧបាសិកា ហេង ងួនអ៊ឹម | 20 AUS |
| -ឧបាសិកា យានី | 20 AUS |
| -សេង សៀងឈុន | 20 AUS |
| -ឧបាសក វ៉ាន់ យ៉ាណូរ៉េត ឧបាសិកា វ៉ាន់យ៉ាណូរី | 20 AUS |
| -ឧបាសិកា អ៊ុច សុផល្លី | 20 AUS |
| -ឧបាសិកា ឡាច សារឹម | 15 AUS |
| -ចៃស៊ុម,ចៃខេង,អាមួយ | 15 AUS |
| -ឧបាសិកា កូវ សារី | 15 AUS |
| -ឧបាសិកា ទូច ស៊ីណា | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លីសាង | 10 AUS |
| -ឧបាសិកា ទូច ស៊ីផា | 10 AUS |
| -ឧបាសិកា លាង ហុងប៊ុន | 10 AUS |
| -ឧបាសិកា សៀ ចន្ថា និងគ្រួសារ | 10 AUS |
| -ឧបាសិកា កាំង អ៊ីវហ៊្គិច | 10 AUS |
| -ឧបាសក ក្រូច សាន | 10 AUS |
| -ឧបាសិកា សា ចាន់ថា | 10 AUS |
| -ឧបាសក យឹម វ៉ាន់ ឧបាសិកា អ៊ុំ ខេង | 10 AUS |
| -ឧបាសក សុខ ជួន ឧបាសិកា សុខ ធួក | 10 AUS |
| -ឧបាសិកា អេង ងឹមសុខ | 10 AUS |
| -ឧបាសក ឃុត សរ ឧបាសិកា សុខ សច្ចា | 10 AUS |
| -ឧបាសិកា កេសរកូល និងគ្រួសារ | 5 AUS |
| -ឧបាសិកា វ៉ាណ្ណនីសា | 5 AUS |
| -ឧបាសិកា សាន់ ឆាយ, គីម ស្រួន | 5 AUS |

